សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

## ការប្រៀបធៀបរវាងការស៊ើបអង្កេតដោយមន្ត្រីនគរបាលយុត្តិធម៌ តាមក្រមនីតិវិធីព្រហ្មទណ្ឌ និងអង្គភាពប្រឆាំងអំពើពុករលួយ

ស្រាវជ្រាវ ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ មិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖

១. លោក **កែវ សុវណ្ណារិទ្ធ**

២. លោក **ជា តារាទុឌ្ឍ**

សាស្ត្រាចារ្យណែនាំ

លោក **រុន ពណ្ណារិទ្ធ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ ***កែវ សុវណ្ណរិទ្ធ*** និងខ្ញុំបាទឈ្មោះ **ជា តារាវុឌ្ឍ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតអស់ពីដួងចិត្តចំពោះ ៖

**លោកឪពុក អ្នកម្តាយ** ដែលមិនត្រឹមតែផ្តល់ជីវិតដ៏ប្រពៃនេះឲ្យយើងខ្ញុំប៉ុណ្ណោះទេ លោកថែមទាំងបានចិញ្ចឹមបីបាច់ ថែរក្សា ថ្នាក់ថ្នម និងលះបង់អស់កម្លាំងកាយចិត្តប្រកបដោយព្រហ្មវិហារធម៌អប់រំយើងខ្ញុំឲ្យក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ។ យើងខ្ញុំជាកូនមិនមានអ្វីតបស្នងដល់លោកទាំងពីរឲ្យសមទៅនឹងអំណោយ និងគុណូបការៈនេះទេ គឺមានតែការខិតខំប្រឹងប្រែងរៀនសូត្រ ហាត់ពត់ធ្វើជាមនុស្សល្អម្នាក់សម្រាប់ **លោកឪពុក អ្នកម្តាយ** និងសង្គមជាតិទាំងមូល។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងគណៈគ្រប់គ្រងសាកលវិទ្យាល័យទាំងអស់ ដែលបានដឹកនាំ សម្របសម្រួល និង ចាត់ចែងការសិក្សារបស់និស្សិត ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងស្មារតីពង្រឹងការបណ្តុះបណ្តាលធនធានមនុស្សឲ្យមានសមត្ថភាពខ្ពស់ ចំណេះដឹង បទពិសោធន៍ សីលធម៌ និងគុណធម៌ ដើម្បីជាទុនក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ជាតិមាតុភូមិ។

លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ព្រឹទ្ធបុរសនៃមហាវិទ្យាល័យនីតិសាស្ត្រ និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំសារណាមួយនេះអស់ពីកម្លាំងកាយចិត្ត ដោយលោកគ្រូ អ្នកគ្រូបង្ហាត់បង្រៀន ផ្តល់ដំបូន្មាន បទពិសោធន៍ថ្មីៗ ហើយថែមទាំងណែនាំឲ្យសិស្សបានធ្វើការងារដែលមានតំលៃនេះទទួលបានជោគជ័យចេញជាផ្លែផ្កាផងដែរ។ បន្ថែមពីនេះ លោកគ្រូ អ្នកគ្រូ គឺជាអ្នកដែលបានណែនាំឲ្យសិស្សមកពីតំបន់ផ្សេងគ្នា មានឱកាសសិក្សាជាមួយគ្នា រួមសុខរួមទុក្ខនឹងគ្នា ជាពិសេសគឺបានរៀនសូត្រ និងស្វែងយល់ពីគ្នាទៅវិញទៅមក។ យើងខ្ញុំសូមគោរពអរគុណលោកគ្រូ អ្នកគ្រូ ដែលបានពង្រីកចំណេះដឹងដល់សិស្ស និងបានផ្តល់ទ្រឹស្តីល្អៗដល់សិស្សសម្រាប់យកទៅអភិវឌ្ឍខ្លួននៅក្នុងសង្គម។ យើងខ្ញុំជានិស្សិតសូមប្តេជ្ញាថានឹងស្តាប់តាម ការពន្យល់ ការបង្ហាត់បង្រៀនរបស់លោកគ្រូ អ្នកគ្រូដើម្បីឲ្យសមនឹងពាក្យថា គ្រូល្អ សិស្សពូកែ។

សូមគោរពថ្លែងអំណរគុណជូនចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានបង្ហាត់បង្រៀន ណែនាំ និងផ្តល់ពុទ្ធិយ៉ាងច្រើនដល់យើងខ្ញុំជានិស្សិតជំនាន់ថ្មី ទទួលបានចំណេះជំនាញ បទពិសោធន៍ក្នុងជីវិត និងជាពិសេសមានសមត្ថភាពសមល្មមនឹងប្រកបវិជ្ជាជីវៈដើម្បីបម្រើផលប្រយោជន៍ជាតិមាតុភូមិមួយនេះ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកគ្រូអ្នកគ្រូដែលបានបង្ហាត់បង្រៀន យើងខ្ញុំតាំងពីបឋមសិក្សា រហូតដល់យើងខ្ញុំអាចមានវាសនារៀនថ្នាក់ឧត្តមសិក្សានេះ។ គុណរបស់លោកគ្រូអ្នកគ្រូពិតជាធំធេងណាស់ ហើយសិស្សមានតែការខិតខំបន្ថែមដើម្បីជាការតបស្នង និងជាក្តីសង្ឃឹមពិតរបស់ លោកគ្រូអ្នកគ្រូ និងប្រទេសជាតិ។

យើងខ្ញុំក៏មិនភ្លេចដែរចំពោះការជួយជ្រោមជ្រែងរបស់បងប្អូន ញាតិមិត្ត ដោយបានប្រមូលឯកសារពិគ្រោះយោបល់បន្ថែម និងចែករំលែកបទពិសោធន៍ជាច្រើនក្នុងការសរសេរសារណាមួយនេះ។

ជាទីបញ្ចប់ យើងខ្ញុំសូមគោរពអរគុណយ៉ាងក្រៃលែងជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និងបងបងយោធាដ៏ក្លាហាន ដែលបានលះបង់កម្លាំងកាយចិត្តក្នុងការរក្សាការពារសន្តិភាព ហើយរួមគ្នាអភិវឌ្ឍន៍ប្រទេសដ៏ផូរផង់របស់យើង។ ទង្វើទាំងនេះ ពិតជាបានផ្តល់ឱកាសឲ្យយើងខ្ញុំបានសិក្សារៀនសូត្រ មានឱកាសជួបគ្នា អង្គុយក្នុងថ្នាក់រៀនប្រកបដោយផាសុកភាពមួយ ហើយថែមទាំងមានឱកាសធ្វើជាពលរដ្ឋ ដែលមានសិទ្ធិគ្រប់គ្រាន់ក្នុងសង្គមកម្ពុជានេះ។

យើងខ្ញុំសូមប្រគេនពរ និងជូនពរដល់អ្នកមានគុណទាំងអស់ សូមប្រសិទ្ធពរជ័យសិរី មង្គល វិបុលសុខគ្រប់ប្រការចូលកើតមានដល់លោកទាំងអស់ឲ្យជួបប្រទះនូវពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បាតុភូតអសកម្មក្នុងសង្គមនីមួយៗតែងតែកើតមានឡើងនៅលើសកលលោកនេះ តាំងពីក្នុងសម័យអតីតកាលដ៏យូរលង់ណាស់មកហើយ។ ដើម្បីជាការឆ្លើយតបទៅនឹងបាតុភូតអវិជ្ជមានដែលជាបទល្មើសនេះ សង្គមមនុស្សនៅគ្រប់សម័យកាលរមែងបង្កើតយន្តការទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសសមស្របទៅតាមបរិបទនៃសង្គមនីមួយៗ។ ព្រមគ្នាជាមួយនឹងការវិវត្តនៃសង្គមជនល្មើសក៏បានធ្វើការអភិវឌ្ឍខ្លួន តតាំងនឹងយន្តការនានាដែលរដ្ឋនីមួយៗបានបង្កើតឡើង។ ទន្ទឹមនឹងនេះ ប្រភេទនៃបទល្មើស និងរូបភាពនៃបទល្មើសក៏ចេះតែប្រែប្រួលបន្តិចម្តងៗ ហើយអ្នកទប់ស្កាត់ និងអ្នកបង្ក្រាបក៏ចេះតែអភិវឌ្ឍន៍សមត្ថភាព ឧបករណ៍ គតិយុត្ត និងបច្ចេកវិទ្យាផ្សេងៗរបស់ខ្លួនឲ្យកាន់តែប្រសើរឡើងថែមទៀត ប្រឈមមុខនឹងស្ថានភាពថ្មីៗនៃបទល្មើសបែបនេះ។ មិនខុសប្លែកអ្វីពីប្រទេសផ្សេងទៀតទេ ព្រះរាជាណាចក្រកម្ពុជាក៏បានជួបប្រទះនឹងបាតុភូតរបៀបនេះដែរ។ ក្នុងគោលដៅដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈឲ្យកាន់តែមានភាពប្រសើរឡើង ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៧ ដោយក្នុងនោះមានមន្ត្រីនគរបាលយុត្តិធម៌ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ក្រាបបទល្មើស ក្នុងនាមជាអ្នកជំនួយអំណាចតុលាការ។ ក៏ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌក៏បានទុកលទ្ធភាពឲ្យច្បាប់ផ្សេង ដើម្បីបង្កើតនូវបទប្បញ្ញត្តិជាលក្ខណៈពិសេស សម្រាប់មន្ត្រីនគរបាលយុត្តិធម៌ដោយឡែក ចំពោះបទល្មើសជាក់លាក់ណាមួយផងដែរ។

ក្នុងទស្សនវិស័យនេះ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ក៏ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១០ ហើយអង្គភាពប្រឆាំងអំពើពុករលួយក៏ត្រូវបានផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីចាត់ការលើបទល្មើសពុករលួយ។ ជាក់ស្តែង អង្គភាពប្រឆាំងអំពើពុករលួយ គឺជាស្ថាប័នថ្មីមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយជាស្ថាប័នដែលត្រូវបានសាធារណជនស្គាល់ច្រើន បើប្រៀបធៀបទៅនឹងស្ថាប័នដែលទើបតែបង្កើតថ្មីៗដទៃទៀត។ ការទាញចំណាប់អារម្មណ៍របស់សាធារណជន យ៉ាងទូលំទូលាយបែបនេះ គឺដោយសារតែប្រសិទ្ធភាពនៃស្នាដៃជាក់ស្តែងរបស់អង្គភាពប្រឆាំងអំពើពុករលួយ ដែលបានធ្វើការបង្ក្រាបបទល្មើសសំខាន់ៗមួយចំនួនដែលមិនធ្លាប់មានកាលពីអតីតកាលកន្លងទៅ។ ស្ថិតនៅក្នុងបរិបទបែបនេះហើយ ទើបយើងខ្ញុំយល់ឃើញថា ការសិក្សាប្រៀបធៀបរវាងមន្ត្រីនគរបាលយុត្តិធម៌តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ ប្រាកដជាអាចចូលរួមចំណែកក្នុងការបង្កើនចំណេះដឹងបន្ថែមទៀតលើវិស័យថ្មីមួយដែលកំពុងតែទទួលបានការចាប់អារម្មណ៍ជាពិសេសពីមជ្ឈដ្ឋានទូទៅ។

ថ្ងៃសុក្រ ៦កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............ ១

**ជំពូកទី ១ សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌**

**១. មន្ត្រីនគរបាលយុត្តិធម៌តាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ** ............ ៣

១.១. ការទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌តាមរយៈសញ្ញាបត្រ ............ ៣

១.២. ការទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌តាមឋានន្តរសក្តិ និងមុខងារ ............ ៤

**២. មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ** ............ ៥

**ជំពូកទី ២ សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌**

**១. សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌** ............ ៨

១.១. សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌តាមក្រមនីតិវិធីព្រហ្មទណ្ឌ ............ ៨

១.២. សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ ............ ៩

**២. សមត្ថកិច្ចសម្ភារៈរបស់មន្ត្រីនគរបាលយុត្តិធម៌** ............ ១០

២.១. សមត្ថកិច្ចសម្ភារៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ ............ ១០

២.២. សមត្ថកិច្ចសម្ភារៈរបស់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ ............ ១១

២.២.១. បទល្មើសពុករលួយ តាមបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ............ ១២

២.២.១.១. បទល្មើសពុករលួយក្នុងវិស័យឯកជន ............ ១២

ក. បទស៊ីសំណូកនៃនិយោជិត និង បទសូកប៉ាន់ដល់និយោជិត ............ ១២

ខ. បទស៊ីសំណូករបស់អភិបាល ............ ១៣

គ. បទដេញថ្លៃមិនត្រឹមត្រូវ ............ ១៤

ឃ. ការសម្អាតប្រាក់ ............ ១៥

២.២.១.២. បទល្មើសពុករលួយដែលធ្វើឲ្យប៉ះពាល់ដល់វិស័យយុត្តិធម៌ ............ ១៥

ក. បទស៊ីសំណូកប្រព្រឹត្តដោយចៅក្រម និងបទសូកប៉ាន់ចំពោះចៅក្រម ............ ១៥

ខ. បទស៊ីសំណូករបស់សាក្សី ដើម្បីធ្វើសក្ខីកម្មក្លែងក្លាយ និងបទសូកប៉ាន់សាក្សី ............ ១៦

គ. បទស៊ីសំណូករបស់អ្នកបកប្រែ និងបទសូកប៉ាន់អ្នកបកប្រែ ........................................ ១៧
ឃ. បទស៊ីសំណូករបស់អ្នកជំនាញ និងបទសូកប៉ាន់អ្នកជំនាញ ........................................ ១៧
២.២.១.៣. បទល្មើសពុករលួយដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការរបស់រដ្ឋបាលសាធារណៈ ........ ១៨
ក. វីតិក្រម ........................................ ១៨
ខ. បទស៊ីសំណូក និងបទសូកប៉ាន់ ........................................ ១៩
គ. ជំនួញឥទ្ធិពល ........................................ ២០
ឃ. ការកេងយកផលប្រយោជន៍ដោយខុសច្បាប់ ........................................ ២១
ង. បទបក្ខានុគ្រោះ ........................................ ២១
ច. បទបំផ្លាញដោយចេតនា និង គៃបំបាត់ដោយទុច្ចរិត ........................................ ២២
ឆ. បទសម្លុតគំរាម ........................................ ២៣
២.២.១.៤. បទល្មើសពុករលួយដែលធ្វើឲ្យប៉ះពាល់ដល់ទំនុកចិត្តសាធារណៈ ........................................ ២៤
ក. បទស៊ីសំណូក និងបទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិត បញ្ជាក់មិនពិត .... ២៤
ខ. បទស៊ីសំណូក និងបទសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាង
វេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត ........................................ ២៥
២.២.២. បទល្មើសពុករលួយ តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ........................................ ២៥
២.២.២.១. បទល្មើសពាក់ព័ន្ធនឹងការប្រកាសទ្រព្យសម្បត្តិ ........................................ ២៥
ក. បទមានទ្រព្យសម្បត្តិដោយខុសច្បាប់ ........................................ ២៦
ខ. បទមិនប្រកាសទ្រព្យសម្បត្តិ និងបំណុល ........................................ ២៦
២.២.២.២. បទល្មើសពាក់ព័ន្ធនឹងដំណើរការនីតិវិធីទាក់ទងនឹងបទល្មើសពុករលួយ ........................................ ២៧
ក. បទទម្លាយការសម្ងាត់នៃប្រភពព័ត៌មានស្តីពីអំពើពុករលួយ ........................................ ២៧
ខ. បទរារាំង និងជ្រៀតជ្រែកដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ ........................................ ២៧
គ. បទប្តឹងបរិហារដោយភូតកុហក ........................................ ២៨
ឃ. បទបំពានលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក ........................................ ២៨
២.២.២.៣. បទល្មើសបន្ថែម ........................................ ២៩

ក. បទស៊ីសំណូក និង សូកប៉ាន់ចំពោះបុគ្គលដែលមិនមានចែងនៅក្នុង ក្រមព្រហ្មទណ្ឌ .......... ២៩
ខ. បទល្មើសពុករលួយតូចតាច ........................................................................................ ៣០
គ. បទទទួលផលបន្តពីបទល្មើសពុករលួយ ........................................................................ ៣០
ឃ. បទរំលោភអំណាច ..................................................................................................... ៣១

**ជំពូកទី ៣ បុព្វសិទ្ធិពិសេសក្នុងកិច្ចស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ ធៀបនឹងមន្ត្រីនគរបាលយុត្តិធម៌តាមក្រមនីតិវិធីព្រហ្មទណ្ឌ**

**១. បុព្វសិទ្ធិពិសេសរបស់អង្គភាពប្រឆាំងអំពើពុករលួយ** ..................................... ៣៤
១.១. ការឆែកឆេរការិយាល័យមេធាវី ................................................................................ ៣៤
១.២. បញ្ជាឲ្យចូលខ្លួន ..................................................................................................... ៣៤
១.៣. ការស្តាប់ និងថតការឆ្លើយឆ្លងតាមទូរស័ព្ទ ឬមធ្យោបាយទូរគមនាគមន៍ ផ្សេងទៀត.................... ៣៥
១.៤. អធិបញ្ញា និងការស្នើសុំការសហការជាមួយអាជ្ញាធរសាធារណៈ ......................................... ៣៥
១.៥. ការផ្អាកបណ្តោះអាសន្ននូវមុខងារ ................................................................................ ៣៦
១.៦. ការស្នើសុំធ្វើបត្យាប័ន ................................................................................................ ៣៦
១.៧. ការស្នើសុំបង្កកទ្រព្យសម្បត្តិ ...................................................................................... ៣៧
**២. កិច្ចស៊ើបអង្កេតដែលមានលក្ខណៈដូចគ្នាសម្រាប់មន្ត្រីនគរបាលយុត្តិធម៌ នៃអង្គភាពប្រឆាំងអំពើពុករលួយ និងមន្ត្រីនគរបាលយុត្តិធម៌ផ្សេងទៀត** .................................... ៣៨
២.១. ការអនុលោមតាមវិធានការស្រាវជ្រាវដូចគ្នា................................................................... ៣៩
២.១.១. ការបើកការស៊ើបអង្កេតបឋម ................................................................................ ៣៩
២.១.២. ការចាប់យកវត្ថុតាង.............................................................................................. ៣៩
២.១.៣. ការស្តាប់ចម្លើយ ................................................................................................... ៣៩
២.១.៤. កោសល្យវិច័យ ...................................................................................................... ៤០
២.២. នីតិវិធីក្រោយការឃាត់ខ្លួនជនសង្ស័យ ......................................................................... ៤០
២.២.១. ការបញ្ជូនជនសង្ស័យ ........................................................................................... ៤០

២.២.២. ការអនុវត្តកិច្ចផ្សេងៗតាមការបញ្ជាដោយចៅក្រម ........................................................ ៤១
**សេចក្ដីសន្និដ្ឋាន** ........................................................................................................ ៤៣
**អនុសាសន៍** ................................................................................................................ ៤៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

អនុលោមតាមមាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់នូវសមាសភាពរបស់ នគរបាលយុត្តិធម៌ ចែកចេញជាបីប្រភេទគឺ ៖ *មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ព្រមទាំងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន។* តាមន័យនៃមាត្រាខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌ គឺជាសមាសភាពមួយនៃនគរបាលយុត្តិធម៌ ដែលមានតួនាទីជាជំនួយរបស់អំណាចតុលាការក្នុងការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់ អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។ យ៉ាងណាមិញ នៅក្នុងចំណោមសមាសភាពរបស់នគរបាលយុត្តិធម៌ដូចដែលបានរៀបរាប់ខាងលើ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានប្រគល់តួនាទីយ៉ាងសំខាន់នៅក្នុងការត្រួតពិនិត្យបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ដែលជាបុគ្គលមានសមត្ថកិច្ចក្នុងការពិនិត្យ បង្ក្រាបបទល្មើស ក៏ត្រូវបានបែងចែកសមត្ថកិច្ចទៅតាមជំនាញនីមួយៗផងដែរ ដើម្បីអាចឲ្យការធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងន័យនេះ ថ្វីបើក្រមនីតិវិធីព្រហ្មទណ្ឌបានចែងពីបទបញ្ញត្តិទូទៅនៃនីតិវិធី ព្រមទាំងបានកំណត់នូវសមាសភាពជាក់លាក់នៃមន្ត្រីនគរបាលយុត្តិធម៌ក៏ដោយ ក៏ក្រមនីតិវិធីព្រហ្មទណ្ឌនៅតែប្រគល់សមត្ថកិច្ចឲ្យច្បាប់ដោយឡែក ដើម្បីកំណត់នូវមន្ត្រីនគរបាលយុត្តិធម៌ជំនាញដោយឡែក សម្រាប់បទល្មើសពិសេសណាមួយដែលមានចែងនៅក្នុងច្បាប់។ ហេតុដូច្នេះហើយ រដ្ឋបាលព្រៃឈើត្រូវបានចាត់ទុកថាជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចក្នុងការពិនិត្យបទល្មើសព្រៃឈើ ហើយក៏ត្រូវបានប្រគល់នូវអំណាចពិសេសដោយឡែកខ្លះៗ បើប្រៀបធៀបទៅនឹងបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ដូចគ្នានេះផងដែរ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយត្រូវបានរៀបចំតាក់តែងឡើង ដោយប្រើប្រាស់ពេលវេលាជាយូរ ហើយនៅទីបំផុតក៏ត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/00៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០១០។ ដោយឡែក លក្ខណៈពិសេសមួយនៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ គឺការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដល់អង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់ធ្វើការពិនិត្យបទល្មើសពុករលួយ។ ម្យ៉ាងវិញទៀត ដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ដែលក្នុងនោះរួមមាន ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ[1] ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយត្រូវបានធ្វើវិសោធនកម្ម ហើយច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨១១/ ០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដែលបានផ្តល់សិទ្ធិឲ្យប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ក្នុងការចេញប្រកាសរៀបចំរចនាសម្ព័ន្ធ របស់អង្គភាពប្រឆាំងអំពើពុករលួយ ចាប់ពីថ្នាក់ក្រោមនាយកដ្ឋាន និងការតែងតាំងផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីក្របខណ្ឌ

[1] មាត្រា ៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/00៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០។

ស្ថាប័នប្រឆាំងអំពើពុករលួយ ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋានតាម សំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។ ជាពិសេសទៅទៀត ស្ថាប័នប្រឆាំងអំពើពុករលួយមានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការការងារខ្លួន ដែលស្ថិតនៅក្នុងថវិការបស់ជាតិ។ ជាងនេះទៅទៀត ស្ថាប័នប្រឆាំងអំពើពុករលួយក៏អាចទទួលធនធានចាំបាច់នានាពីរាជរដ្ឋាភិបាល និងមានសិទ្ធិទទួលអំណោយ ឬជំនួយពីអង្គការជាតិ អន្តរជាតិនានាផងដែរ[2]។

ក្នុងបរិបទបែបនេះហើយ ការលើកយកប្រធានបទស្តីពីការប្រៀបធៀបមន្ត្រីនគរបាលយុត្តិធម៌ តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយយកមកធ្វើការវិភាគសិក្សាអាចអនុញ្ញាតឲ្យយើងយល់ដឹងជ្រួតជ្រាបកាន់តែច្បាស់ពី លក្ខណៈពិសេសរបស់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ ដែលត្រូវបានផ្តល់បុព្វសិទ្ធិពិសេសមួយចំនួនធំ ក្នុងគោលដៅធានាឲ្យបាននូវការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន សមស្របទៅតាមលក្ខណៈពិសេសនៃបទល្មើសពុករលួយ ដែលជាទូទៅរមែងប្រព្រឹត្តឡើងដោយបុគ្គលដែលមានឋានៈ បុណ្យសក្តិខ្ពស់នៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រង។ ដូច្នេះ នៅក្នុងក្របខ័ណ្ឌនៃសារណាមួយនេះ យើងខ្ញុំនឹងលើកយកបញ្ហាចម្បងបីយ៉ាងដែលពាក់ព័ន្ធនឹងមន្ត្រីនគរបាលយុត្តិធម៌មកធ្វើការសិក្សាប្រៀបធៀប គឺសមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ **(ជំពូកទី ១)** សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ **(ជំពូកទី ២)** និង កិច្ចស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ដោយផ្តោតជាសំខាន់ទៅលើបុព្វសិទ្ធិពិសេសរបស់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយបើប្រៀបនឹងមន្ត្រីនគរបាលយុត្តិធម៌តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ **(ជំពូកទី ៣)** ។

---

[2] មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០។

# ជំពូកទី១
# សមាសភាពរបស់
# មន្ត្រីនគរបាលយុត្តិធម៌

# ជំពូកទី ១
# សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌

មាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់វិធីពីរយ៉ាងដើម្បីទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ពោលគឺ តាមរយៈសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ និងតាមរយៈឋានន្តរសក្តិមុខងារ។ ដោយឡែក ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដល់ប្រធាន អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ព្រមទាំងមន្ត្រីនៃអង្គភាពនេះផងដែរ។

## ១. មន្ត្រីនគរបាលយុត្តិធម៌តាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដូចបានបញ្ជាក់ខាងលើ មាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់មធ្យោបាយចំនួនពីរយ៉ាងដើម្បីទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។

### ១.១. ការទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌តាមរយៈសញ្ញាបត្រ

ដើម្បីទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌តាមវិធីនេះ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

-មន្ត្រីនគរបាលជាតិមានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបម្រើការងារយ៉ាងតិចបំផុតពីរឆ្នាំ នៅក្នុងនគរបាលជាតិ ឬជានាយទាហាននៃកងរាជអាវុធហត្ថដែលបានបម្រើការងារយ៉ាងតិចបំផុតពីរឆ្នាំ នៅក្នុងកងរាជអាវុធហត្ថ។

-ការទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ នឹងត្រូវផ្តល់ជូន ក្រោយពីបានឆ្លងកាត់ការប្រលងបែបវិជ្ជាជីវៈ ដែលរួមមានវិញ្ញាសាជាមូលដ្ឋានដូចតទៅ ៖ នីតិព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ និងករណីយកិច្ចសាស្ត្រដូចមានចែងនៅក្នុងក្រមសីលធម៌ដែលតាក់តែងដោយអង្គការសហប្រជាជាតិ។ ការប្រលងបែបវិជ្ជាជីវៈនេះ ត្រូវរៀបចំឡើងដោយគណៈមេប្រយោគមួយ ស្ថិតក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលមុខងារនេះ[3]។ តាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ គណៈមេប្រយោគដែលទទួលបន្ទុកលើការប្រលងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ រួមមាន ៖ ចៅក្រមស៊ើបសួរម្នាក់ដែលតែងតាំងដោយប្រធានតុលាការកំពូល ចៅក្រមអយ្យការម្នាក់ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល និង តំណាងមកពីក្រសួងមហាផ្ទៃចំនួន ០២ នាក់ នៅក្នុងករណីដែលបេក្ខជនប្រលងជាមន្ត្រីនគរបាលជាតិ និង តំណាងមកពីក្រសួងការពារជាតិចំនួន ០២ នាក់ នៅក្នុងករណីដែលបេក្ខជនប្រលង

[3] មាត្រា ៦១ និង មាត្រា ៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

គឺជាយោធិននៃកងរាជអាវុធហត្ថ។ សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ នឹងត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិទៅតាមករណីនីមួយៗ។

**១.២. ការទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌តាមឋានន្តរសក្តិ និងមុខងារ**

យោងតាមបទប្បញ្ញត្តិនៃមាត្រា ៦០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានរៀបរាប់ពីមុខងារ និងឋានន្តរសក្តិដែលផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ក្នុងនោះរួមមាន ៖

-អភិបាល អភិបាលរង ខេត្ត ក្រុង អភិបាល អភិបាលរង ស្រុក ខណ្ឌ និង មេឃុំ ចៅសង្កាត់។

-ប្រធាន និង អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និង ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

-ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និង អនុប្រធានផ្នែកដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ។ នៅត្រង់ចំណុចនេះ គេឃើញមានដូចជានាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នាយកដ្ឋាននគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ។ល។

-ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃ ៖

- នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"
- មន្ទីរប្រឆាំងគ្រឿងញៀន
- នាយកដ្ឋាននគរបាលទេសចរណ៍
- ស្នងការពិសេសការពារបេតិកភណ្ឌ។

-ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង។

-ប្រធាន អនុប្រធានការិយាល័យ ប្រធាន អនុប្រធានផ្នែក ដែលទទួលបន្ទុកការងារព្រហ្មទណ្ឌ ចំណុះស្នងការដ្ឋាននគរបាលខេត្ត ក្រុង ដូចជា ៖

- ការិយាល័យព្រហ្មទណ្ឌកំរិតធ្ងន់ និង ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- ការិយាល័យប្រឆាំងគ្រឿងញៀន

- ការិយាល័យប្រឆាំងភេរវកម្ម និង
- ការិយាល័យជនបរទេស។

-អធិការ អធិការរង ប្រធាន និង អនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុកខណ្ឌ។

-ប្រធាន អនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន អនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ"។ ប្រធាន អនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែកគ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធជាតិផ្ទុះ" ។ ប្រធាន និង អនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍។

-ប្រធាន និង អនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ"។

-មេបញ្ជាការ និង មេបញ្ជាការរងនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

-មេបញ្ជាការ និង មេបញ្ជាការរងនៃកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

-មេបញ្ជាការ និង មេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុកខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

-ប្រធាន និង អនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថ ទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

-ប្រធាន និង អនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់។

## ២. មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ

យោងតាមមាត្រា ២៣ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានកំណត់ថា ប្រធាន និង អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ មានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដោយពេញច្បាប់។ ដូចដែលបានចែងនៅមាត្រា ១១ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវដឹកនាំដោយប្រធានមួយរូបដែលមានឋានៈស្មើទេសរដ្ឋមន្ត្រី និងមានអនុប្រធានមួយចំនួនមានឋានៈជារដ្ឋមន្ត្រី ដែលជាជំនួយការតាមការចាំបាច់។ ប្រធាន និងអនុប្រធានរបស់អង្គភាពប្រឆាំងអំពើពុករលួយត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។ ប្រធាន និងអនុប្រធានត្រូវមានលក្ខណៈសម្បត្តិដូចតទៅ[4] ៖

-មានសញ្ជាតិខ្មែរពីកំណើត។

-មានសីលធម៌ល្អ និង កេរ្តិ៍ឈ្មោះស្អាតស្អំ។

-មិនដែលមានទោសមជ្ឈិម ឬឧក្រិដ្ឋ ឬមិនមានក្ស័យធន។

---

[4] មាត្រា ១២ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០។

-មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ។

-មានបទពិសោធន៍ការងារក្នុងសង្គមយ៉ាងតិច ៧ ឆ្នាំ។

-មានអាយុយ៉ាងតិច ៣៥ ឆ្នាំ។

ក្រៅពីនេះទៀត មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយក៏អាចទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ផងដែរ។ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយជាអ្នករៀបចំបញ្ជីឈ្មោះមន្ត្រីនៃអង្គភាពដែលត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌។ ដោយផ្អែកលើបញ្ជីឈ្មោះនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចេញប្រកាសសម្រេចប្រគល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ជូនមន្ត្រីទាំងនោះ។ ជាក់ស្តែង តាមរយៈប្រកាសលេខ ១០៩ កយ.ប្រក/១១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ ស្តីពីការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឃើញថាមន្ត្រីរាជការចំនួន ៧៧ នាក់ ដែលបម្រើការងារនៅអង្គភាពប្រឆាំងអំពើពុករលួយត្រូវបានទទួលស្គាល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌។

ជាងនេះទៀត នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួន ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចប្រើប្រាស់ធនធានមនុស្ស សម្ភារៈ ឧបករណ៍ បច្ចេកទេសនៃនាយកដ្ឋានចារកម្ម ស៊ើបអង្កេត និងកម្លាំងពិសេសវាយលុកភេរវកម្មនៃនាយកដ្ឋានពិសេសនៃលេខាធិការដ្ឋានជាតិប្រឆាំងភេរវកម្មហើយមិនត្រឹមតែប៉ុណ្ណោះ ប្រធានអង្គភាពក៏មានសិទ្ធិស្នើសុំកិច្ចសហប្រមូលព័ត៌មាន និង តាមដានពីផ្នែកចារកម្មពីស្ថាប័ននានា និងសុំកម្លាំងប្រតិបត្តិការពីនគរបាលជាតិ កងរាជអាវុធហត្ថ និងកម្លាំងប្រដាប់អាវុធផ្សេងទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ[5] ។

ស្របពេលជាមួយគ្នានេះ ដើម្បីជានាយល់ឲ្យកាន់តែច្បាស់ពីអង្គភាពប្រឆាំងអំពើពុករលួយ យើងខ្ញុំសូមបង្ហាញជូនពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ ដោយផ្អែកតាមអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ។

តាមការពិត អង្គភាពប្រឆាំងអំពើពុករលួយមិនមែនដើរតួនាទីត្រឹមតែជាមន្ត្រីនគរបាលយុត្តិធម៌ ដែលមានភារកិច្ចអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយតែប៉ុណ្ណោះទេ គឺថែមទាំងមានភារកិច្ចក្នុងការទប់ស្កាត់ និងបង្ការអំពើពុករលួយផងដែរ[6] ។

ហេតុដូច្នេះ រចនាសម្ព័ន្ធរបស់អង្គភាពនេះក៏ត្រូវបានអនុលោមទៅតាមស្ថានភាពនេះដែរ ។ អង្គភាពប្រឆាំងអំពើពុករលួយមានរចនាសម្ព័ន្ធដូចតទៅ[7] ៖

១-អគ្គនាយកដ្ឋានរដ្ឋបាល និងសន្តិសុខ

[5] មាត្រា ៧ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១។

[6] មាត្រា ១៣ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០។

[7] មាត្រា ៤ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១។

២-អគ្គនាយកដ្ឋានប្រតិបត្តិការ

៣-ផ្នែកស៊ើបអង្កេតផ្ទៃក្នុង

៤-ការិយាល័យប្រឆាំងអំពើពុករលួយរាជធានី ខេត្ត

៥-ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ។

អគ្គនាយកដ្ឋានរដ្ឋបាល និង សន្តិសុខ មានតួនាទីជាសេនាធិការឲ្យអង្គភាពប្រឆាំងអំពើពុករលួយលើការងារសម្របសម្រួល និងគ្រប់គ្រងកិច្ចការរដ្ឋបាលហិរញ្ញវត្ថុ បុគ្គលិកបណ្តុះបណ្តាល សន្តិសុខ ប្រកាសទ្រព្យសម្បត្តិ និងបំណុល ហើយអគ្គនាយកដ្ឋាននេះមាននាយកដ្ឋានក្រោមឱវាទចំនួន ៤ គឺ ៖ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ - នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល - នាយកដ្ឋានសន្តិសុខ និងនាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុល[8]។

ចំណែកឯអគ្គនាយកដ្ឋានប្រតិបត្តិការ មានតួនាទីជាសេនាធិការឲ្យអង្គភាពប្រឆាំងអំពើពុករលួយលើការងារសម្របសម្រួល និងគ្រប់គ្រងកិច្ចការគតិយុត្ត ទទួលពាក្យប្តឹង ស៊ើបអង្កេត និង ចារកម្ម បច្ចេកទេស និងកោសល្យវិច័យ អប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ បង្ក្រាប និងទំនាក់ទំនងអន្តរជាតិ។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានក្រោមឱវាទចំនួន ៤ គឺ ៖ នាយកដ្ឋានកិច្ចការគតិយុត្ត ពាក្យប្តឹង និងអន្តរជាតិ នាយកដ្ឋានអប់រំ បង្ការ និងទប់ស្កាត់ នាយកដ្ឋានបច្ចេកទេស និងកោសល្យវិច័យ និងនាយកដ្ឋានស៊ើបអង្កេត និងចារកម្ម[9]។

ក្រៅពីនេះ ផ្នែកស៊ើបអង្កេតផ្ទៃក្នុងមានភារកិច្ចឃ្លាំមើល និងតាមដានពីសកម្មភាពការងាររបស់មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ[10]។ រីឯក្រុមជនបង្គោលប្រឆាំងអំពើពុករលួយវិញ គឺត្រូវបានបង្កើតឡើងដើម្បីចូលរួមអប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើពុករលួយ[11]។

---

[8] មាត្រា ១០ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១។

[9] មាត្រា ១៥ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១។

[10] មាត្រា ២០ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១។

[11] មាត្រា ២២ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១។

# ជំពូកទី២
# សមត្ថកិច្ចរបស់
# មន្ត្រីនគរបាលយុត្តិធម៌

# ជំពូកទី ២
# សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងការបំពេញការងារ មន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពទៅតាមសមត្ថកិច្ចដែនដី ក៏ដូចជាសមត្ថកិច្ចសម្ភារៈដែលត្រូវបានកំណត់ដោយច្បាប់។ ខុសប្លែកពីសមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌តាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលកម្រិតសមត្ថកិច្ចដែនដីទៅតាមព្រំដែនជាកំណត់ អង្គភាពប្រឆាំងអំពើពុករលួយត្រូវបានផ្តល់សមត្ថកិច្ចដែនដីទូលំទូលាយ ប៉ុន្តែសមត្ថកិច្ចសម្ភារៈរបស់អង្គភាពប្រឆាំងអំពើពុករលួយត្រូវបានកម្រិតសម្រាប់តែបទល្មើសពុករលួយប៉ុណ្ណោះ។

## ១. សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌

សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌ សំដៅទៅលើព្រំដែនកំណត់ជាក់លាក់ណាមួយ ដែលមន្ត្រីនគរបាលយុត្តិធម៌អាចបំពេញភារកិច្ចរបស់ខ្លួនបាន។ វិធានទាក់ទងនឹងសមត្ថកិច្ចដែនដីមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះថា ការមិនគោរពតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងសមត្ថកិច្ចខាងដែនដី គឺជាមូលហេតុនាំឲ្យកិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ ខុសសមត្ថកិច្ចដែនដី ត្រូវទុកជាមោឃៈ[12]។

### ១.១. សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌តាមក្រមនីតិវិធីព្រហ្មទណ្ឌ

មាត្រា ៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា "មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗមានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាព ដែលខ្លួនត្រូវបានចាត់តាំងឲ្យទៅបម្រើការងារ"។ ជាធម្មតា សេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌រមែងបញ្ជាក់មណ្ឌលរដ្ឋបាល។ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចទៅតាមមណ្ឌលរដ្ឋបាល ដែលបានកំណត់នៅក្នុងសេចក្តីសម្រេចតែងតាំងនោះឯង។ ក្នុងន័យនេះ អធិការនគរបាលស្រុកកោះសូទិន ខេត្តកំពង់ចាម មានសមត្ថកិច្ចដែនដីនៅក្នុងព្រំប្រទល់នៃស្រុកកោះសូទិនតែប៉ុណ្ណោះ។

ទន្ទឹមនឹងនេះផងដែរ មន្ត្រីនគរបាលយុត្តិធម៌ខ្លះក៏ត្រូវបានតែងតាំងឲ្យបំពេញការងារដែលមានសមត្ថកិច្ចដែនដីទូលាយផងដែរ ដូចជាមន្ត្រីនគរបាលយុត្តិធម៌ នៅក្រសួងមហាផ្ទៃជាដើម ដែលអាចអនុវត្តតួនាទីរបស់ខ្លួនបាន លើដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូលតែម្តង។

ជាអញ្ញត្រកម្មទៅនឹងគោលការណ៍ខាងលើ ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឲ្យមានការពន្លាតសមត្ថកិច្ចដែនដី ក្នុងករណីពីរយ៉ាងគឺ ៖

-នៅរាជធានីភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចដែនដីនៅរាជធានីភ្នំពេញទាំងមូលតែម្តង ទោះបីជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានតែងតាំងឲ្យបំពេញការងារនៅត្រឹមខណ្ឌណាមួយក៏ដោយ[13]។ នេះគឺមក

[12] មាត្រា ៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[13] មាត្រា ៦៧ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ពីរាជធានីភ្នំពេញ មិនត្រឹមមានវិសាលភាពទូលំទូលាយនោះទេ ហើយក៏ជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច វប្បធម៌របស់ព្រះរាជាណាចក្រកម្ពុជា ដែលមានប្រជាពលរដ្ឋជាច្រើននាក់រស់នៅ ដូច្នេះការកម្រិតព្រំដែនសមត្ថកិច្ចដែនដីត្រឹមតែខណ្ឌ ឬ សង្កាត់ នឹងបង្កឲ្យមានឧបសគ្គយ៉ាងធំដល់ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌។

-ការអនុញ្ញាតឲ្យពន្លាតសមត្ថកិច្ចដោយព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរ ឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការលើវិសាលភាពនៃដែនដីជាតិទាំងមូល តាមខ្លឹមសារនៃមាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

តាមច្បាប់ ការអនុញ្ញាតឲ្យពន្លាតសមត្ថកិច្ចដោយព្រះរាជអាជ្ញា ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

-បទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្ដែង តាមអត្ថន័យនៃមាត្រា ៨៦ និងមាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្ដែងតាមមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សំដៅលើ ៖

- បទល្មើសដែលកំពុងប្រព្រឹត្ត។
- បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម។
- បទល្មើសត្រូវបានប្រព្រឹត្តរួចបន្តិចមក ហើយជនសង្ស័យត្រូវបានសាធារណជនស្រែកប្រផាប់ចាប់ប្រកីង ឬក៏បុគ្គលដែលត្រូវគេរកឃើញ មានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។

-ការបន្ទាន់ដែលតម្រូវឲ្យធ្វើប្រតិបត្តិការលើវិសាលភាពនៃដែនដីជាតិទាំងមូល។

ចំពោះការអនុញ្ញាតឲ្យពន្លាតសមត្ថកិច្ចដោយចៅក្រមស៊ើបសួរ គឺត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

-ចៅក្រមស៊ើបសួរបានចេញដីកាចាត់ឲ្យស៊ើបសួរជំនួស លើកិច្ចស៊ើបសួរណាមួយ ប្រគល់ឲ្យទៅមន្ត្រីនគរបាលយុត្តិធម៌។

-ការបន្ទាន់ដែលតម្រូវឲ្យធ្វើប្រតិបត្តិការលើវិសាលភាពនៃដែនដីជាតិទាំងមូល។

ជាងនេះទៅទៀត ប្រសិនបើត្រូវធ្វើប្រតិបត្តិការក្រៅមណ្ឌលដែនដីរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ខាងដែនដី ហើយចៅក្រមដែលជាអ្នកផ្ដល់ការអនុញ្ញាតឲ្យមានការពន្លាតសមត្ថកិច្ច ត្រូវជូនដំណឹងតាមគ្រប់មធ្យោបាយ ដល់ព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដី។

### ១.២. សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ

មាត្រា ១១ នៃច្បាប់ស្ដីពីការប្រឆាំងនឹងអំពើពុករលួយ បានចែងថា "ត្រូវបានបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ដែលមានឯករាជ្យភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួន"។ តាមបទបញ្ញត្តិនេះ សមត្ថកិច្ចដែនដីរបស់អង្គភាពប្រឆាំងអំពើពុករលួយ មិនត្រូវបានកម្រិតនោះឡើយ នេះមានន័យថា អង្គភាពប្រឆាំងអំពើពុករលួយមានសមត្ថកិច្ចដែនដីលើវិសាលភាពដែនដីជាតិ ទាំងមូលតែម្ដង។

ម្យ៉ាងវិញទៀត ទោះបីជាអង្គភាពប្រឆាំងអំពើពុករលួយ អាចមានការិយាល័យនៅគ្រប់រាជធានី-ខេត្ត នៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏ការិយាល័យនោះគ្រាន់តែជាបណ្ដាញការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយតែប៉ុណ្ណោះ ហើយការិយាល័យប្រឆាំងអំពើពុករលួយត្រូវអនុវត្តការងាររបស់ខ្លួន ក្រោមការដឹកនាំរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។ ក្នុងន័យនេះ គឺពុំមានបទប្បញ្ញត្តិណាមួយដែលកម្រិតសមត្ថកិច្ចដែនដីរបស់ការិយាល័យប្រឆាំងអំពើពុករលួយនៅតាមបណ្ដារាជធានី-ខេត្ត នោះឡើយ។

ជាក់ស្ដែង តាមប្រការ ២ នៃប្រកាសលេខ ១០៩ កយ.ប្រក/១១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ បានបញ្ជាក់ថា មន្ត្រីនគរបាលយុត្តិធម៌របស់អង្គភាពប្រឆាំងអំពើពុករលួយមានសមត្ថកិច្ចនៅលើវិសាលភាពទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ២. សមត្ថកិច្ចសម្ភារៈរបស់មន្ត្រីនគរបាលយុត្តិធម៌

អង្គភាពប្រឆាំងអំពើពុករលួយ គឺជាស្ថាប័នពិសេស ដែលត្រូវបានបង្កើតឡើងដោយច្បាប់ពិសេស ដូច្នេះ សមត្ថកិច្ចសម្ភារៈរបស់អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវបានកម្រិតឲ្យសមស្របទៅតាមគោលបំណងនៃការបង្កើតច្បាប់ពិសេស ពោលគឺច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ។ ចំណែកឯមន្ត្រីនគរបាលយុត្តិធម៌តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌវិញ មានសមត្ថកិច្ចសម្ភារៈទៅតាមប្រភេទនៃមន្ត្រីនគរបាលយុត្តិធម៌រៀងៗខ្លួន ។

### ២.១. សមត្ថកិច្ចសម្ភារៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់ពីសមត្ថកិច្ចសម្ភារៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ឲ្យជាក់លាក់ជាទូទៅនោះទេ ក៏ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់នូវសមត្ថកិច្ចជាក់លាក់ សម្រាប់មន្ត្រីនគរបាលយុត្តិធម៌ខ្លះ។ ក្នុងន័យបែបនេះ គេអាចបកស្រាយបានថា មន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មានសមត្ថកិច្ចសម្ភារៈសម្រាប់គ្រប់បទល្មើសព្រហ្ម-ទណ្ឌគ្រប់ប្រភេទ លើកលែងតែមានបទប្បញ្ញត្តិពិសេសរបស់ច្បាប់។

ជាក់ស្ដែង មាត្រា ៦០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់សមត្ថកិច្ចសម្ភារៈជាពិសេសរបស់មន្ត្រីនគរបាលខ្លះ។ ដូច្នេះ ប្រធាន អនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ មានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ សម្រាប់តែបទល្មើសចរាចរប៉ុណ្ណោះ។ បទល្មើសចរាចរសំដៅទៅលើបទល្មើសដែលមានចែងនៅក្នុងច្បាប់ចរាចរណ៍។ ដូចគ្នាដែរ ប្រធាន អនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ មានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ សម្រាប់តែបទល្មើសអាវុធជាតិផ្ទុះប៉ុណ្ណោះ។ បទល្មើសអាវុធជាតិផ្ទុះ សំដៅលើបទល្មើសដែលកើតឡើងដោយសារតែការប្រើប្រាស់អាវុធគ្រឿងផ្ទុះផ្សេងៗ សមស្របទៅតាមនិយមន័យដែលមានដែលមានចែងនៅក្នុងច្បាប់ស្ដីពីការគ្រប់គ្រង អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ។ ចំណែកឯប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃនាយកដ្ឋាននគរបាលព្រំដែន

មានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ សម្រាប់តែបទល្មើសឆ្លងដែនប៉ុណ្ណោះ។ សម្រាប់ពាក្យ "បទល្មើសឆ្លងដែន" គឺជាពាក្យដែលមានអត្ថន័យទូលំទូលាយ ហើយអាចឲ្យមានការបកស្រាយបានច្រើនយ៉ាង។ ពាក្យនេះអាចសំដៅទៅលើបទល្មើសពាក់ព័ន្ធនឹងការឆ្លងដែនខុសច្បាប់ ហើយក៏អាចសំដៅទៅលើបទល្មើសដែលធ្វើឡើងហួសពីកម្រិតនៃប្រទេសមួយ ដូចជាការជួញដូរមនុស្សឆ្លងដែន ជាដើម។

លើសពីនេះទៅទៀត ចំពោះបទល្មើសយោធា មានតែកងរាជអាវុធហត្ថទេ ដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌[14]។ បទល្មើសយោធាជាបទល្មើសពិសេស ហើយត្រូវបានច្បាប់ឲ្យនិយមន័យដោយឡែក។ ច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ត្រង់មាត្រា ៩ កំណត់និយមន័យបទល្មើសយោធាថា ជាបទល្មើសដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ហើយដែលពាក់ព័ន្ធនឹងវិន័យកងទ័ព ឬ ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ។ ម្យ៉ាងវិញទៀត មាត្រា ១១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ក៏បានឲ្យនិយមន័យប្រហាក់ប្រហែលគ្នានេះដែរ ដោយគ្រាន់តែបានបន្ថែមបញ្ជាក់ពីប្រភេទនៃយោធិនដែលអាចជាប់ទាក់ទងនឹងបទល្មើសយោធា។ បទប្បញ្ញត្តិខាងលើបានចែងថា បទល្មើសយោធាជាបទល្មើសដែលទាក់ទិនដល់យោធិន ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយដែលពាក់ព័ន្ធដល់បទវិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា។

***ឧទាហរណ៍៖*** យោធិនម្នាក់បានយករថយន្តរបស់អង្គភាពទៅលក់យកប្រាក់ចាយវាយផ្ទាល់ខ្លួន។ អំពើនេះគឺជាអំពើលួច ហើយត្រូវចាត់បញ្ចូលជាបទល្មើសយោធា និងស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការយោធា មិនមែនក្រោមសមត្ថកិច្ចរបស់សាលាដំបូងរាជធានី-ខេត្ត ឡើយ។

### ២.២. សមត្ថកិច្ចសម្ភារៈរបស់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ

យោងតាមអត្ថន័យនៃមាត្រា ២២ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយមានសមត្ថកិច្ចតែទៅលើបទល្មើសពុករលួយតែប៉ុណ្ណោះ។ ជាបដិបញ្ញត្តិទៅនឹងគោលការណ៍ខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌ក៏មានសមត្ថកិច្ចធ្វើការស៊ើបអង្កេតលើបទល្មើសផ្សេងទៀតផងដែរ ប្រសិនបើបទល្មើសនោះមានអង្គហេតុទាក់ទងនឹង បទល្មើសពុករលួយដែលមន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយបានធ្វើការស៊ើបអង្កេតនោះ។ ព្រមជាមួយគ្នានេះ អាជ្ញាធរតុលាការអាចបញ្ជាឲ្យអង្គភាពប្រឆាំងអំពើពុករលួយ ធ្វើការស៊ើបអង្កេតលើបទល្មើសផ្សេងពីបទល្មើសពុករលួយបានដែរ។

[14] មាត្រា ៨១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

បទល្មើសពុករលួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ គឺជាបទល្មើសដែលមានចែងនៅក្នុងជំពូកទី ៦ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ[15]។ ជារួមមក គេអាចកំណត់បានថា បទល្មើសពុករលួយមួយចំនួនមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ហើយក្រៅពីនេះគឺមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនេះតែម្តង។

### ២.២.១. បទល្មើសពុករលួយ តាមបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ

បទល្មើសពុករលួយតាមក្រមព្រហ្មទណ្ឌមានចំនួន ២៧ បទល្មើស ហើយត្រូវបានចែង នៅក្នុង ៤០ មាត្រា នៃក្រមព្រហ្មទណ្ឌ។ សរុបទៅ បទល្មើសទាំងនេះអាចត្រូវបានចែកចេញជា ៤ សណ្ឋាន រួមមានដូចតទៅ ៖

#### ២.២.១.១. បទល្មើសពុករលួយក្នុងវិស័យឯកជន

ពេលខ្លះ នៅពេលដែលគេនិយាយពីបញ្ហាពុករលួយ ភាគច្រើនគេតែងតែគិតសំដៅទៅរកវិស័យសាធារណៈ ពោលគឺមានការពាក់ព័ន្ធនឹងរាជការសាធារណៈ។ ក៏ប៉ុន្តែតាមការពិតទៅ បញ្ហា ពុករលួយក៏អាចកើតមានផងដែរនៅក្នុងវិស័យឯកជន។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងពីបទល្មើសពុករលួយនៅក្នុងសណ្ឋាននេះចំនួន ៥ បទល្មើស ពោលគឺ ៖ បទស៊ីសំណូកនៃនិយោជិត - បទសូកប៉ាន់ដល់និយោជិត បទស៊ីសំណូករបស់អភិបាល - បទដេញថ្លៃមិនត្រឹមត្រូវ - និងការសម្អាតប្រាក់។

##### ក. បទស៊ីសំណូកនៃនិយោជិត និង បទសូកប៉ាន់ដល់និយោជិត

បទស៊ីសំណូកនៃនិយោជិត គឺជាអំពើប្រព្រឹត្តដោយនិយោជិតដែលសុំ ឬយល់ព្រមទទួល អំណោយជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយ ដើម្បីបំពេញ ឬមិនបំពេញកិច្ចណាមួយ នៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹង និងគ្មានការយល់ព្រមពីនិយោជកទេ។ អំពើបែបនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី១លានរៀល ទៅ ៤លានរៀល[16]។ ធាតុផ្សំនៃបទល្មើសនេះរួមមាន ៖

- ✓ និយោជិតសុំ ឬ យល់ព្រមទទួលអំណោយជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយ។ យោងតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ពាក្យ "អត្ថប្រយោជន៍។ សំដៅលើ អំណោយអ្វីមួយ កម្ចី តម្លៃឈ្នួល រង្វាន់ ឬកម្រៃជើងសាដែលមិនមាន ការអនុញ្ញាតដោយច្បាប់ជាធរមាន ជាទឹកប្រាក់ ឬជាវត្ថុមានតម្លៃ ឬជាទ្រព្យ សម្បត្តិប្រភេទអ្វីមួយ ការងារ តំណែង មុខងារ កិច្ចព្រមព្រៀង ឬកិច្ចសន្យាអ្វីមួយ ការបង់ប្រាក់ ការលើកលែងការលុបចោល ការលុបបំបាត់នូវប្រាក់កម្ចីអ្វីមួយ កាតព្វកិច្ច ឬបំណុលដទៃទៀត ទោះជាទាំងមូលក្តី ឬ ដោយផ្នែកក្តី សេវាកម្មឯទៀត ឬការផ្តល់ជាគុណប្រយោជន៍រួមទាំងកិច្ចការពារមិនឲ្យមានការដាក់ ទណ្ឌកម្ម ដែលលេចចេញពីអំពើ

[15] មាត្រា ៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/០០៥ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០។

[16] មាត្រា ២៧៨ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ឬដំណើរការនៃការដាក់ទណ្ឌកម្មរដ្ឋប្បវេណី ឬ ព្រហ្មទណ្ឌ ទោះបីទណ្ឌកម្មនេះ ត្រូវបានកំណត់ ឬពុំទាន់ត្រូវបានកំណត់ក៏ដោយ ការអនុវត្ត ឬការរារាំងមិនឲ្យអនុវត្តនូវសិទ្ធិ ឬអំណាច ឬភារកិច្ចអ្វីមួយ ការស្នើជូន ឬការសន្យាជូន ទោះបីមានលក្ខខណ្ឌ ឬគ្មានលក្ខខណ្ឌក្ដីនូវអត្ថប្រយោជន៍ដូចមានចែងខាងដើម[17]។

- ✓ គោលដៅ គឺដើម្បីបំពេញ ឬមិនបំពេញកិច្ចណាមួយនៃមុខងាររបស់ខ្លួន
- ✓ និយោជកមិនបានដឹង និងមិនមានការព្រមព្រៀងពីនិយោជក

***ឧទាហរណ៍*** ៖ និយោជិតម្នាក់ត្រូវបានថៅកែចាត់តាំងឲ្យធ្វើជាអ្នកសម្ភាស ដាក់ពិន្ទុដើម្បីជ្រើសរើសបេក្ខជនដែលដាក់ពាក្យសុំចូលបម្រើការងារក្នុងក្រុមហ៊ុន។ និយោជិតម្នាក់នេះបាន ទទួលប្រាក់ចំនួន ១០០ ដុល្លារអាមេរិក ពីបេក្ខជនម្នាក់ ដើម្បីផ្ដល់ពិន្ទុល្អសម្រាប់ការសម្ភាសខាងលើនេះ។ អំពើនេះគឺជាការស៊ីសំណូករបស់និយោជិត។

ស្របជាមួយនឹងការផ្តន្ទាទោសការស៊ីសំណូក ការសូកប៉ាន់[18]ក៏ត្រូវផ្តន្ទាទោសជាបទល្មើសដែរ។ ដូច្នេះ បេក្ខជនខាងលើដែលបានសូកប៉ាន់ដល់និយោជិតដើម្បីផ្ដល់ពិន្ទុឲ្យខ្លួនបានល្អ។

**ខ. បទស៊ីសំណូករបស់អភិបាល**

យោងតាមខ្លឹមសារនៃមាត្រា ២៨០ កថាខណ្ឌទី ១ នៃក្រមព្រហ្មទណ្ឌបានចែងថា ៖ "បើបុគ្គលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និងទី ២ នៃមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ និង អធិការបានទទួលផលប្រយោជន៍ជាទ្រព្យសម្បត្តិ ឬ បានទាមទារឬបានសន្យាទទួលផលប្រយោជន៍នោះ ដោយបានទទួលការពឹងពាក់ខុសច្បាប់ បុគ្គលនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ"។

ផ្អែកតាមបទបញ្ញត្តិខាងលើ ជាតុផ្សំនៃបទល្មើសនេះរួមមានដូចតទៅ ៖

- ✓ ប្រធាននៃបទល្មើសគឺ ៖
  - ○ អភិបាល[19]។

---

[17] មាត្រា ៤ ចំណុចទី ៩ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/០០៨ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០។

[18] មាត្រា ២៧៩ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។ អត្ថប្រយោជន៍អ្វីមួយដល់និយោជិត ដើម្បីឲ្យបំពេញ ឬមិនបំពេញកិច្ចអ្វីមួយនៃមុខងាររបស់ខ្លួន ដោយនិយោជកមិនបានដឹង និងគ្មានការព្រមព្រៀងពីនិយោជកទេនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៤លានរៀល"។

[19] អភិបាល គឺជាអង្គភាពមួយដែលអនុវត្តកិច្ចការរបស់នីតិបុគ្គល និងជាអ្នកតំណាងឲ្យនីតិបុគ្គល (មាត្រា ៥៦ និង មាត្រា ៥៨ នៃក្រមរដ្ឋប្បវេណី)។

- អ្នកត្រួតពិនិត្យ[20]របស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលមូលនិធិ[21]
- បុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឲ្យធ្វើជំនួសនូវកិច្ចការទាំងនេះ
- និយោជិតដែលទទួលអាណត្តិពីនីតិបុគ្គល
- អ្នកជម្រះបញ្ជីរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលមូលនិធិ
- បុគ្គលដែលត្រូវបានតុលាការជ្រើសតាំង ឲ្យធ្វើជំនួសនូវកិច្ចការរបស់អ្នកជម្រះបញ្ជីខាងលើ
- អធិការ
  - ✓ ប្រធាននៃបទល្មើសបានទទួលផលប្រយោជន៍ ឬបានទាមទារ ឬសន្យាទទួលបាន
  - ✓ ដោយបានទទួលការពឹងពាក់ខុសច្បាប់។

ទន្ទឹមនឹងនេះដែរ បុគ្គលដែលផ្តល់ផលប្រយោជន៍ ឬបានស្នើសុំផ្តល់ ឬសន្យាផ្តល់ ផលប្រយោជន៍ ក៏ត្រូវទទួលការផ្តន្ទាទោសដូចគ្នាផងដែរ[22]។ និយាយម្យ៉ាងវិញទៀតថា អ្នកស៊ីសំណូក និង អ្នកសូកប៉ាន់ ត្រូវមានទោសដូចគ្នា។

**គ. បទដេញថ្លៃមិនត្រឹមត្រូវ**

មាត្រា ៣៨៧ នៃក្រមព្រហ្មទណ្ឌបានចែងថា ៖ "អំពើប្រព្រឹត្តនៅក្នុងការលក់ជាសាធារណៈតាមការដេញថ្លៃ ដើម្បីកម្ចាត់អ្នកដេញថ្លៃ ឬធ្វើឲ្យខូចការដេញថ្លៃដោយអំណោយ ការសន្យា ការព្រមព្រៀង ឬតាមគ្រប់មធ្យោបាយទុច្ចរិតដទៃទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៤លានរៀល"។ ដូច្នេះ ដើម្បីកំណត់ថាជាបទដេញថ្លៃមិនត្រឹមត្រូវ ត្រូវរួមមានធាតុផ្សំដូចតទៅ ៖

- ✓ អំពើកម្ចាត់អ្នកដេញថ្លៃ តាមរយៈអំណោយ ការសន្យា ការព្រមព្រៀង ឬមធ្យោបាយទុច្ចរិតដទៃទៀត។
- ✓ អំពើនេះបានធ្វើឲ្យខូចការដេញថ្លៃ។
- ✓ ការដេញថ្លៃនៅក្នុងការលក់ជាសាធារណៈ។

***ឧទាហរណ៍៖*** រដ្ឋបាលព្រៃឈើបានប្រកាសឲ្យមានការចូលរួមដេញថ្លៃទិញឈើដែលរឹបអូសបាន។ ជីវ៉ា និង សុគន្ធ បានព្រមព្រៀងគ្នាថា ជីវ៉ា នឹងចូលរួមដេញថ្លៃក្នុងតម្លៃ X ហើយសុគន្ធ នឹងចូលរួមដេញថ្លៃក្នុងតម្លៃ

[20] នីតិបុគ្គលត្រូវមានអ្នកត្រួតពិនិត្យម្នាក់ ឬច្រើននាក់។ ប៉ុន្តែនីតិបុគ្គលសាជីវកម្មគ្មានកម្រិត អាចមិនមានអ្នកត្រួតពិនិត្យ។ អ្នកត្រួតពិនិត្យត្រូវបានជ្រើសតាំងតាមការកំណត់នៃលក្ខន្តិកៈ ឬដោយសេចក្តីសម្រេចនៃមហាសន្និបាតសមាជិក ឬ ក្រុមប្រឹក្សាភិបាល (៦២ នៃក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧)។

[21] នីតិបុគ្គលសាជីវកម្ម គឺជាក្រុមដែលមានសមាជិក ហើយត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចដោយ ឯករាជ្យ។ សិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ (មាត្រា ៤៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧។

[22] មាត្រា ២៨០ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

Yដែលជាតម្លៃទាបជាងតម្លៃ X។ តាមវិធីយ៉ាងដូច្នេះ ជីវ៉ា ប្រាកដជាទទួលបានជោគជ័យនៅក្នុងការដេញថ្លៃ ហើយឧបមាថា អ្នកដែលចូលរួមដេញថ្លៃគឺមាន តែអ្នកទាំងពីរប៉ុណ្ណោះ។ ជីវ៉ា ដែលធ្វើជាចូលរួមដេញថ្លៃយ៉ាងដូច្នេះ នឹងទទួលបានប្រាក់កម្រៃចំនួន ២ ម៉ឺនដុល្លារពី សុគន្ធ តាមការព្រមព្រៀងខាងលើ។ អំពើរបស់អ្នកទាំងពីរ បានធ្វើឲ្យខូចការដេញថ្លៃ ត្រង់ថា ប្រសិនបើមិនមានការព្រមព្រៀងសម្ងាត់បែបនេះ ការដេញថ្លៃប្រកួតប្រជែង នឹងនាំឲ្យតម្លៃឈើកើនជាក់ជាមិនខាន។ ជីវ៉ា និង សុគន្ធ បានប្រព្រឹត្តបទដេញថ្លៃមិនត្រឹមត្រូវ។

**ឃ. ការសម្អាតប្រាក់**

ការសម្អាតប្រាក់ គឺជាអំពើផ្តល់ឲ្យតាមគ្រប់មធ្យោបាយនូវយុត្តិកម្ម[23] កុហកដើម្បីលាក់បំបាំង អត្ថប្រយោជន៍ផ្ទាល់ ឬប្រយោលនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម[24]។ ត្រូវចាត់ជាការសម្អាតប្រាក់ ផងដែរ អំពើជួយដល់ប្រតិបត្តិការនៃការបណ្តាក់ទុន ការលាក់បំបាំង ឬការផ្លាស់ប្តូរផលផ្ទាល់ ឬប្រយោលនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម។ យោងតាមមាត្រា ៤០៥ នៃក្រមព្រហ្មទណ្ឌ ការសម្អាតប្រាក់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល រហូតស្មើនឹងតម្លៃមូលនិធិ ឬតម្លៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសម្អាតប្រាក់។

***ឧទាហរណ៍*** ៖ នីតា បើកភោជនីយដ្ឋានមួយកន្លែងនៅរាជធានីភ្នំពេញ។ មុខរបររបស់គាត់មិនសូវទទួលបានប្រាក់កម្រៃ សម្រាប់ដំណើរការអាជីវកម្មរបស់គាត់ឡើយ។ ថ្ងៃមួយ បងប្រុសជីដូនមួយរបស់គាត់បានស្នើសុំ នីតា ឲ្យជួយធ្វើការអះអាងថា គាត់ (នីតា) ទទួលបាន ប្រាក់កម្រៃចំនួន ១០ ម៉ឺនដុល្លារ សម្រាប់ការធ្វើអាជីវកម្ម ភោជនីយដ្ឋានរបស់គាត់មួយឆ្នាំកន្លង មក ហើយបានធ្វើការបែងចែកប្រាក់ចំណេញរវាង នីតា និង រូបគាត់បាន ប្រាក់ម្នាក់ ៥ ម៉ឺន ដុល្លារ។ តាមរយៈអំពើនេះ បងប្រុសជីដូនរបស់ នីតា អាចអះអាងដោយស្របច្បាប់ថា ប្រាក់ ៥ ម៉ឺនដុល្លារ ដែលគាត់មាន គឺទទួលបានពីប្រាក់ចំណេញនៅក្នុងភោជនីយដ្ឋានជាមួយនឹង នីតា។ អំពើរបស់ បញ្ញា ដែលធ្វើបែបនេះ គឺជាការសម្អាតប្រាក់។

**២.២.១.២. បទល្មើសពុករលួយដែលធ្វើឲ្យប៉ះពាល់ដល់វិស័យយុត្តិធម៌**

បទល្មើសពុករលួយដែលអាចចាត់ទុកថា បានធ្វើឲ្យប៉ះពាល់ដល់វិស័យយុត្តិធម៌រួមមាន ចំនួន ៨ ដូចខាងក្រោមនេះ។

**ក. បទស៊ីសំណូកប្រព្រឹត្តដោយចៅក្រម និងបទសូកប៉ាន់ចំពោះចៅក្រម**

ការស៊ីសំណូកប្រព្រឹត្តដោយចៅក្រម សំដៅទៅលើអំពើរបស់ចៅក្រមដែលទទូចសុំ ឬយល់ព្រម ដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោល ទទួលអំណោយជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ

---

[23] យុត្តិកម្មមានន័យថា អំពើដ៏គួរអំពើ ឬការដែលត្រឹមត្រូវ មូលហេតុ ឬសេចក្តីដោះសារត្រឹមត្រូវ និងពេញច្បាប់ (សទ្ទានុក្រមពាក្យច្បាប់ប្រើប្រាស់នៅក្នុងសៀវភៅនីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ឆ្នាំ ២០១២)។

[24] មាត្រា ៤០៤ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ដើម្បីបំពេញកិច្ចនៅក្នុងមុខងាររបស់ខ្លួន ឬមិនបំពេញកិច្ចនៅក្នុងមុខងាររបស់ខ្លួន[25]។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ។ គួរគប្បីបញ្ជាក់ថា ពាក្យ "ចៅក្រម" នៅក្នុងន័យនៃមាត្រា ៥១៧ នៃក្រមព្រហ្មទណ្ឌ គឺសំដៅទៅលើចៅក្រមខាងតុលាការ និង ចៅក្រមខាងអយ្យការផងដែរ។ ចៅក្រមខាងតុលាការរួមមានចៅក្រមស៊ើបសួរនិងចៅក្រមអាសនៈ ចំណែកឯចៅក្រមខាងអយ្យការសំដៅទៅលើព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង។ មិនត្រឹមតែប៉ុណ្ណោះ ពាក្យ "ចៅក្រម" ក៏ផ្តោតទៅលើចៅក្រមដែលធ្វើការនៅសាលាជម្រះក្តីជាន់ខ្ពស់ផងដែរ។ ដូចនេះ ដើម្បីបង្កើតទៅជាបទល្មើស តាមន័យនៃមាត្រា ៥១៧ នៃក្រមព្រហ្មទណ្ឌត្រូវមានធាតុផ្សំដូចតទៅ ៖

- ✓ ប្រធាននៃបទល្មើស ៖ ចៅក្រម
- ✓ ប្រធាននៃបទល្មើសទទូចសុំ ឬយល់ព្រមទទួលដោយគ្មានសិទ្ធិនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ
- ✓ ជាការតបស្នងទៅនឹងផលប្រយោជន៍ខាងលើនេះ ប្រធាននៃបទល្មើសនឹងបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន។

មិនខុសប្លែកពីបទស៊ីសំណូកផ្សេងទៀតទេ អ្នកសូកប៉ាន់ចៅក្រមក៏ត្រូវមានទោសដែរ ពោលគឺត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ[26]។

### ខ. បទស៊ីសំណូករបស់សាក្សី ដើម្បីធ្វើសក្ខីកម្មក្លែងក្លាយ និងបទសូកប៉ាន់សាក្សី

ជាការពិត នៅក្នុងរឿងក្តីណាមួយ ពេលខ្លះសក្ខីកម្មរបស់មនុស្សម្នាក់មានឥទ្ធិពលយ៉ាងធំធេងទៅលើលទ្ធផលចុងក្រោយនៃការសម្រេចសេចក្តីរបស់ចៅក្រម។ ព្រោះតែមូលហេតុនេះហើយទើបជាញឹកញាប់ជនពាក់ព័ន្ធនៅក្នុងសំណុំរឿងណាមួយអាចប្រើប្រាស់មធ្យោបាយទុច្ចរិតផ្សេងៗ ក្នុងគោលដៅជះឥទ្ធិពលទៅលើសក្ខីកម្មរបស់សាក្សីនោះ ជាពិសេសគឺការសន្យាផ្តល់នូវផលប្រយោជន៍ណាមួយ ដើម្បីឲ្យសាក្សីធ្វើអំពើផ្តល់នូវផលប្រយោជន៍ដល់រូបខ្លួន។ ក្នុងន័យនេះ មាត្រា ៥៤៧ នៃក្រមព្រហ្មទណ្ឌចាត់ទុកជាបទស៊ីសំណូករបស់សាក្សីនូវអំពើរបស់សាក្សីណាដែលទទូចសុំ ឬយល់ព្រមទទួលយកដោយផ្ទាល់ ឬប្រយោលនូវអំណោយជំនូនការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បីមិនធ្វើជាសាក្សី ឬផ្តល់សក្ខីកម្មភូតកុហក។ អំពើបែបនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។

***ឧទាហរណ៍*** ៖ ធារី បានឃើញ ចន្ថា ចាក់សម្លាប់ ចន្ទី ដោយផ្ទាល់ភ្នែក។ នៅពេលដែលដឹង យ៉ាងដូច្នេះ ធារី បានទទូចសុំប្រាក់ចំនួន ៥០០ ដុល្លារអាមេរិកពី ចន្ថា ជាថ្នូរនឹងការមិនផ្តល់ សក្ខីកម្មអំពីបទល្មើសនេះទៅអាជ្ញាធរមានសមត្ថកិច្ច។ អំពើនេះ គឺជាបទស៊ីសំណូក។

---

[25] មាត្រា ៥១៧ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[26] មាត្រា ៥១៨ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ដូចគ្នាដែរ ប្រសិនបើ ចន្ថា បានដឹងពីរឿងនេះ ហើយយកប្រាក់ចំនួន ៥០០ ដុល្លារទៅឲ្យ ធារី ដើម្បីទិញទឹកចិត្តធារីកុំឲ្យនាងឆ្លើយថា នាងបានឃើញ ចន្ថា ជាអ្នកចាក់សម្លាប់ ចន្ទី។ អំពើរបស់ចន្ថា ដែលបានយកប្រាក់ទៅប្រគល់ឲ្យ ធារី គឺជាការសូកប៉ាន់សាក្សីដែលត្រូវផ្តន្ទា ទោសតាមបញ្ញត្តិមាត្រា ៥៤៨ នៃក្រមព្រហ្មទណ្ឌ[27]។

**គ. បទស៊ីសំណូករបស់អ្នកបកប្រែ និងបទសូកប៉ាន់អ្នកបកប្រែ**

ប្រហាក់ប្រហែលនឹងខ្លឹមសារនៃបទប្បញ្ញត្តិខាងលើដែរ ការស៊ីសំណូក និងការសូកប៉ាន់អ្នកបកប្រែក៏ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ កាលបើការស៊ីសំណូក ឬការសូកប៉ាន់ មានគោលដៅដើម្បីក្លែងខ្លឹមសារនៃភាសា ឬឯកសារដែលបកប្រែ[28]។ ជាការពិតណាស់ថា ការក្លែងខ្លឹមសារនៃភាសា និងឯកសារដែលបកប្រែអាចនឹងផ្តល់នូវភាពអនុគ្រោះ ឬមិនអនុគ្រោះដល់លទ្ធផលនៃរឿងក្តីណាមួយ។ ដូច្នេះប្រសិនបើសាក្សីដែលនិយាយភាសាបរទេសបានផ្តល់សក្ខីកម្មថា "បានឃើញ" ហើយអ្នកបកប្រែបែរជាបកប្រែថា "មិនបានឃើញ" ទៅវិញនោះ គឺ លទ្ធផលចុងក្រោយប្រាកដជាមិនដូចគ្នាទេ។

ដើម្បីបង្កើតបទល្មើសខាងលើនេះ ចារី (អ្នកបកប្រែ) ត្រូវប្រព្រឹត្តអំពើដោយចេតនា មានន័យ ថា ការបកប្រែខុសពីខ្លឹមសារពិតប្រាកដមិនមែនកើតឡើងពីការភាន់ច្រឡំនោះឡើយ ពោលគឺកើតចេញបំណងដ៏ពិតប្រាកដរបស់អ្នកបកប្រែនោះតែម្តង។

**ឃ. បទស៊ីសំណូករបស់អ្នកជំនាញ និងបទសូកប៉ាន់អ្នកជំនាញ**

ក្រៅពីអ្នកបកប្រែ និង សាក្សីសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញអាចមានឥទ្ធិពលធំធេងណាស់ទៅលើដំណោះស្រាយនៃរឿងក្តីណាមួយ។ ដូច្នេះហើយបានជាមាត្រា ៥៥៥ និង មាត្រា ៥៥៦ នៃក្រមព្រហ្មទណ្ឌធ្វើការផ្តន្ទាទោសលើការស៊ីសំណូក និងការសូកប៉ាន់អ្នកជំនាញ ជាបទឧក្រិដ្ឋ មានន័យថា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ ឆ្នាំ។ ការស៊ីសំណូក និងការសូកប៉ាន់អ្នកជំនាញមានគោលដៅដើម្បីក្លែងនៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់របស់អ្នកជំនាញនូវទិន្នន័យ ឬលទ្ធផលនៃកោសល្យវិច័យ។ ជាក់ស្តែង អ្នកជំនាញគឺជាបុគ្គលដែលមានចំណេះដឹងនៅក្នុងវិស័យបច្ចេកទេសណាមួយ។ ដូច្នេះ គ្រូពេទ្យគឺជាអ្នកជំនាញនៅក្នុងវាយតម្លៃទៅលើស្ថានភាពជំងឺ ស្ថានភាពរបួស ឬមូលហេតុនៃមរណភាពរបស់បុគ្គលណាម្នាក់។ ចំណែកឯជាងមាសគឺជាអ្នកជំនាញនៅក្នុងការវាយតម្លៃថា លោហធាតុពណ៌លឿងនេះគឺជាមាសពិតប្រាកដ ឬមិនមែន។ ព្រមជាមួយគ្នានេះ មានតែអ្នកជំនាញទេដែលអាចវាយតម្លៃ

[27] មាត្រា ៥៤៨ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ ចែងថា ៖ "ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ រាល់បុគ្គលណាដែលប្រគល់ឲ្យសាក្សីដោយផ្ទាល់ ឬ ដោយប្រយោល នូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីមិនធ្វើជាសាក្សី ឬផ្តល់សក្ខីកម្មភូតកុហក"។

[28] មាត្រា ៥៥៣ និង មាត្រា ៥៥៤ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃ ទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

បានថា តើម្សៅក្រាមពណ៌សថ្លាណាមួយនោះ គឺជាគ្រឿងញៀន ឬមិនមែនជាគ្រឿងញៀន ឬមានបរិមាណសុទ្ធចំនួនប៉ុន្មាន។ ដូច្នេះ ការវាយតម្លៃរបស់អ្នកជំនាញដែលថា ម្សៅក្រាមពណ៌សមិនមែនជាគ្រឿងញៀនទេនោះ គឺជាមូលហេតុដ៏សំខាន់មួយដែលមិនអាចឲ្យចៅក្រមធ្វើការសម្រេចផ្តន្ទាទោសជនដែលបានកាន់កាប់ម្សៅក្រាមពណ៌សនោះ តាមបទបញ្ញត្តិនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឡើយ។ ស្របជាមួយគ្នានេះ ប្រសិនបើអ្នកជំនាញបានធ្វើការវាយតម្លៃដោយក្លែងថា គ្រឿងញៀនណាមួយនោះមានបរិមាណសុទ្ធទាប នោះសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញនឹងមានឥទ្ធិពលទៅលើការកំណត់ទោសដោយចៅក្រម មានន័យថាប្រសិនបើបរិមាណសុទ្ធមានចំនួនទាបការផ្តន្ទាទោសក៏ទាបទៅតាមនោះដែរ។

**២.២.១.៣. បទល្មើសពុករលួយដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការរបស់រដ្ឋបាលសាធារណៈ**

នៅត្រង់ផ្នែកនេះ បទល្មើសពុករលួយមានចំនួន ១០ ពោលគឺ ៖

**ក. វីតិក្រម**

វីតិក្រមត្រូវបានឲ្យនិយមន័យដោយមាត្រា ៥៩២ នៃក្រមព្រហ្មទណ្ឌថាជាអំពើរបស់អ្នក រាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែរ ៖

- ✓ ទាមទារ ឬទទួលជាសិទ្ធិ ជាពន្ធ ជាអាករ នូវចំនួនប្រាក់ដែលខ្លួនបានដឹងថា មិនត្រូវបង់ ឬដែលលើសពីចំនួនដែលគេត្រូវបង់។
- ✓ យល់ព្រមក្រោមរូបភាពណាមួយ និងដោយមូលហេតុណាមួយក៏ដោយ ធ្វើការលើកលែង ឬការលោះលាចំពោះការបង់ពន្ធ ឬអាករដែលខ្លួនដឹងថាខុសច្បាប់។

បទល្មើស វីតិក្រម ត្រូវទទួលការផ្តន្ទាទោសស្រាលជាងបទស៊ីសំណូក ដោយត្រូវទទួលទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល[29]។ ខុសប្លែកពីបទ ស៊ីសំណូក ជនស៊ីសំណូកទទូចសុំ ឬយល់ព្រមទទួលនូវអំណោយពីបុគ្គលណាម្នាក់ ដែលមានសេរីភាពពេញលេញ និងស្ម័គ្រចិត្តប្រគល់អំណោយ ឬមិនប្រគល់អំណោយ រីឯជនដែល ប្រព្រឹត្តបទ វីតិក្រម វិញ គាត់ទាមទារ ឬទទួលជាសិទ្ធិ ជាពន្ធ ជាអាករ ដោយជនរងគ្រោះមិនអាច ប្រកែកថាចំនបង់ឡើយ ទោះបីជាទឹកប្រាក់នោះមិនត្រូវបង់ ឬមានចំនួនលើសពីប្រាក់ដែលត្រូវបង់ក៏ដោយ។

***ឧទាហរណ៍*** ៖ មន្ត្រីនគរបាលម្នាក់បានទាមទារយកប្រាក់ចំនួន ១០ ដុល្លារក្នុងមួយខែ ពីកន្លែងធ្វើអាជីវកម្មនៅក្នុងរង្វង់សមត្ថកិច្ចដែនដីដែលគាត់គ្រប់គ្រង ដោយមិនមានច្បាប់ណាមួយ ចែងតម្រូវឲ្យគាត់យកប្រាក់បែបនេះឡើយ។ ដូចគ្នាដែរ មន្ត្រីនគរបាលចរាចរណ៍ដែលបានទាមទារ ឲ្យអ្នកបើកបរម៉ូតូមិនគោរពភ្លើងសញ្ញា បង់ប្រាក់ផាកពិន័យលើសពីចំនួនទឹកប្រាក់ដែលកំណត់ដោយច្បាប់ គឺបានប្រព្រឹត្តបទ វីតិក្រម។

---

[29] មាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

### ខ. បទស៊ីសំណូក និងបទសូកប៉ាន់

មកដល់ត្រង់ចំណុចនេះ ឃើញថា ក្រមព្រហ្មទណ្ឌកំណត់បទល្មើស និងទណ្ឌកម្មដែលត្រូវផ្តន្ទាទោសទៅលើអំពើស៊ីសំណូក និងអំពើសូកប៉ាន់[30] ដូចករណីដែលបានពិពណ៌នាពាក់ព័ន្ធនឹង បទស៊ីសំណូកដោយចៅក្រម និងបទសូកប៉ាន់ចំពោះចៅក្រមដែរ។ អ្វីដែលខុសប្លែកគ្នានោះ គឺ ថាបទស៊ីសំណូកតាមបញ្ញត្តិនៃមាត្រា ៥៩៤ នៃក្រមព្រហ្មទណ្ឌ ត្រូវយកទៅអនុវត្តលើប្រធាននៃ បទល្មើសដែលមិនមែនជាចៅក្រម ពោលគឺប្រធាននៃបទល្មើសនៅក្នុងបទល្មើសនេះគឺ៖

- ✓ អ្នករាជការសាធារណៈ។ មាត្រា ៣៣ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌបានផ្តល់និយមន័យនៃពាក្យ "អ្នករាជការសាធារណៈ" ដូចតទៅ ៖ បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិបញ្ញត្តិ[31] ស្ថាប័ននីតិប្រតិបត្តិ[32] ឬស្ថាប័នតុលាការ[33] ដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុ របស់បុគ្គលនោះឡើយ ព្រមទាំងបុគ្គលឯទៀតដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ និងស្ថាប័នសាធារណៈដទៃទៀតដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា[34]។
- ✓ ពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត សំដៅទៅលើ សមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត[35]។

***ឧទាហរណ៍ ៖*** មន្ត្រីនគរបាលម្នាក់បានកែប្រែខ្លឹមសារនៃកំណត់ហេតុណាមួយ ដើម្បីកុំឲ្យគេ រកឃើញអត្តសញ្ញាណរបស់សហចារី[36] ព្រោះតែបានទទួលអំណោយជាប្រាក់ចំនួន ៥០០ ដុល្លារអាមេរិក ពីក្រុមគ្រួសាររបស់ជននោះ។ ដូចគ្នាដែរ ប្រសិនបើមន្ត្រីនគរបាលម្នាក់បានទទួលប្រាក់ ចំនួន ១០០០ ដុល្លារអាមេរិក ពីក្រុមគ្រួសាររបស់ជនល្មើស ជាថ្នូរទៅនឹងការមិនចាប់ខ្លួនជនល្មើស ប្រគល់ឲ្យទៅអាជ្ញាធរតុលាការ។

---

[30] មាត្រា ៥៩៤ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[31] ចំណុចនេះមិនសំដៅទៅលើតំណាងរាស្ត្រទេ។ *ឧទាហរណ៍* ៖ មន្ត្រីរាជការដែលបម្រើការនៅក្នុងរដ្ឋសភា។

[32] *ឧទាហរណ៍* ៖ ប្រធាននាយកដ្ឋាននៃក្រសួងណាមួយ។

[33] ត្រង់ចំណុចនេះ គឺមិនសំដៅទៅលើចៅក្រមទេ។ *ឧទាហរណ៍* ៖ ក្រឡាបញ្ជី ឬ មន្ត្រីគ្រប់គ្រងរដ្ឋបាលនៅសាលាដម្រះក្តី។

[34] *ឧទាហរណ៍* ៖ មន្ត្រីរាជការនៃអង្គភាពរដ្ឋាករទឹក ឬអគ្គិសនីកម្ពុជា ដែលជានីតិបុគ្គលសាធារណៈដោយឡែកពីរដ្ឋ។

[35] មាត្រា ៣៣ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[36] សហចារី សំដៅលើបុគ្គលច្រើននាក់ដែលបានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ (មាត្រា ២៦ កថាខណ្ឌទី ១ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩)។

**គ. ជំនួញឥទ្ធិពល**

តាមខ្លឹមសារនៃក្រមព្រហ្មទណ្ឌ ជំនួញឥទ្ធិពលមានពីរប្រភេទគឺជំនួញឥទ្ធិពលអកម្ម និង ជំនួញឥទ្ធិពលសកម្ម។ មាត្រា ៥៩៥ នៃក្រមព្រហ្មទណ្ឌបានចែងថា ៖ "ជំនួញឥទ្ធិពលអកម្ម គឺជាអំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលទទូចសុំ ឬយល់ព្រមទទួល ដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយ ដើម្បីទទួលបានពីស្ថាប័នរដ្ឋ ដោយសារឥទ្ធិពលពិតប្រាកដ ឬ ដោយសន្មតនូវការងារលទ្ធកម្មសាធារណៈ គ្រឿងសម្គាល់កិត្តិយស ឬសេចក្ដីសម្រេចអនុគ្រោះផ្សេងៗដទៃទៀត"។ ជំនួញឥទ្ធិពលអកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ[37]។

បើប្រៀបធៀបទៅនឹងបទស៊ីសំណូក បទជំនួញឥទ្ធិពលអកម្មមានគោលដៅដើម្បីឲ្យចារី យកឥទ្ធិពលរបស់ខ្លួនទៅប្រើប្រាស់ ក្នុងបំណងទទួលបានពីស្ថាប័នរដ្ឋនូវការងារលទ្ធកម្ម គ្រឿងសម្គាល់កិត្តិយស ឬសេចក្ដីសម្រេចអនុគ្រោះផ្សេងៗ។ ដូច្នេះ ចារីមិនមែនជាបុគ្គលដែលត្រូវសម្រេចសេចក្ដីដោយផ្ទាល់នោះទេ ប៉ុន្តែគាត់បានប្រើឥទ្ធិពលរបស់គាត់ក្នុងនាមជាអ្នករាជការ សាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីទទួលបានភាពអនុគ្រោះផ្សេងៗ ចំណែកឯការស៊ីសំណូកវិញ គឺចារីជាអ្នកសម្រេចផ្ទាល់ ហើយយល់ព្រមបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ មិនយល់ព្រមបំពេញកិច្ចនៃមុខងាររបស់ខ្លួន ជាថ្នូរទៅនឹងផលប្រយោជន៍ណាមួយ។

***ឧទាហរណ៍*** ៖ មន្ត្រីមានបុណ្យសក្តិខ្ពស់ម្នាក់បានធ្វើអន្តរាគមន៍ទៅចៅក្រមដែលកាន់ សំណុំរឿង ដើម្បីឲ្យសម្រេចសេចក្ដីឲ្យភាគី ក. បានឈ្នះក្តី ដោយសារតែគាត់បានទទួលប្រាក់កម្រៃ ពីភាគី ក.។ ដូចគ្នាដែរ មន្ត្រីរាជការមានឋានៈធំម្នាក់បានធ្វើអន្តរាគមន៍ទៅស្ថាប័នសាធារណៈដែល បានដាក់ដេញថ្លៃសាងសង់អាគារនៅក្នុងស្ថាប័ននោះ ដើម្បីឲ្យស្ថាប័ននោះប្រគល់ការងារសាងសង់ ទៅឲ្យក្រុមហ៊ុន ក. ដោយសារតែក្រុមហ៊ុន ក. បានសន្យាថានឹងលក់ផ្ទះនៅក្នុងបូរីរបស់ក្រុមហ៊ុន ក. ឲ្យទៅគាត់ក្នុងតម្លៃទាបជាងទីផ្សារចំនួនពាក់កណ្ដាល។ អំពើរបស់មន្ត្រីនោះ គឺជាបទល្មើស ព្រហ្មទណ្ឌដែលមានឈ្មោះថា ជំនួញឥទ្ធិពលអកម្ម។

ចំណែកឯបុគ្គលដែលបានប្រគល់អំណោយ ឬជំនូន ឬធ្វើការសន្យាផ្សេងៗ ដើម្បីឲ្យមន្ត្រីមានបុណ្យសក្តិធំប្រើប្រាស់ឥទ្ធិពលរបស់គាត់ គឺត្រូវមានទោសពីបទជំនួញឥទ្ធិពលសកម្ម ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦០៦ នៃក្រមព្រហ្មទណ្ឌ។

មាត្រា ៦០៦ នៃក្រមព្រហ្មទណ្ឌបានចែងថា ៖ "ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល បុគ្គលណាដោយគ្មានសិទ្ធិ ដោយផ្ទាល់ ឬដោយប្រយោល ប្រគល់អំណោយ ឬជំនូន ឬធ្វើការសន្យាជាមួយ ឬផ្តល់អត្ថប្រយោជន៍អ្វីមួយ ដល់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីទទួលបានពីស្ថាប័នរដ្ឋ ដោយសារឥទ្ធិពលពិតប្រាកដ ឬដោយសន្មតរបស់អ្នករាជការ ឬពលរដ្ឋនោះ នូវការងារលទ្ធកម្មសាធារណៈ គ្រឿងសម្គាល់កិត្តិយស ឬសេចក្ដីសម្រេចអនុគ្រោះផ្សេងទៀត"។

[37] មាត្រា ៥៩៦ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

បទល្មើសដូចដែលបានរៀបរាប់ខាងលើនេះ នឹងត្រូវកើតឡើងហើយបានសម្រេច ទោះបីជាការប្រើឥទ្ធិពលដោយអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈ មិនទទួលបានជោគជ័យតាមបំណងប្រាថ្នាក៏ដោយ។

**ឃ. ការកេងយកផលប្រយោជន៍ដោយខុសច្បាប់**

បទល្មើសនេះមានចែងនៅមាត្រា៥៩៧ នៃក្រមព្រហ្មទណ្ឌថា៖ "ការកេងយកផល ប្រយោជន៍ដោយខុសច្បាប់ គឺជាអំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋទទួល អាណត្តិសាធារណៈដោយការបោះឆ្នោត ដែលយកទទួលឬរក្សាទុកដោយផ្ទាល់ ឬដោយប្រយោលនូវផលប្រយោជន៍អ្វីមួយនៅក្នុង ៖

- ✓ សហគ្រាសណាមួយ ដែលអ្នករាជការ ឬពលរដ្ឋនោះមានភារកិច្ចរ៉ាប់រងទាំងស្រុង ឬមួយផ្នែកនូវការឃ្លាំ តាមដាន ការគ្រប់គ្រង ឬការជម្រះបញ្ជី។
- ✓ ប្រតិបត្តិការណាមួយដែលអ្នករាជការ ឬពលរដ្ឋនោះមានភារកិច្ចរ៉ាប់រងទាំងស្រុង ឬមួយផ្នែកនូវការឃ្លាំ តាមដាន ឬការទូទាត់។

ជារួមមក ធាតុផ្សំនៃបទល្មើសនេះមានដូចតទៅ ៖

- ✓ ប្រធាននៃបទល្មើស ៖ អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត។
- ✓ ចារីបានធ្វើសកម្មភាពណាមួយដែលនាំឲ្យខ្លួនទទួលបាន ឬរក្សាទុកនូវផលប្រយោជន៍ណាមួយ។
- ✓ ផលប្រយោជន៍ដែលទទួលបាននោះ គឺបានមកពីសហគ្រាស ឬប្រតិបត្តិការណាមួយដែលចារីមានភារកិច្ចរ៉ាប់រងទាំងស្រុង ឬមួយផ្នែកនូវការឃ្លាំ តាមដាន។ល"។

***ឧទាហរណ៍*** ៖ អភិបាលក្រុងម្នាក់បានផ្តល់សិទ្ធិសាងសង់អាគាររបស់ក្រុងទៅឲ្យក្រុមហ៊ុន មួយដែលគាត់ជាម្ចាស់ភាគហ៊ុនម្នាក់នៅក្នុងនោះ។ ទន្ទឹមនឹងនេះដែរ ប្រសិនបើអភិបាលក្រុងបានលក់អចលនវត្ថុរបស់ក្រុងទៅឲ្យក្រុមហ៊ុនភរិយារបស់គាត់ក៏អាចចាត់បញ្ចូលទៅក្នុងបទល្មើសនេះដែរ ពីព្រោះថាក្នុងករណីបែបនេះ គាត់ទទួលបានផលប្រយោជន៍ដោយប្រយោល។ ព្រមជាមួយគ្នានេះ ប្រសិនបើសាលាឃុំបានជួល និងបើកប្រាក់បៀវត្សឲ្យបុគ្គលិកសាលាឃុំម្នាក់ ប៉ុន្តែមេឃុំ បានឲ្យបុគ្គលិករូបនោះទៅធ្វើកិច្ចការងារផ្ទះនៅគេហដ្ឋានផ្ទាល់ខ្លួនរបស់គាត់ទៅវិញក្នុងស្ថានភាពនេះ មេឃុំបានទទួលផលប្រយោជន៍ត្រង់ថា គាត់មិនចាំបាច់ត្រូវចំណាយប្រាក់ផ្ទាល់ខ្លួន ទៅជួលមនុស្សឲ្យមកធ្វើការងារផ្ទះរបស់គាត់នោះទេ។ អំពើដូចរៀបរាប់ខាងលើគឺជាបទកេងយកផលប្រយោជន៍ដោយខុសច្បាប់។

**ខ. បទបក្ខានុគ្រោះ**

បទបក្ខានុគ្រោះ គឺជាប្រភេទមួយនៃបទល្មើសពុករលួយដែលមានចែងនៅមាត្រា ៥៥៩ នៃក្រមព្រហ្មទណ្ឌថា "បក្ខានុគ្រោះ គឺជាអំពើរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលផ្តល់ឲ្យ

ដោយខុសច្បាប់នូវអត្ថប្រយោជន៍ដល់អ្នកដទៃនៅក្នុងឱកាសនៃការធ្វើលទ្ធកម្មសាធារណៈ។ អំពើនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៤លានរៀល[38]"។ ផ្អែកតាមបទប្បញ្ញត្តិខាងលើ ធាតុផ្សំនៃបទបក្ខានុគ្រោះមានដូចតទៅ ៖

- ✓ ប្រធាននៃបទល្មើសគឺជាអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត។
- ✓ ការផ្តល់ឲ្យដោយខុសច្បាប់នូវអត្ថប្រយោជន៍ដល់អ្នកដទៃនៅក្នុងឱកាសនៃការធ្វើលទ្ធកម្មសាធារណៈ។

តាមពិតបទបក្ខានុគ្រោះកើតមានឡើង ដោយមិនតម្រូវឲ្យមានភស្តុតាងពីការទទួចសុំ ឬការយល់ព្រមទទួលនូវអំណោយ ជំនូន ការសន្យាណាមួយឡើយ។ អ្វីដែលជាធាតុផ្សំសំខាន់នៃ បទល្មើសនេះគឺជាការផ្តល់អត្ថប្រយោជន៍ឲ្យអ្នកដទៃដោយខុសច្បាប់។

***ឧទាហរណ៍*** ៖ សាកលវិទ្យាល័យមួយបានប្រគល់សិទ្ធិសាងសង់អាគាររបស់សាកលវិទ្យាល័យទៅឲ្យក្រុមហ៊ុនមួយ ដោយមិនបានដាក់ឲ្យដេញថ្លៃឡើយ។ នេះគឺជាការផ្តល់អត្ថប្រយោជន៍ឲ្យអ្នកដទៃដោយខុសច្បាប់។ នេះគឺជាបទល្មើស បក្ខានុគ្រោះ។

ជាងនេះទៅទៀត ប្រសិនបើមានភស្តុតាងពីការផ្តល់អំណោយជំនូន ការសន្យាណាមួយ ជាថ្នូរនឹងការប្រគល់ការងារលទ្ធកម្ម (ការងារសាងសង់អាគាររបស់សាកលវិទ្យាល័យ) ទៅឲ្យក្រុមហ៊ុននោះវិញ អំពើបែបនេះគឺជាបទស៊ីសំណូក តែម្តងមិនមែនជាបទបក្ខានុគ្រោះទេ។

**ច. បទបំផ្លាញដោយចេតនា និង គៃបំបាត់ដោយទុច្ចរិត**

អំពើបែបនេះមានចែងនៅក្នុងមាត្រា ៦០១ នៃក្រមព្រហ្មទណ្ឌថា ៖ "អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលគ្រប់គ្រងលិខិតបណ្ណមូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗទៀត ដោយសារមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ប្រសិនបើអ្នករាជការ ឬពលរដ្ឋនោះបំផ្លាញដោយដោយចេតនា ឬ គៃបំបាត់ដោយទុច្ចរិតនូវលិខិតបណ្ណមូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗទៀតនោះៗ"។ ជារួមមក ដើម្បីបង្កើតបានជាបទល្មើសនេះ ត្រូវមានធាតុផ្សំដូចតទៅ ៖

- ✓ ប្រធាននៃបទល្មើសគឺជាអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត។
- ✓ មានការបំផ្លាញ ការគៃបំបាត់ដោយចេតនា នូវលិខិតបណ្ណមូលនិធិ សាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗទៀត

[38] មាត្រា ៦០០ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

- ✓ ប្រធាននៃបទល្មើស មានមុខងារជាអ្នកគ្រប់គ្រងលិខិតបណ្ណមូលនិធិ សាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗទៀតនោះ
- ✓ មុនពេលកើតមានអំពើបំផ្លាញ ឬការគៃបំបាត់នោះ ប្រធាននៃបទល្មើសបាន ទទួលលិខិតបណ្ណមូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗទៀត មកគ្រប់គ្រង ដោយសារតែមុខងាររបស់ខ្លួន។

***ឧទាហរណ៍*** ៖ មន្ត្រីអត្រានុកូលដ្ឋានម្នាក់បានដុតសៀវភៅបញ្ជីសំបុត្រកំណើតដែលមាន សុពលភាពចោល ដោយសារតែចង់បំបាត់ដានរឿងអ្វីមួយ។ អំពើនេះគឺជាការបំផ្លាញដោយ ចេតនា។ ទន្ទឹមនឹងនេះដែរ មន្ត្រីរាជការដែលជាគណនេយ្យករបានទទួលយកប្រាក់មកគ្រប់គ្រង ដើម្បីផ្ទេរចូលគណនីរបស់រដ្ឋ ហើយបែរជាយកប្រាក់នោះទៅចាយវាយផ្ទាល់ខ្លួន គឺជាបទគៃបំបាត់ដោយទុច្ចរិត។

ប្រសិនបើការបំផ្លាញ ឬការគៃបំបាត់ មិនមែនធ្វើឡើងដោយបុគ្គលដែលមានភារកិច្ចជាអ្នកគ្រប់គ្រងទេនោះ អំពើនេះត្រូវផ្តន្ទាទោសតាមមាត្រា ៦០៨ នៃក្រមព្រហ្មទណ្ឌវិញហើយ បទល្មើសនេះក៏ត្រូវបានចាត់ទុកថាជាប្រភេទមួយនៃបទល្មើសពុករលួយផងដែរ។ មាត្រា ៦០៨ នៃក្រមព្រហ្មទណ្ឌបានចែងថា ៖ "អំពើបំផ្លាញ គៃបំបាត់ ឬដកយកលិខិតបណ្ណមូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងៗទៀត ដែលរក្សាទុកដោយអ្នករាជការសាធារណៈ ឬពលរដ្ឋ ទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដោយសារមុខងាររបស់ខ្លួននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល។

### ឆ. បទសម្លុតគំរាម

អំពើសម្លុតគំរាមមានចែងឲ្យផ្តន្ទាទោសនៅមាត្រា ៦០៧ នៃក្រមព្រហ្មទណ្ឌថា ៖ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល អំពើសម្លុតគំរាមដែលអនុវត្តទៅលើអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដើម្បី ៖

- ✓ ឲ្យអ្នករាជការ ឬពលរដ្ឋនោះបំពេញកិច្ចនៃមុខងាររបស់ខ្លួន។
- ✓ កុំឲ្យអ្នករាជការ ឬពលរដ្ឋនោះបំពេញកិច្ចនៃមុខងាររបស់ខ្លួន
- ✓ ឲ្យអ្នករាជការឬពលរដ្ឋនោះរំលោភឥទ្ធិពលរបស់ខ្លួនដែលមានពិតប្រាកដ ឬដោយសន្មត ដើម្បីនឹងទទួលបានពីរាជការនូវការងារលទ្ធកម្មសាធារណៈគ្រឿងសម្គាល់កិត្តិយស ឬសេចក្តីសម្រេចអនុគ្រោះផ្សេងទៀត។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាពុំបានរៀបរាប់ពីមធ្យោបាយ និងប្រភេទនៃការសម្លុតគំរាមដែលជាកម្មវត្ថុនៃបទល្មើសនេះទេ ហេតុនេះ ការគំរាមតាមគ្រប់រូបភាពទាំងអស់គឺជាធាតុផ្សំនៃបទល្មើសនេះ ដូចជាការសម្លុតគំរាមថានឹងសម្លាប់ ថានឹងប្រើហិង្សាថានឹងដុតបំផ្លាញទ្រព្យសម្បត្តិជាដើម។ នៅក្នុងករណីនេះ អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិ សាធារណៈដោយការបោះឆ្នោត មិនមែនជាប្រធាននៃបទល្មើសទេ ប៉ុន្តែគឺជាជនរងគ្រោះនៃបទល្មើសទៅវិញ។ ជាងនេះទៅទៀត ការសម្លុតគំរាមត្រូវមានគោលដៅពិសេស គឺដើម្បីឲ្យ

ជនរងគ្រោះបំពេញឬមិនបំពេញកិច្ចណាមួយនៃមុខងាររបស់ខ្លួន ឬប្រើឥទ្ធិពលរបស់ខ្លួន ដើម្បីទទួលបានពីរាជការនូវការងារលទ្ធកម្មសាធារណៈ គ្រឿងសម្គាល់កិត្តិយស ឬសេចក្តីសម្រេចអនុគ្រោះផ្សេងទៀត។ ក្នុងន័យនេះ ប្រសិនបើចារីបានគំរាមជនរងគ្រោះ ដោយសារតែមានគោលបំណងផ្សេងក្រៅពីគោលដៅពិសេសដូចបានរៀបរាប់ខាងលើអំពើរបស់ចារីមិនមែនជាបទសម្លុតគំរាមតាមខ្លឹមសារនៃមាត្រាខាងលើនោះទេ ប៉ុន្តែគឺជាបទគំរាមកំហែង ដែលមានបញ្ញត្តឲ្យផ្តន្ទាទោសតាមមាត្រាផ្សេងទៀត[39]។

***ឧទាហរណ៍*** ៖ បុរសម្នាក់បានគំរាមចៅក្រមឲ្យចេញសេចក្តីសម្រេចឲ្យខ្លួនឈ្នះក្តី។

**២.២.១.៤. បទល្មើសពុករលួយដែលធ្វើឲ្យប៉ះពាល់ដល់ទំនុកចិត្តសាធារណៈ**

បទល្មើសពុករលួយដែលស្ថិតនៅក្នុងផ្នែកនេះមានចំនួន ៤ បទល្មើស ក្នុងនោះរួមមាន ៖

**ក. បទស៊ីសំណូក និងបទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត**

យោងតាមមាត្រា ៦៣៧ នៃក្រមព្រហ្មទណ្ឌបានចែងថា ៖ "ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល អំពើរបស់បុគ្គលដែលប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនដោយទទូចសុំ ឬយល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពីការណភាព[40] ដែលតាមជាក់ស្តែង មិនមែនជាការពិត"។

តាមខ្លឹមសារនៃមាត្រាខាងលើឃើញថា ចារីនៃបទល្មើសនេះមិនមែនជាអ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតឡើយ ពីព្រោះថា ក្រមព្រហ្មទណ្ឌ បានប្រើពាក្យ "អ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់" មិនបានប្រើពាក្យថា "អ្នករាជការ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈ" ឡើយ។ ដូច្នេះ អ្នកមាននីតិសម្បទានោះអាចជាមេធាវីសាលារៀនឯកជនជាដើម។

***ឧទាហរណ៍*** ៖ ក្រោយពីបានទទួលប្រាក់ចំនួន ១០០០ ដុល្លារអាមេរិកពីឈ្មោះ ក. នាយកសាលារៀនឯកជនមួយកន្លែងបានធ្វើលិខិតបញ្ជាក់ថា ឈ្មោះ ក. ពិតជាបានមករៀននៅថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៣ ដែលតាមការពិតទៅ ឈ្មោះ ក. មិនបានមករៀនឡើយនៅថ្ងៃនោះ។

ក្នុងសម្មតិកម្មខាងលើ ឈ្មោះ ក. ដែលបានផ្តល់ប្រាក់ចំនួន ១០០០ ដុល្លារអាមេរិក ដើម្បីឲ្យនាយកសាលាធ្វើលិខិតបញ្ជាក់យ៉ាងដូច្នេះ ត្រូវមានទោសពីបទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទា ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត ដែលមានចែងឲ្យផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំទៅ ៣ឆ្នាំ និង ពិន័យជាប្រាក់ពី ២លានរៀល ទៅ ៦លានរៀល[41]។

[39] *ឧទាហរណ៍* ៖ មាត្រា ២៣១ ដល់មាត្រា ២៣៤ និងមាត្រា ៤២ មាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌជាដើម។

[40] ការណភាព មានន័យថា ស្ថានភាពនៃអ្វីមួយ។

[41] មាត្រា ៦៣៨ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

**ខ. បទស៊ីសំណូក និងបទសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត**

ខុសប្លែកពីបទបញ្ញត្តិខាងលើបន្តិច មាត្រា ៦៣៩ នៃក្រមព្រហ្មទណ្ឌផ្តោតជាពិសេស ទៅលើការស៊ីសំណូកដោយសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ។ មាត្រានេះចែងថា ៖ "ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល អំពើរបស់គ្រូពេទ្យ ឬបុគ្គលដែលជាសមាជិក នៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដែលទទូចសុំ ឬយល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្រ រៀបរាប់ពីមរណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត"។

ទន្ទឹមនឹងនេះដែរ ការសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើ លិខិតបញ្ជាក់មិនពិតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លាន រៀល ទៅ ៦លានរៀល[42]។

***ឧទាហរណ៍*** ៖ ដើម្បីអាចចូលទៅធ្វើការនៅក្នុងក្រុមហ៊ុនមួយ ឈ្មោះ ក. បានយកប្រាក់ចំនួន ១លានរៀលទៅឲ្យគ្រូពេទ្យម្នាក់ ដើម្បីធ្វើលិខិតបញ្ជាក់ថា គាត់មិនមានជំងឺទេ ប៉ុន្តែតាមការពិតជាក់ស្តែង ឈ្មោះ ក. មានជំងឺជាប់ខ្លួន ដែលជាធម្មតា ប្រសិនបើខាងក្រុមហ៊ុនដឹង គេនឹងមិនទទួលយក ទៅធ្វើការនៅក្នុងក្រុមហ៊ុនឡើយ។

នៅក្នុងករណីខាងលើនេះ ឈ្មោះ ក. បានប្រព្រឹត្តអំពើសូកប៉ាន់ ចំណែកឯគ្រូពេទ្យដែលបានចេញលិខិតបញ្ជាក់ដូចខាងលើនេះ ត្រូវមានទោសពីបទស៊ីសំណូក។

**២.២.២. បទល្មើសពុករលួយ តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ**

បទល្មើសពុករលួយដែលមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ មានចំនួន ១០ បន្ថែមពីលើបទល្មើសពុករលួយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ។

**២.២.២.១. បទល្មើសពាក់ព័ន្ធនឹងការប្រកាសទ្រព្យសម្បត្តិ**

ជាក់ស្តែង តាមបទបញ្ញត្តិនៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយមិនមែនមានតួនាទីគ្រាន់តែជាអ្នកបង្ក្រាបអំពើពុករលួយតែប៉ុណ្ណោះទេ ក៏ប៉ុន្តែនៅមានតួនាទីផ្សេងទៀតជាច្រើន ជាពិសេស ការទប់ស្កាត់បទល្មើសពុករលួយ ដែលជាគោលដៅចម្បង បំផុតនៃការប្រឆាំងអំពើពុករលួយ។ នៅក្នុងចំណោមវិធានការជាច្រើនដែលតម្រូវដោយច្បាប់ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានតម្រូវឲ្យបុគ្គលមួយចំនួនធ្វើការប្រកាសទ្រព្យសម្បត្តិ និង បំណុល។ ស្របជាមួយនឹងកាតព្វកិច្ចនេះ ក៏អាចនឹងបទល្មើសមួយចំនួនដែលមានការពាក់ព័ន្ធផងដែរ។

[42] មាត្រា ៦៤០ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

### ក. បទមានទ្រព្យសម្បត្តិដោយខុសច្បាប់

មាត្រា ៣៦ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានចែងថា ៖ "ការមានទ្រព្យសម្បត្តិ ដោយខុសច្បាប់ គឺជាកំណើនទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលបុគ្គលនោះមិនអាចផ្តល់ការពន្យល់សមហេតុសមផល នូវការកើនឡើងនៃទ្រព្យសម្បត្តិនេះ ដោយប្រៀបធៀបនឹងចំណូលស្របច្បាប់របស់ខ្លួន"។

ប្រធាននៃបទល្មើសនេះ គឺបុគ្គលដែលបានធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុល ដូចបានចែងនៅក្នុងមាត្រា ១៧ និងមាត្រា ១៩ នៃច្បាប់សីពីការប្រឆាំងអំពើពុករលួយ។ បុគ្គលទាំង នោះរួមមានដូចតទៅ ៖

- ✓ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងសមាជិករាជរដ្ឋាភិបាល។
- ✓ មន្ត្រីសាធារណៈដែលមានអាណត្តិជ្រើសតាំង។
- ✓ សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធាន អនុប្រធាន និងមន្ត្រីទាំងអស់នៃអង្គភាពប្រឆាំងអំពើពុករលួយ។
- ✓ មន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និង អ្នករាជការសាធារណៈផ្សេងទៀតដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ។
- ✓ មន្ត្រីផ្សេងទៀតដែលតែងតាំងដោយប្រកាស ហើយត្រូវបានកំណត់ឲ្យប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមបញ្ជីដែលរៀបចំឡើងដោយអង្គភាពប្រឆាំងអំពើពុករលួយ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ។
- ✓ ចៅក្រមអាសនៈ ចៅក្រមអយ្យការ សារការី ក្រឡាបញ្ជី និង អាជ្ញាសាលា។
- ✓ ថ្នាក់ដឹកនាំនៃសង្គមស៊ីវិល។

បន្ថែមពីលើនេះទៀត មាត្រា ១៩ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយតម្រូវឲ្យជនដែលមានការពាក់ព័ន្ធនឹងអំពើពុករលួយ ធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុលក្រោយពីត្រូវបានស៊ើបអង្កេត និងក្រោយពីបានទទួលសេចក្តីសម្រេចពីអង្គភាពប្រឆាំងអំពើពុករលួយ។

ដូច្នេះ ការមិនអាចពន្យល់ដោយសមហេតុផលនូវកំណើនទ្រព្យសម្បត្តិ នឹងត្រូវទទួលរងការរឹបអូសទ្រព្យសម្បត្តិដែលពុំអាចពន្យល់បានទាំងអស់ទុកជាសម្បត្តិរដ្ឋ។

### ខ. បទមិនប្រកាសទ្រព្យសម្បត្តិ និងបំណុល

បទល្មើសនេះមានចែងនៅមាត្រា ៣៨ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយថា ៖ ជនណា ដែលមិនបានប្រកាសទ្រព្យសម្បត្តិ និងបំណុល ឬបានប្រកាសមិនត្រឹមត្រូវនូវទ្រព្យសម្បត្តិរបស់ខ្លួន ទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ១៧ មាត្រា ១៨ និង មាត្រា ១៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ២លានរៀល ហើយត្រូវបានបង្ខំឲ្យធ្វើការប្រកាសទ្រព្យសម្បត្តិជូនអង្គភាពប្រឆាំងអំពើពុករលួយ។ ក្នុងករណីរឹងរូសមិនព្រមប្រកាសទ្រព្យសម្បត្តិទៀតត្រូវផ្តន្ទាទោសទ្វេដងៗ។

អនុលោមតាមបទប្បញ្ញត្តិខាងលើនេះ ធាតុផ្សំនៃបទល្មើសខាងលើរួមមាន ៖

- ✓ ប្រធាននៃបទល្មើសគឺជាបុគ្គលដែលមានចែងនៅមាត្រា ១៧ និង មាត្រា ១៩ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។
- ✓ មិនបានប្រកាសទ្រព្យសម្បត្តិ និងបំណុល ឬបានប្រកាសមិនត្រឹមត្រូវ។
- ✓ សម្រាប់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល ចាំបាច់ត្រូវមានការរំលឹកជាលាយលក្ខណ៍អក្សរពីសំណាក់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយជាមុនសិន។

### ២.២.២.២. បទល្មើសពាក់ព័ន្ធនឹងដំណើរការនីតិវិធីទាក់ទងនឹងបទល្មើសពុករលួយ

ដំណើរការនៃនីតិវិធីទាក់ទងនឹងបទល្មើសពុករលួយអាចនឹងត្រូវរាំងស្ទះ ឬមានឧបសគ្គដោយសារមូលហេតុផ្សេងៗ។ ដូច្នេះ ដើម្បីបង្ការនូវបញ្ហាមួយចំនួន បន្ថែមពីលើបទល្មើសដែលមានចែងនៅក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានកំណត់នូវបទល្មើសចំនួន៣ ពោលគឺ ៖

#### ក. បទទម្លាយការសម្ងាត់នៃប្រភពព័ត៌មានស្តីពីអំពើពុករលួយ

មាត្រា ៣៩ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានចែងថា ៖ "ជនណាដែលធ្វើឲ្យធ្លាយការសម្ងាត់នៃប្រភពព័ត៌មានស្តីពីអំពើពុករលួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ"។

#### ខ. បទរារាំង និងជ្រៀតជ្រែកដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ

ដូចគ្នាដែរ មាត្រា ៤០ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានដាក់ទោសដល់ការរារាំង និងការជ្រៀតជ្រែកនានាដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ ដោយតម្រូវឲ្យផ្តន្ទាទោស ដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល។ អំពើរារាំង ឬជ្រៀតជ្រែកនេះសំដៅទៅលើការសម្លុតគំរាមកំហែង និងសកម្មភាពផ្សេងៗទៀតដែលមានគោលដៅរារាំង ឬជ្រៀតជ្រែកដល់ការបំពេញមុខងាររបស់មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ។

យោងតាមខ្លឹមសារនៃមាត្រា ៤០ នៃច្បាប់ ប្រធាននៃបទល្មើសនេះសំដៅទៅលើអ្នករាជការ សាធារណៈ យោធិន នគរបាលជាតិ ពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត មន្ត្រីសង្គមស៊ីវិល មន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ។

ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានផ្តល់និយមន័យទៅលើពាក្យ "សង្គមស៊ីវិល" ថាជា សហគមន៍ ឬក្រុមមនុស្សដែលបង្កើតឡើង ដើម្បីធ្វើសកម្មភាពក្នុងការការពារផលប្រយោជន៍លើ វិស័យសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ វិទ្យាសាស្ត្រ វប្បធម៌ និង សាសនា មានជាអាទិ៍ សមាគម អង្គការក្រៅរដ្ឋាភិបាល គណបក្សនយោបាយ[43]។ ចំណែកពាក្យ "មន្ត្រីសាធារណៈបរទេស" មានន័យថា មន្ត្រីបរទេសដែលកាន់តំណែងក្នុង

[43] មាត្រា ៤ ចំណុចទី ៨ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/ ០០៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០។

ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការ របស់ប្រទេសក្រៅ ទោះជាបានតែងតាំង ឬបោះឆ្នោតជ្រើសរើសក៏ដោយនិងជនបរទេសដែល អនុវត្តមុខងារសាធារណៈសម្រាប់ប្រទេសក្រៅណាមួយ រួមមានទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ[44]។ ម្យ៉ាងវិញទៀត មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ មានន័យថា មន្ត្រីអន្តរជាតិ ឬជនណាដែលទទួលបានការអនុញ្ញាតពីអង្គការអន្តរជាតិឲ្យបំពេញភារកិច្ច ក្នុងនាមអង្គការអន្តរជាតិនោះ[45]។

### គ. បទប្ដឹងបរិហារដោយភូតកុហក

មិនខុសប្លែកពីខ្លឹមសារនៃក្រមព្រហ្មទណ្ឌប៉ុន្មានទេ មាត្រា ៤១ នៃច្បាប់ស្ដីការប្រឆាំងអំពើ ពុករលួយ បានចែងថា ៖ "អំពើប្ដឹងបរិហារដោយភូតកុហកដល់អង្គភាពប្រឆាំងអំពើពុករលួយ ឬ តុលាការនូវអង្គហេតុ បទល្មើស ពុករលួយ កាលបើអំពើនេះនាំឲ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ពី១ខែ ទៅ ៦ខែ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ១លានរៀល"[46]។

ដូច្នេះ ការដាក់ពាក្យបណ្ដឹងចោទប្រកាន់ថាមានអំពើពុករលួយបានកើតឡើង ក៏ប៉ុន្តែតាមការពិត គឺជាការប្រឌិតតែប៉ុណ្ណោះ ហើយការប្រឌិតនេះបានធ្វើឲ្យអង្គភាពប្រឆាំងអំពើពុករលួយធ្វើការស្រាវជ្រាវដោយ ឥតប្រយោជន៍ គឺជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវរាប់បញ្ចូលថាជាបទល្មើសពុករលួយ ស្ថិតក្នុងសមត្ថកិច្ចរបស់ មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ។

### ឃ. បទបំពានលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក

មាត្រា ៤២ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយបានចែងថា ៖ "បុគ្គលណាដែលគ្មានសិទ្ធិ ធ្វើការផ្ទេរ ធ្វើអនុប្បទាន ឬធ្វើការដោះដូរនូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យកដោយរំលោភលើបទប្បញ្ញត្តិនៃមាត្រា ៣០ នៃច្បាប់នេះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ ១០លានរៀល"។

ដូច្នេះ ប្រសិនបើវត្ថុណាមួយត្រូវបានចាប់យក ត្រូវបានផ្ទេរចេញ ដោយបុគ្គលដែលគ្មានសិទ្ធិនោះនឹង ធ្វើឲ្យមានការប៉ះពាល់ដល់ភស្ដុតាង នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងអំពើពុករលួយ ដែលអាចមានផលប៉ះពាល់ យ៉ាងខ្លាំងដល់លទ្ធផលនៃរឿងក្ដី។ ដូច្នេះ អំពើបែបនេះនឹងត្រូវផ្ដន្ទាទោសជាបទល្មើសព្រហ្មទណ្ឌ។

---

[44] មាត្រា ៤ ចំណុចទី ៣ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/ ០០៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០។

[45] មាត្រា ៤ ចំណុចទី ៤ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/ ០០៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០។

[46] មាត្រា ៥២៤ នៃក្រមព្រហ្មទណ្ឌបានចែងពីបទ ប្ដឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ ដូចតទៅ ៖ "អំពើដែល ប្ដឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ ឬអាជ្ញាធររដ្ឋបាលនូវអំពើជាបទល្មើស កាលបើការប្ដឹងបរិហារនេះនាំឲ្យ ធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១ខែ ទៅ ៦ខែ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ១លានរៀល"។

### ២.២.២.៣. បទល្មើសបន្ថែម

ក្រៅពីបទល្មើសដូចបានរៀបរាប់ខាងលើ យើងឃើញមានបទល្មើសចំនួន ៥ ទៀត ដែលច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានចែងជាបន្ថែមនូវបទល្មើស ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ។

**ក. បទស៊ីសំណូក និង សូកប៉ាន់ចំពោះបុគ្គលដែលមិនមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ**

ក្នុងលក្ខណៈប្រហាក់ប្រហែលនឹងបទស៊ីសំណូកដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌដែរ បទស៊ីសំណូកដែលមានចែងនៅមាត្រា ៣៣ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ សំដៅទៅលើអំពើប្រព្រឹត្តដោយមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈដែលសុំទាមទារ ឬយល់ព្រមទទួលដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍ណាមួយដើម្បីបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្របសម្រួលដោយ មុខងាររបស់ខ្លួន ឬ ដើម្បីមិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន។

ជារួមមក មាត្រា ៣៣ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានកំណត់បន្ថែមប្រធាននៃ បទល្មើសស៊ីសំណូកដែលមិនមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ពោលគឺ មន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ[47]។

ព្រមពេលជាមួយគ្នានេះ អំពើសូកប៉ាន់ចំពោះមន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ[48] ក៏ត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌដែរ ដោយតម្រូវឲ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ[49]។

---

[47] មន្ត្រីសាធារណៈបរទេស មានន័យថា មន្ត្រីបរទេសដែលកាន់តំណែងក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការរបស់ប្រទេសក្រៅ ទោះជាបានតែងតាំង ឬបោះឆ្នោតជ្រើសរើសក៏ដោយនិងជនបរទេសដែលអនុវត្តមុខងារសាធារណៈសម្រាប់ប្រទេសក្រៅណាមួយ រួមមានទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ (មាត្រា ៤ ចំណុចទី ៣ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/០០៨ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០)។

[48] មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ មានន័យថា មន្ត្រីអន្តរជាតិ ឬជនណាដែលទទួលបានការអនុញ្ញាតពីអង្គការអន្តរជាតិឲ្យបំពេញភារកិច្ច ក្នុងនាមអង្គការអន្តរជាតិនោះ (មាត្រា ៤ ចំណុចទី ៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០)។

[49] មាត្រា ៣៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/០០៨ ចុះថ្ងៃ ទី ១៧ ខែមេសា ឆ្នាំ២០១០។

**ខ. បទល្មើសពុករលួយតូចតាច**

ទន្ទឹមនឹងនេះ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយក៏បានបង្កើតឲ្យមានប្រភេទមួយទៀតនៃ បទល្មើសពុករលួយ ដែលត្រូវបានកំណត់ថា បទល្មើសពុករលួយតូចតាច តាមន័យនៃមាត្រា ៤៣ នៃច្បាប់។ បទល្មើសពុករលួយតូចតាច សំដៅទៅលើបទល្មើសពុករលួយដែលបានបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម ៖

- ✓ បទល្មើសប្រព្រឹត្តឡើងសម្រាប់ជីវភាពប្រចាំថ្ងៃ
- ✓ បទល្មើសប្រព្រឹត្តឡើងមានលក្ខណៈតូចតាច
- ✓ បទល្មើសដែលមិនបង្កព្យសនកម្មធ្ងន់ធ្ងរដល់សង្គមជាតិ
- ✓ មានការវាយតម្លៃទទួលស្គាល់ពីអង្គភាពប្រឆាំងអំពើពុករលួយថាជាបទល្មើសពុករលួយតូចតាច។

ដូចបានកំណត់យ៉ាងច្បាស់នៅមាត្រា ៤៣ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ លក្ខខណ្ឌទាំងបួនខាងលើនេះត្រូវតែបំពេញទាំងអស់ដើម្បីកំណត់បានថាជាបទល្មើសពុករលួយតូចតាច។ ទោះបីជាមិនទាន់មានឧទាហរណ៍ជាក់ស្តែងជាក់លាក់ពីបញ្ហានេះក៏ដោយ យើងអាចគិតថាការយកប្រាក់ពីសិស្សសាលាចំនួន ១០០០ រៀល ដើម្បីទទួលបានពិន្ទុជាប់នៅក្នុងមុខវិជ្ជាណាមួយរបស់សាលារៀន គួរគប្បីចាត់ទុកថាជាបទល្មើសពុករលួយតូចតាចហើយ។

**គ. បទទទួលផលបន្តពីបទល្មើសពុករលួយ**

តាមមាត្រា ៣៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានចែងថា "អំពើទទួលផលបន្តពីបទល្មើសពុករលួយ គឺជាអំពើលាក់បំបាំង រក្សាទុក ឬ ជញ្ជូនរបស់អ្វីមួយដោយដឹងថារបស់នោះ បានមកពីបទល្មើសពុករលួយដូចមានចែងនៅក្នុងច្បាប់នេះ។ ត្រូវចាត់ទុកជាអំពើទទួលផលបន្ត ពីបទល្មើសពុករលួយផងដែរចំពោះ ៖ ១. អំពើធ្វើជាអន្តរការី ដើម្បីបញ្ជូនរបស់អ្វីមួយដោយដឹងថារបស់នោះបានមកពីបទល្មើសពុករលួយ។ ២. អំពើដែលបានទទួលប្រយោជន៍ពីផលបន្ត ពីបទល្មើសពុករលួយដោយបានដឹងហេតុការណ៍ច្បាស់លាស់។

អំពើទទួលផលបន្តពីបទល្មើសពុករលួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល។

អំពើទទួលផលបន្តពីបទល្មើសពុករលួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ កាលបើបទល្មើសនេះត្រូវបានប្រព្រឹត្តឡើង ៖ ១. ជាទម្លាប់។ ២. ដោយប្រើប្រាស់ភាពងាយស្រួល ដែលទទួលបានពីសកម្មភាពវិជ្ជាជីវៈផ្តល់ឲ្យ។ ៣. ជាក្រុមមានការចាត់តាំងៗ។

ខ្លឹមសារនៃបទបញ្ញត្តិខាងលើអំពីបទទទួលផលបន្តពីបទល្មើសពុករលួយ គឺមិនមានលក្ខណៈខុសប្លែកពីបទទទួលផលចោរកម្ម តាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌឡើយ[50] ក៏ប៉ុន្តែមាត្រា ៣៧ ខាងលើនេះអនុវត្ត

[50] មាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

តែសម្រាប់ការទទួលផលពីបទល្មើសពុករលួយប៉ុណ្ណោះ មិនយកទៅអនុវត្តសម្រាប់ការទទួលផលនៃបទល្មើសផ្សេងទៀតទេ។

***ឧទាហរណ៍*** ៖ នៅក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសមួយ រដ្ឋា ដែលជាមន្ត្រីនគរបាល បានទទួលនូវរថយន្តមួយគ្រឿងជាសំណូក ដើម្បីឲ្យ រដ្ឋា ធ្វើរបាយការណ៍ខុសពីការពិតថា រដ្ឋា មិនបានឃើញមានគ្រឿងញៀននៅលើខ្លួនប្រាណរបស់ជនល្មើសឡើយ។ នេះគឺជាបទស៊ីសំណូក។ ក៏ប៉ុន្តែ រថយន្តដែល រដ្ឋា បានទទួលគឺជារថយន្តដែលមិនមានសំបុត្រពន្ធ ហេតុដូច្នេះហើយបានជា រដ្ឋា បាននិយាយពីរឿងនេះប្រាប់មិត្តភក្តិជិតដិតរបស់គាត់ម្នាក់ឈ្មោះ បញ្ញា ដែលមានមុខរបរជាអ្នក ឌួកដេររថយន្ត ហើយបានពឹង បញ្ញា ឲ្យជួយយករថយន្តនោះទៅលក់បានប្រាក់ចំនួន ១ ម៉ឺន ដុល្លារអាមេរិក ហើយបានប្រគល់ប្រាក់ចំនួន ១០០០ ដុល្លារឲ្យទៅបញ្ញា ដែលបានជួយរូបគាត់។ ក្នុងករណីនេះ បញ្ញា បានប្រព្រឹត្តបទទទួលផលបន្តពីបទល្មើសពុករលួយ។

**ឃ. បទរំលោភអំណាច**

ការរំលោភអំណាច សំដៅទៅលើអំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋ ដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត នៅក្នុងការបំពេញមុខងាររបស់ខ្លួន ឬក្នុង ឱកាសនៃការបំពេញមុខងាររបស់ខ្លួនចាត់វិធានការរារាំងការអនុវត្តច្បាប់ ដើម្បីទទួលបានដោយខុសច្បាប់នូវអត្ថប្រយោជន៍ណាមួយ។ អំពើនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ៥ឆ្នាំ ទៅ ១០ឆ្នាំ ប្រសិនបើបទល្មើសនេះមានប្រសិទ្ធភាព[51]។

តាមការពិត ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏មានចែងពីបទល្មើសប្រហាក់ប្រហែលនឹងបទរំលោភអំណាចដូចបានចែងខាងលើនេះដែរ ដោយបានបញ្ញត្តិនៅមាត្រា ៥៨១ ក្រោមឈ្មោះបទចាត់វិធានការសំដៅរារាំងការអនុវត្តច្បាប់។ មាត្រា ៥៨៦ នៃក្រមព្រហ្មទណ្ឌបាន ចែងថា "អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬ ដោយពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោតនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ចាត់វិធានការសម្រាប់ការរារាំងការអនុវត្តច្បាប់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និង ពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ប្រសិនបើបទល្មើសនេះសម្តែងចេញជាលទ្ធផល"។ ខុសប្លែកពីបទរំលោភអំណាចតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ មាត្រា ៥៨៦ នៃក្រមព្រហ្មទណ្ឌមិនបានកំណត់គោលបំណងនៃអ្នក ប្រព្រឹត្តបទល្មើស ដើម្បីឲ្យអំពើមួយក្លាយជា បទចាត់វិធានការសំដៅរារាំងការអនុវត្ត

[51] មាត្រា ៣៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃ ទី ១៧ ខែមេសា ឆ្នាំ២០១០។

ច្បាប់ឡើយ។ ផ្ទុយទៅវិញ មាត្រា ៣៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ តម្រូវឲ្យប្រធាននៃបទល្មើសចាត់វិធានការរារាំងការអនុវត្តច្បាប់ ដើម្បីទទួលបានដោយខុសច្បាប់នូវអត្ថប្រយោជន៍ណាមួយ។

ក្រមព្រហ្មទណ្ឌ ក៏ដូចជាច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ មិនបានធ្វើការពន្យល់ជាក់លាក់ឲ្យបានច្បាស់លាស់ថាតើអ្វីទៅជាវិធានការសម្រាប់រារាំងការអនុវត្តច្បាប់។ ពាក្យ "ចាត់វិធានការសម្រាប់រារាំងការអនុវត្តច្បាប់" គឺជាពាក្យមួយដែលអាចនាំឲ្យមានការបកស្រាយច្រើនបែបច្រើនយ៉ាងណាស់។

# ជំពូកទី៣

# បុព្វសិទ្ធិពិសេសក្នុង
# កិច្ចស៊ើបអង្កេតរបស់
# មន្ត្រីនគរបាលយុត្តិធម៌
# នៃអង្គភាពប្រឆាំងអំពើពុករលួយ
# បើប្រៀបនឹងមន្ត្រីនគរបាលយុត្តិធម៌
# តាមក្រមនីតិវិធីព្រហ្មទណ្ឌ

# ជំពូកទី ៣
# បុព្វសិទ្ធិពិសេសក្នុងកិច្ចស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ បើប្រៀបនឹងមន្ត្រីនគរបាលយុត្តិធម៌តាមក្រមនីតិវិធីព្រហ្មទណ្ឌ

ក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ អង្គភាពប្រឆាំងអំពើពុករលួយមានភារកិច្ចធ្វើការត្រួតពិនិត្យបទល្មើសពុករលួយ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាងផ្សេងៗទាក់ទងនឹងបទល្មើស។ ក្នុងន័យនេះ អង្គភាពប្រឆាំងអំពើពុករលួយមានសិទ្ធិធ្វើការស៊ើបអង្កេតលើបទល្មើស ដោយប្រើប្រាស់នូវវិធានការផ្សេងៗសម្រាប់ការស្រាវជ្រាវ ដែលក្នុងនោះ អង្គភាពប្រឆាំងអំពើពុករលួយត្រូវបានផ្តល់នូវបុព្វសិទ្ធិពិសេសខ្លះៗដែលជាធម្មតាមន្ត្រីនគរបាលយុត្តិធម៌ដទៃទៀតមិនអាចធ្វើបាន។ ព្រមជាមួយគ្នានេះ អង្គភាពប្រឆាំងអំពើពុករលួយក៏ត្រូវបានផ្តល់សិទ្ធិដ៏ជាក់លាក់មួយនៅក្នុងវិស័យបត្យាប័នដែរ ហើយជាពិសេសទៅទៀតគឺសិទ្ធិទាក់ទិននឹងការបង្កកទ្រព្យសម្បត្តិ។

តាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានបែងចែករវាងការស៊ើបអង្កេតបឋម និង ការស៊ើបអង្កេតករណីជាក់ស្តែង។ ជាទូទៅ សម្រាប់ការស៊ើបអង្កេតករណីជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិធំទូលំទូលាយជាងនៅក្នុងការស៊ើបអង្កេតបឋម ដើម្បីអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើប្រតិបត្តិការរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពខ្ពស់ ប្រឈមនឹងបទល្មើសជាក់ស្តែង។ ការទទួលស្គាល់នូវសិទ្ធិពិសេសរបស់អង្គភាពប្រឆាំងអំពើពុករលួយនៅក្នុងការចាត់វិធានការស្រាវជ្រាវផ្សេងៗ បើប្រៀបទៅនឹងមន្ត្រីនគរបាលយុត្តិធម៌ផ្សេងទៀត ត្រូវបានកម្រិតត្រឹមតែនីតិវិធីមុនការឃាត់ខ្លួនជនសង្ស័យតែប៉ុណ្ណោះ។ ចំណុចនេះមានន័យថា បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្តជាដដែល ក្រោយពីមានការឃាត់ខ្លួនជនសង្ស័យរួចមក។

ដើម្បីលេចឲ្យឃើញពីភាពខុសប្លែកគ្នារវាងមន្ត្រីនគរបាលយុត្តិធម៌ នៃអង្គភាពប្រឆាំងអំពើពុករលួយ និង មន្ត្រីនគរបាលយុត្តិធម៌ផ្សេងទៀត យើងខ្ញុំនឹងមិនធ្វើការវិភាគសិក្សា ដោយបែងចែក រវាងការស៊ើបអង្កេតបឋម និង ការស៊ើបអង្កេតករណីជាក់ស្តែងឡើយ ប៉ុន្តែនឹងធ្វើការបកស្រាយ ដោយផ្អែកប្រភេទនៃកិច្ចការដែលនឹងឆ្លុះបញ្ចាំងឲ្យឃើញពីភាពខុសប្លែកគ្នារវាងអំណាចនៃមន្ត្រីនគរបាលយុត្តិធម៌តាមក្រមនីតិវិធីព្រហ្មទណ្ឌ និងអំណាចនៃមន្ត្រីនគរបាលយុត្តិធម៌របស់អង្គភាពប្រឆាំងអំពើពុករលួយ។

# ១. បុព្វសិទ្ធិពិសេសរបស់អង្គភាពប្រឆាំងអំពើពុករលួយ

ពាក់ព័ន្ធ និងការស្រាវជ្រាវផ្សេងៗក្នុងគោលដៅពិនិត្យបទល្មើស ក៏ដូចជាការស្រាវជ្រាវរក ភស្តុតាងផ្សេងៗ ក្រមនីតិវិធីព្រហ្មទណ្ឌបានតម្រូវឲ្យមានការដឹកនាំសម្របសម្រួលលើសកម្មភាព ផ្សេងៗរបស់មន្ត្រីនគរបាលយុត្តិធម៌ និយាយមួយបែបទៀតថា សិទ្ធិរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវ បានកម្រិតខ្លះៗដោយច្បាប់បានផ្តល់សិទ្ធិដឹកនាំសម្របសម្រួលទៅឲ្យអាជ្ញាធរផ្សេង។ ក៏ប៉ុន្តែជាបដិបញ្ញត្តិ អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានផ្តល់សិទ្ធិឲ្យធ្វើប្រតិបត្តិការទាំងនេះបានដោយខ្លួនឯង។

## ១.១. ការឆែកឆេរការិយាល័យមេធាវី

មាត្រា ៩១ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ៖ "មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ តែប៉ុណ្ណោះដែលអាចធ្វើ ការឆែកឆេរនេះបាននៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី"។

ផ្ទុយទៅនឹងបទប្បញ្ញត្តិខាងលើ ការបកស្រាយទៅលើអត្ថន័យនៃមាត្រា ២៥ កថាខណ្ឌទី ៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលបានយោងយ៉ាងច្បាស់ទៅលើមាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នាំឲ្យមានការសន្និដ្ឋានថា ការឆែកឆេរការិយាល័យមេធាវីអាចធ្វើបានដោយប្រធាន អង្គភាពប្រឆាំងអំពើពុករលួយ ឬតំណាងរបស់គាត់ នៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូ របស់ប្រធានគណៈមេធាវី ឬមេធាវីសាមី។

## ១.២. បញ្ជាឲ្យចូលខ្លួន

នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបាន។ បុគ្គលដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុសំដៅទៅលើបុគ្គលដែលមិនមានការសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើសទេ ប៉ុន្តែអាចដឹងព័ត៌មានផ្សេងៗពីបទល្មើស។ នៅក្នុងករណីបែបនេះ ប្រសិនបើបុគ្គលនោះរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឲ្យចូលខ្លួនបាន។

ចំណែកឯសម្រាប់ការស៊ើបអង្កេតបឋមវិញ មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬដែលអាចព័ត៌មានស្តីពីរឿងហេតុ ហើយប្រសិនបើមានការរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឲ្យចូលខ្លួនបាន។ ខុសប្លែកពីបទប្បញ្ញត្តិនៃមាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ជាឲ្យចូលខ្លួនខាងលើនេះអាចប្រើបានសម្រាប់បុគ្គលដែលអាចផ្តល់ព័ត៌មានផង និង បុគ្គលដែលជាជនសង្ស័យផងដែរ។

ផ្អែកតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដីកាបញ្ជាឲ្យចូលខ្លួនត្រូវចុះហត្ថលេខាដោយព្រះរាជអាជ្ញា ហើយតាមរយៈដីកាបញ្ជាឲ្យចូលខ្លួននេះ មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កងកម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួន។

ក៏ប៉ុន្តែសម្រាប់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ ដីកាបញ្ជាឲ្យចូលខ្លួនយោងតាមបញ្ញត្តិ នៃមាត្រា ៩៤ និងមាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចេញដោយប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ឬតំណាងរបស់គាត់ ពោលគឺ មិនមែនចេញដោយព្រះរាជអាជ្ញានោះទេ។

### ១.៣. ការស្តាប់ និងថតការឆ្លើយឆ្លងតាមទូរស័ព្ទ ឬមធ្យោបាយទូរគមនាគមន៍ផ្សេងទៀត

ដើម្បីធានាការពារសិទ្ធិសេរីភាពរបស់បុគ្គល ជាពិសេសគឺការសម្ងាត់នៃការឆ្លើយឆ្លងដែល ត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[52] ក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវថា ដាច់ខាតឲ្យមានអន្តរាគមន៍ពីសំណាក់ចៅក្រមស៊ើបសួរ ដើម្បីអាចស្តាប់ និង ថតការឆ្លើយឆ្លងតាមទូរស័ព្ទ ឬការឆ្លើយឆ្លងតាមរយៈមធ្យោបាយទូរគមនាគមន៍ផ្សេងទៀតដូចជាសារតាមទូរសារ ឬ សារតាមអិនធើណែត[53]។ ជាក់ស្តែង មាត្រា ១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការហាមឃាត់ យ៉ាងជាក់លាក់ពីបញ្ហានេះ ដោយបានចែងថា ៖ "មន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចបង្គាប់ឲ្យ ស្តាប់ និងថតសំឡេងការសន្ទនាតាមទូរស័ព្ទឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចបង្គាប់ឲ្យចាប់ និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ជាអាទិ៍ សារតាមទូរសារ ឬ សារតាមអិនធើណែត"។ ការហាមឃាត់បែបនេះមានទំនាក់ទំនងជាមួយនឹងបទបញ្ញត្តិ នៃមាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលផ្តល់សិទ្ធិដ៏ជាក់លាក់នេះសម្រាប់តែចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។

ក៏ប៉ុន្តែផ្ទុយនឹងបទបញ្ញត្តិខាងលើនៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានអនុញ្ញាតឲ្យអង្គភាពប្រឆាំងអំពើពុករលួយធ្វើប្រតិបត្តិការ ដោយវិបញ្ញត្តិទៅនឹងមាត្រា ១០៥ និងមាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌតែម្តង។ ដូច្នេះបានសេចក្តីថា អង្គភាពប្រឆាំងអំពើពុករលួយអាចតាមដានឃ្លាំមើល លបស្តាប់ លបថតសំឡេង និង ដាក់ខ្សែទូរស័ព្ទក្រោមការលបស្តាប់ និងថត ព្រមទាំងចូលទៅពិនិត្យឯកសារនានា ព្រមទាំងឯកសាររក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិកទៀតផង ដោយពុំបាច់មានការអនុញ្ញាតឬមានការបង្គាប់បញ្ជាពីចៅក្រម ឬ ព្រះរាជអាជ្ញាឡើយ។

### ១.៤. អធិបញ្ជា និងការស្នើសុំការសហការជាមួយអាជ្ញាធរសាធារណៈ

មាត្រា ២៩ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានចែងថា ៖ "ប្រធានអង្គភាពប្រឆាំង អំពើពុករលួយអាចធ្វើអធិបញ្ជាដល់អាជ្ញាធរសាធារណៈ មន្ត្រីរាជការ ពលរដ្ឋដែលទទួលអាណត្តិ សាធារណៈតាមការបោះឆ្នោត ព្រមទាំងបណ្តាអង្គភាពនៃវិស័យឯកជនពាក់ព័ន្ធមានជាអាទិ៍ ស្ថាប័ន ហិរញ្ញវត្ថុ ធ្វើកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីនៃអង្គភាព

---

[52] មាត្រា ៤០ កថាខណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[53] មាត្រា ១៧២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ បានចែងថា ៖ "តាមតម្រូវការចាំបាច់ដើម្បីសំដែងឲ្យឃើញនូវការពិត ចៅក្រមស៊ើបសួរ អាចបង្គាប់ឲ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឲ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នា តាមមធ្យោបាយទូរគមនាគមន៍ផងដែរ ដូចជា សារតាមទូរសារ ឬសារតាមអិនធើណែត"។

ក្នុងការងារស៊ើបអង្កេត។ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ក៏អាចស្នើសុំការសហការ ពីស្ថាប័នជាតិ និង អន្តរជាតិក្នុងការធ្វើកោសល្យវិច័យនានាទាក់ទងទៅនឹងការស៊ើបអង្កេតរបស់ខ្លួនផងដែរ"។

ជាទូទៅ នៅក្នុងតម្រូវការនៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំឲ្យមានការសហការ ជាមួយនឹងអាជ្ញាធរសាធារណៈផ្សេងៗទៀតបាន ក៏ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើ អធិបញ្ញា បានឡើយ។ ពាក្យ "អធិបញ្ញា" សំដៅទៅលើបញ្ជាដែលត្រូវតែអនុវត្តតាម ដោយមិនអាចប្រកែកបានឡើយ។ ផ្ទុយទៅវិញ សម្រាប់បទល្មើសពុករលួយ ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ បានផ្ដល់នូវសិទ្ធិពិសេសបែបនេះដល់អង្គភាព ប្រឆាំងអំពើពុករលួយ ដើម្បីសម្រួលដល់ការស៊ើបអង្កេត ជាពិសេសនៅពេលដែលជនសង្ស័យគឺជាមន្ត្រីរាជការ។

ព្រមជាមួយគ្នានេះ ដើម្បីបញ្ជាក់ឲ្យបានច្បាស់សម្រាប់ការស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ ជាពិសេសនៅពេលដែលវិទ្យាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា មិនទាន់មានការរីកចម្រើនគ្រប់គ្រាន់ សម្រាប់ ជាជំនួយដល់ការងារស៊ើបអង្កេតនោះ មាត្រា ២៩ នៃច្បាប់បានផ្ដល់សិទ្ធិពិសេសដល់ប្រធានអង្គភាពប្រឆាំង អំពើពុករលួយស្នើសុំការសហការជាមួយមិនត្រឹមតែស្ថាប័នជាតិប៉ុណ្ណោះទេ ថែមទាំងអាចស្នើសុំការសហការ ពីស្ថាប័នអន្តរជាតិទៀតផង ក្នុងគោលដៅធ្វើកោសលវិច័យផ្សេងៗ ដែលមានប្រយោជន៍ចំពោះការស៊ើបអង្កេត របស់អង្គភាពប្រឆាំងអំពើពុករលួយ។

## ១.៥. ការផ្អាកបណ្ដោះអាសន្ននូវមុខងារ

ផ្សារភ្ជាប់ជាមួយនឹងលក្ខណៈពិសេសនៃបទល្មើសពុករលួយ និង បុគ្គលដែលមានការពាក់ព័ន្ធនឹងបទ ល្មើសពុករលួយ មាត្រា ២៦ កថាខណ្ឌទី ១ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយបានចែងថា ៖ ប្រធានអង្គភាព ប្រឆាំងអំពើពុករលួយអាចស្នើសុំពីអាជ្ញាធរឋានានុក្រមពាក់ព័ន្ធ ឲ្យផ្អាកជាបណ្ដោះអាសន្ននូវមុខងារនៃបុគ្គល ទាំងឡាយណាដែលមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជាប់ទាក់ទិននឹងរឿងហេតុនៃបទល្មើសពុករលួយ។

ដូចជាករណីខាងលើដែរ សិទ្ធិស្នើសុំឲ្យមានការផ្អាកមុខងាររបស់ជនសង្ស័យគឺជាសិទ្ធិពិសេសមួយ ដែលជាធម្មតាមន្ត្រីនគរបាលយុត្តិធម៌តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌមិនអាចធ្វើយ៉ាងដូច្នេះឡើយ។ នៅក្នុង ការអនុវត្តជាក់ស្ដែង ការផ្អាកមុខងារជាបណ្ដោះអាសន្នអាចជាវិធានការ ដ៏មានប្រសិទ្ធភាព ដើម្បីទប់ស្កាត់កុំឲ្យ ជនសង្ស័យប្រើប្រាស់មុខងាររបស់ខ្លួន ក្នុងគោលដៅជះឥទ្ធិពលដល់ការស៊ើបអង្កេតផ្សេងៗ។

## ១.៦. ការស្នើសុំធ្វើបត្យាប័ន

មាត្រា ២៦ កថាខណ្ឌទី ២ ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយបានចែងថា ៖ "ប្រសិនបើជនជាប់ សង្ស័យរត់គេចខ្លួនទៅបរទេស ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ច ធ្វើបត្យាប័នតាមបទប្បញ្ញត្តិជាធរមាន"។

តាមពិត នេះគឺជាបញ្ញត្តិពិសេសមួយដែលផ្ដល់សិទ្ធិយ៉ាងសំខាន់ និងជាក់លាក់ដល់ប្រធានអង្គភាព ប្រឆាំងអំពើពុករលួយ នៅក្នុងការស្នើសុំឲ្យមានដំណើរការនីតិវិធីនៃការធ្វើបត្យាប័ន ជនដែលត្រូវបានសង្ស័យថា

ប្រព្រឹត្តបទល្មើសពុករលួយ។ ទោះជាយ៉ាងនេះក្តី ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយមិនបានចែងពីបទបញ្ញត្តិពិសេសស្តីពីការធ្វើបត្យាប័ន ខុសប្លែកពីក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ពោលគឺបទប្បញ្ញត្តិនៃជំពូកទី ២ មាតិកាទី ១ គន្ថីទី ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងរឿងបត្យាប័នពាក់ព័ន្ធនឹងបទល្មើសពុករលួយដែរ[54]។ ថ្វីត្បិតតែ ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងច្បាស់លាស់អំពីអាជ្ញាធរមានសមត្ថកិច្ចក្នុងការស្នើសុំបត្យាប័នក៏ដោយ ក៏ប៉ុន្តែបើយើងពិនិត្យមើលលើមាត្រា ១៥ នៃអនុក្រឹត្យលេខ ៤៧ អនក្រ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ឃើញថា នៅក្នុងចំណោមភារកិច្ចផ្សេងៗជាច្រើនរបស់នាយកដ្ឋានកិច្ចការព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ គេឃើញមានតួនាទីមួយរបស់នាយកដ្ឋាននេះក្នុងការពិនិត្យលើពាក្យសុំរបស់ស្ថាប័នអយ្យការនៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងការអនុវត្តបត្យាប័ន និងការធានាឲ្យមានការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជាអន្តរជាតិ ក្នុងរឿងព្រហ្មទណ្ឌ ហើយដែលក្រោយមកភារកិច្ចនេះត្រូវបានផ្ទេរទៅឲ្យអាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌វិញ។ សរុបមក គេអាចទាញនូវសេចក្តីសន្និដ្ឋានថា អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរឿងនេះ គឺក្រសួងយុត្តិធម៌ដែលជាស្ថាប័នមួយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការស្នើសុំតាមរយៈផ្លូវទូតទៅរដ្ឋនៃប្រទេសដែលជនល្មើសកំពុងជ្រកកោននៅ។

ចំណែកឯក្រមនីតិវិធីព្រហ្មទណ្ឌវិញ មិនបានផ្តល់សិទ្ធិពិសេសបែបនេះដល់មន្ត្រីនគរបាលយុត្តិធម៌ជាធម្មតាឡើយ។ ទោះជាយ៉ាងនេះក្តី គេអាចគិតថា ក្នុងស្ថានភាពខ្លះមន្ត្រីនគរបាលយុត្តិធម៌ក៏អាចចូលរួមចំណែក ដើម្បីឈានទៅដល់ការផ្តួចផ្តើមគំនិតស្នើសុំឲ្យមានបត្យាប័នផងដែរ ក៏ប៉ុន្តែច្បាប់មិនបានផ្តល់សិទ្ធិជាក់លាក់បែបនេះដល់មន្ត្រីនគរបាលយុត្តិធម៌ឡើយ។

### ១.៧. ការស្នើសុំបង្កកទ្រព្យសម្បត្តិ

មាត្រា ២៨ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានចែងថា ៖ "តាមការស្នើសុំរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រាជរដ្ឋាភិបាលអាចធ្វើអធិបញ្ញាឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអមសាលាដំបូង បង្កកទ្រព្យសម្បត្តិរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងនៅក្នុងច្បាប់នេះ និងបទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ"។

មិនខុសពីករណីខាងលើប៉ុន្មានទេ នេះគឺជាបុព្វសិទ្ធិមួយរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ហើយអាចធ្វើការស្នើសុំដូចខាងលើបាន។ អ្វីដែលជាលក្ខណៈពិសេសនៃបញ្ញត្តិនេះ គឺតាមរយៈការស្នើសុំដូចខាងលើ រាជរដ្ឋាភិបាលអាចធ្វើអធិបញ្ញាបាន ពោលគឺរាជរដ្ឋាភិបាលចេញបញ្ជាឲ្យបង្កកទ្រព្យសម្បត្តិ ទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ទៅកាន់

[54] មាត្រា ៥០ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃ ទី ១៧ ខែមេសា ឆ្នាំ២០១០។

ព្រះរាជអាជ្ញាឲ្យធ្វើការបង្កកទ្រព្យសម្បត្តិ ហើយជាពិសេសបញ្ហានេះ គឺជាបញ្ហាដែលមិនអាចប្រកែកប្រឆាំងបានឡើយ។

ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌមិនបានផ្តល់សិទ្ធិបែបនេះ ដល់មន្ត្រីនគរបាលយុត្តិធម៌ ជាទូទៅក្តី ក៏គេសង្កេតឃើញថា សម្រាប់បទល្មើសពិសេសមួយចំនួន ច្បាប់ពិសេសក៏បានចែងពី ការបង្កកទ្រព្យសម្បត្តិផងដែរ ហើយនៅក្នុងយន្តការដែលឈានដល់ការបង្កកទ្រព្យសម្បត្តិនេះ ក៏អាចមានការចូលរួមវិភាគទានពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ផងដែរ ក៏ប៉ុន្តែច្បាប់នៅតែមិនបានផ្តល់សិទ្ធិជាក់លាក់បែបនេះដល់មន្ត្រីនគរបាលយុត្តិធម៌ដែរ។ ជាក់ស្តែង ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅត្រង់មាត្រា ៨៩ និងមាត្រា ៩០ បានចែងពីការ ឃាត់ទុក និង បង្កកទ្រព្យសម្បត្តិ។ មាត្រា ៨៥ នៃច្បាប់ចែងថា ៖ "ព្រះរាជអាជ្ញាត្រូវឃាត់ទុកទ្រព្យសម្បត្តិ ដែលជាផលដែលកើតចេញពីបទល្មើស ឬត្រូវបានសង្ស័យថា ត្រូវបានប្រើប្រាស់ ឬបម្រុងទុកប្រើប្រាស់ ក្នុងការប្រព្រឹត្តបទល្មើស ហើយប្តឹងសុំជាបន្ទាន់ទៅចៅក្រមស៊ើបសួរ ឬតុលាការ ដោយយោងតាមករណីនៃការចោទប្រកាន់ ដើម្បីបង្កកទ្រព្យសម្បត្តិទាំងនោះ"។ ចំណែកឯមាត្រា ៩០ នៃច្បាប់នេះបានចែងថា ៖ "ចៅក្រមស៊ើបសួរ ឬតុលាការអាចបញ្ជាដោយឯកឯង ឬតាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញាឲ្យបង្កកទ្រព្យសម្បត្តិ ប្រសិនបើពិនិត្យឃើញថា មានមូលហេតុសមហេតុផល និងសង្ស័យថាទ្រព្យនោះជាផលដែលកើតចេញពីបទល្មើស ឬត្រូវបានសង្ស័យថាបានប្រើប្រាស់ ឬបម្រុងទុកប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស។ រួមសេចក្តីមកថ្វីត្បិតតែច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចែងពីការបង្កកទ្រព្យសម្បត្តិក៏ពិតមែន តែច្បាប់មិនបានផ្តល់សិទ្ធិដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស្នើសុំឲ្យមានអធិបញ្ញាដូចករណីដែលបានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែរ ជាពិសេសទៅ ទៀតគំនិតផ្តួចផ្តើមគឺស្ថិតនៅលើព្រះរាជអាជ្ញា ហើយចៅក្រមស៊ើបសួរ ឬតុលាការជាអ្នកសម្រេច។

## ២. កិច្ចស៊ើបអង្កេតដែលមានលក្ខណៈដូចគ្នាសម្រាប់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ និងមន្ត្រីនគរបាលយុត្តិធម៌ផ្សេងទៀត

ក្រៅពីលក្ខណៈពិសេសដែលបានធ្វើការកត់សម្គាល់ខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌ រួមទាំងមន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយផងដែរ អាចចាត់វិធានការមួយចំនួន ដោយខ្លួនឯងបានដោយមិនតម្រូវឲ្យមានការរាយការណ៍ ឬ ការអនុញ្ញាតជាពិសេសអ្វីឡើយ។ ត្រង់ចំណុចនេះមន្ត្រីនគរបាលយុត្តិធម៌ រួមបញ្ចូលទាំងមន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយដែរ ត្រូវគោរពតាមបទបញ្ញត្តិនៃនីតិវិធីដូចគ្នា។ លក្ខណៈដូចគ្នាទាំងនោះស្តែងចេញតាមរយៈការអនុវត្តវិធានការស្រាវជ្រាវខ្លះ និង ការអនុវត្តនីតិវិធីក្រោយពីមានការឃាត់ខ្លួន ជនសង្ស័យរួចហើយ។

## ២.១. ការអនុលោមតាមវិធានការស្រាវជ្រាវដូចគ្នា

យោងតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានស្តែងឲ្យឃើញថា ការសម្រេចពីការបើកការស៊ើបអង្កេតបឋម ការចាប់យកវត្ថុតាង ការស្តាប់ចម្លើយ ជនពាក់ព័ន្ធ ព្រមទាំងការធ្វើកោសល្យវិច័យនានា សុទ្ធសឹងតែជាកិច្ចការដែលមន្ត្រីនគរបាលយុត្តិធម៌ អាចសម្រេចដោយខ្លួនឯង ពោលគឺមិនចាំបាច់មានការសម្របសម្រួលដឹកនាំពីព្រះរាជអាជ្ញាឡើយ ក្នុងន័យនេះ អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ ក៏មិនខុសប្លែកពីគ្នានោះដែរ។

### ២.១.១. ការបើកការស៊ើបអង្កេតបឋម

មាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ៖ "កាលណាបានដឹងពីអំពើដែលអាចជា បទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា ។

### ២.១.២. ការចាប់យកវត្ថុតាង

ពាក់ព័ន្ធនឹងវត្ថុចាប់យក មាត្រា ៩២[55] នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ៖ "មន្ត្រីនគរបាលយុត្តិធម៌អាចចាប់យកវត្ថុតាង។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ។ ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬ ដល់សាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការចាប់យកដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់។ កំណត់ហេតុស្តីពីការចាប់យកត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់"[56]។

### ២.១.៣. ការស្តាប់ចម្លើយ

ដូចគ្នាដែរ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស្តាប់ចម្លើយជនពាក់ព័ន្ធនៅក្នុងនីតិវិធីបាន។ ការស្តាប់ចម្លើយនីមួយៗត្រូវមានធ្វើកំណត់ហេតុ។ កំណត់ហេតុត្រូវដកស្រង់តាមដោយត្រឹមត្រូវនូវ សេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែដែលស្បថថានិយាយការពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាច ជ្រើសរើសពីក្នុងចំណោមនគរបាលកងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ។ ទំព័រនីមួយៗនៃកំណត់ហេតុត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយ។ មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំឡេងខ្លាំងៗ នូវខ្លឹមសារ

[55] សម្រាប់ការស៊ើបអង្កេតបឋម មាត្រា ១១៣ កថាខណ្ឌចុងក្រោយនៃក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវឲ្យយកមាត្រា ៩២ នៃ ក្រមមកអនុវត្ត។
[56] មាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានចែងថា ៖ "ការចាប់យកត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

កំណត់ហេតុ។ មន្ត្រីនគរបាលយុត្តិធម៌អាចហៅកអ្នកប្រែបាន។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[57]។

### ២.១.៤. ភោសល្យវិច័យ

បន្ថែមពីលើនេះទៀត ដើម្បីស្វែងរកភស្តុតាងនានានៅក្នុងរឿងក្តី មន្ត្រីនគរបាលយុត្តិធម៌ អាចពឹងពាក់ទៅលើអ្នកជំនាញឲ្យជួយដល់ការងាររបស់ខ្លួនបាន។ ជាក់ស្តែង មាត្រា៩៥ នៃក្រម នីតិវិធីព្រហ្មទណ្ឌបានចែងថា ៖ "ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បានមន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា ១៦៣ នៃក្រមនេះទេ! បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ[58]។

## ២.២. នីតិវិធីក្រោយការឃាត់ខ្លួនជនសង្ស័យ

ក្រោយពីមានការឃាត់ខ្លួនជនសង្ស័យរួចហើយ មាត្រា ២៥ កថាខណ្ឌទី ៦ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយបានកំណត់ថា ព្រះរាជអាជ្ញាអនុវត្តអំណាចរបស់ខ្លួនដូចបានកំណត់នៅក្នុង បទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះ បន្ទាប់ពីមានការឃាត់ខ្លួនជនសង្ស័យរួចហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពតាមបញ្ញត្តិស្តីពីការបញ្ជូនខ្លួន ព្រមទាំងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការ អនុវត្តកិច្ចការដែលតុលាការប្រគល់ជូន។

### ២.២.១. ការបញ្ជូនជនសង្ស័យ

យោងតាមមាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បុគ្គលដែលត្រូវបានឃាត់ខ្លួនអាចត្រូវ បញ្ជូនទៅព្រះរាជអាជ្ញា ឬ ដោះលែងឲ្យមានសេរីភាពឡើងវិញ។ ការសម្រេចយ៉ាងដូច្នេះ មិនមែនស្ថិតនៅលើមន្ត្រីនគរបាលយុត្តិធម៌នោះទេ ក៏ប៉ុន្តែស្ថិតនៅលើការសម្រេចសេចក្តីរបស់ព្រះរាជអាជ្ញាទៅវិញ។

ប្រសិនបើព្រះរាជអាជ្ញាបានសម្រេចថាឲ្យដោះលែងបុគ្គលដែលឃាត់ខ្លួនឲ្យមានសេរីភាពឡើងវិញ បុគ្គលនោះមិនចាំបាច់ត្រូវបញ្ជូនមកចំពោះមុខព្រះរាជអាជ្ញាឡើយ។ ផ្ទុយទៅវិញនោះ ពេលដែលព្រះរាជអាជ្ញាសម្រេចឲ្យបញ្ជូនបុគ្គលដែលឃាត់ខ្លួនមកចំពោះមុខព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនបុគ្គលនេះទៅចំពោះមុខព្រះរាជអាជ្ញាភ្លាម។ ក៏ប៉ុន្តែប្រសិនបើមានឧបសគ្គ នៅក្នុងការដឹកជញ្ជូន ឬបណ្តាលមកពីចម្ងាយផ្លូវឆ្ងាយដែលនាំឲ្យពុំអាចបញ្ជូនបុគ្គលដែលត្រូវបាន ឃាត់ខ្លួនមកចំពោះមុខព្រះរាជអាជ្ញានៅថ្ងៃតែមួយបាន ព្រះរាជអាជ្ញាអាចអនុញ្ញាតផ្តល់រយៈពេលបន្ថែមឲ្យបាន។ ទោះជាយ៉ាងនេះក្តី ការយឺតយ៉ាវនៃការបញ្ជូនត្រូវចុះមូលហេតុ

---

[57] មាត្រា ៩៣ និង មាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[58] ចំពោះការស៊ើបអង្កេតបឋម មាត្រា ១១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឲ្យយកមាត្រា ៩៥ នៃក្រមមកអនុវត្តផងដែរ។

នៅក្នុងកំណត់ហេតុផងដែរ[59]។ ទន្ទឹមនឹងនេះដែរ មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញាផងដែរ ក្រោយពីបានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន[60]។

**២.២.២. ការអនុវត្តកិច្ចផ្សេងៗតាមការបញ្ជាដោយចៅក្រម**

ក្រៅពីនេះ មន្ត្រីនគរបាលយុត្តិធម៌ក៏មានភារកិច្ចនៅក្នុងការអនុវត្តដីកាផ្សេងៗដែលចេញដោយចៅក្រម ។ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចក្នុងការជូនដំណឹងពីដីកាបង្គាប់ឲ្យចូលខ្លួន អនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន និង ដីកាបង្គាប់ឲ្យចាប់ខ្លួន ដែលចេញដោយចៅក្រមស៊ើបសួរ[61]។

ដីកាបង្គាប់ឲ្យចូលខ្លួន គឺជាបញ្ជាដល់បុគ្គលណាម្នាក់ឲ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឲ្យចូលខ្លួនអាចចេញតែទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែល មានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ[62] ហើយបុគ្គលដែលត្រូវបញ្ជាឲ្យចូលខ្លួនមានសិទ្ធិសេរីភាពក្នុងការបង្ហាញខ្លួន ចំពោះមុខចៅក្រមស៊ើបសួរ ឬមិនបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ។ ផ្ទុយទៅវិញ ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន និង ដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលអាចប្រើកម្លាំងសាធារណៈ ចាប់បង្ខំដល់ជនត្រូវចោទឲ្យចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរបាន។ ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឲ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ដែលអាចជាជនត្រូវចោទ ឬបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពទៅចំពោះមុខចៅក្រមស៊ើបសួរ[63]។ ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ និងឲ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន និងជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនបុគ្គលនោះ[64]។

ព្រមជាមួយគ្នានេះ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចទទួលសិទ្ធិឲ្យធ្វើការស៊ើបសួរជំនួសចៅក្រមស៊ើបសួរដែរ តាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស។ មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ៖ "តាមរយៈដីកា

---

[59] មាត្រា ១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧។

[60] មាត្រា ១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៨ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧។

[61] មាត្រា ១៨៨ មាត្រា ១៩២ និង មាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម /០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[62] មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[63] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[64] មាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។ ក្រៅពីនេះ ចៅក្រមជំនុំជម្រះក៏អាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទដែលអវត្តមានផងដែរ ហើយដីកានេះមានអានុភាពអនុវត្តភ្លាមៗ (មាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧)។

ចាត់ឲ្យស៊ើបសួរជំនួសចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិឲ្យទៅចៅក្រមនៃតុលាការរបស់ខ្លួន ឬតុលាការផ្សេងទៀត មន្ត្រីនគរបាលយុត្តិធម៌ ឬដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរ។ កាលណាដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវបានប្រគល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលមានចែងនៅក្នុងមាត្រា ១៧៨ ដល់មាត្រា ១៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយនៅក្នុងការបំពេញកិច្ចការនេះ មន្ត្រីនគរបាលយុត្តិធម៌ស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនចៅក្រមនេះតែប៉ុណ្ណោះ[65]។ នៅក្នុងការបំពេញការងារដូចខាងលើ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើ កំណត់ហេតុស្ដីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួនអាចកោះហៅ និងស្ដាប់ចម្លើយសាក្សី ក៏ប៉ុន្តែសាក្សីត្រូវតែស្បថតាមសាសនា ឬជំនឿរបស់ខ្លួនជាមុនសិន មុននឹងផ្ដល់ចម្លើយ។ ទន្ទឹមនឹងនេះ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងផ្សេង ស្ដាប់និងថត ការសន្ទនាតាមទូរស័ព្ទ ឬចាប់ និងថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ព្រមទាំងអាចឈានទៅដល់ការឃាត់ខ្លួនជនត្រូវចោទថែមទៀតផង[66]។ ក៏ប៉ុន្តែទោះជាយ៉ាងណាក្ដី មន្ត្រីនគរបាលយុត្តិធម៌មិនអាចត្រូវបានផ្ទេរសិទ្ធិឲ្យសួរចម្លើយជនត្រូវចោទ ឬស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីបានទេ[67]។

---

[65] មាត្រា ១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[66] មាត្រា ១៧៨ មាត្រា ១៧៩ មាត្រា ១៨១ មាត្រា ១៨២ មាត្រា ១៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជ ក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[67] មាត្រា ១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាអំពីមន្ត្រីនគរបាលយុត្តិធម៌តាមបញ្ញត្តិ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយរួចមក យើងសង្កេតឃើញថា ច្បាប់បានផ្តល់នូវសិទ្ធិអំណាចពិសេសជាច្រើនដល់អង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីអនុញ្ញាតឲ្យអង្គភាពអាចបំពេញបេសកកម្មរបស់ខ្លួនដោយជោគជ័យ។ ក្នុងនាមជាអង្គភាពនគរបាលយុត្តិធម៌ អង្គភាពប្រឆាំងអំពើពុករលួយមានតួនាទីយ៉ាងសំខាន់ ក្នុងការបង្ក្រាបបទល្មើសពុករលួយ ដែលជាដំបៅមហារីកនៅក្នុងសង្គមគ្រប់ប្រភេទទាំងអស់ ហើយនេះគឺជាសមត្ថកិច្ចផ្តាច់មុខរបស់អង្គភាពប្រឆាំងអំពើពុករលួយ ដែលមិនអាចអង្គភាពណាផ្សេងអនុវត្តជំនួសបានឡើយ។ តាមពិតការប្រគល់សមត្ថកិច្ចផ្តាច់មុខបែបនេះ គឺជាការល្អប្រសើរណាស់ ដើម្បីអង្គភាពដែលមានជំនាញច្បាស់លាស់ និង ជាក់លាក់ អាចចាត់វិធានការផ្សេងៗ ក្នុងគោលដៅបង្ក្រាបបទល្មើសពុករលួយ ដែលជាបទល្មើសប្រកបដោយលក្ខណៈពិសេសដោយឡែក បើប្រៀបទៅនឹងបទល្មើសព្រហ្មទណ្ឌសាមញ្ញដទៃទៀត នៅក្នុងសង្គម។ លក្ខណៈពិសេសនេះ គឺដោយសារតែភាគច្រើនជនពុករលួយគឺជាបុគ្គលដែលមានសិទ្ធិអំណាច មានទ្រព្យសម្បត្តិ និងមានឥទ្ធិពលនៅក្នុងសង្គមជាក់ស្តែង។

ជាងនេះទៅទៀត តាមរយៈព័ត៌មានដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ ពាក់ព័ន្ធនឹងការងារបង្ក្រាបបទល្មើសដោយអង្គភាពប្រឆាំងអំពើពុករលួយ បានបង្ហាញឲ្យឃើញថា ចាប់តាំងពីការបង្កើតអង្គភាពនេះរួចមក បទល្មើសពុករលួយសំខាន់ៗជាច្រើនត្រូវបានបង្ក្រាប ដែលសុទ្ធសឹងតែជាបទល្មើសដែលបានបង្កនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈរបស់សង្គមជាតិ ហើយជនល្មើសដែលត្រូវបានបង្ក្រាប គឺជាបុគ្គលដែលមានឋានៈខ្ពង់ខ្ពស់នៅក្នុងជួរមន្ត្រីរាជការ ហើយទន្ទឹមនឹងនេះ ក៏ឃើញមានការបង្ក្រាបបុគ្គលជាជនល្មើសដែលជាបុគ្គល ឯកជន ហើយមានការពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើពុករលួយ ដូចជាអ្នកឆបោកប្រាក់ ក្រោមលេសថាយកទៅប្រគល់ឲ្យមន្ត្រីតុលាការជាដើម។ ទាំងអស់នោះសុទ្ធសឹងតែជាសមិទ្ធផលដ៏ត្រចះត្រចង់របស់អង្គភាពប្រឆាំងអំពើពុករលួយ ដែលបានចាប់ផ្តើមធ្វើប្រតិបត្តិការរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់ និងដោយមានការគាំទ្រពីសំណាក់មតិជាតិ និង អន្តរជាតិជាទូទៅ ហើយក៏បានបង្ហាញឲ្យឃើញដែរថា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការកាត់បន្ថយអំពើអសកម្មបែបនេះនៅក្នុងសង្គម និងឈានទៅដល់ការលុបបំបាត់ចោលទាំងស្រុង នៅពេលអនាគត។

លទ្ធផលជាវិជ្ជមាននេះកាន់តែបង្ហាញឲ្យឃើញជាបន្ថែមទៀតថា ការកំណត់ប្រគល់បុព្វសិទ្ធិពិសេសដល់អង្គភាពប្រឆាំងអំពើពុករលួយ គឺជាជម្រើសដ៏ត្រឹមត្រូវបំផុត ពីព្រោះថា បទល្មើសពុករលួយជាបទល្មើសដែលមានលក្ខណៈពិសេសខុសប្លែកពីបទល្មើសសាមញ្ញ។

# អនុសាសន៍

ទន្ទឹមនឹងនេះ នៅក្នុងបរិបទបច្ចុប្បន្ននេះ ប្រសិនបើមានត្រឹមតែអង្គភាពប្រឆាំងអំពើពុករលួយនៅថ្នាក់ជាតិ គឺមិនអាចបំពេញការងារបង្ក្រាបបទល្មើសពុករលួយបានជាទូទៅឡើយ។ ដូច្នេះ យើងខ្ញុំសូមផ្តល់អនុសាសន៍ដូចតទៅ៖

១. គួរតែបង្កើតការិយាល័យប្រឆាំងអំពើពុករលួយរាជធានី-ខេត្ត ឲ្យបានកាន់ឆាប់រហ័ស។

២. គួរតែបង្កើនចំនួនមន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ ឲ្យបានកាន់តែច្រើនជាងពេលបច្ចុប្បន្ន ដើម្បីមានលទ្ធភាពចាត់វិធានការបង្ក្រាបលើបទល្មើសពុករលួយ កាន់តែបានចំនួនច្រើន និង ប្រកបដោយប្រសិទ្ធភាពកាន់តែខ្ពស់។

៣. បង្កើនកិច្ចសហប្រតិបត្តិការរវាងអង្គភាពអនុវត្តច្បាប់នានាជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយក្នុងការបង្ក្រាបបទល្មើសពុករលួយឲ្យមានប្រសិទ្ធភាពខ្ពស់។

៤. ណែនាំ ផ្សព្វផ្សាយ អប់រំទៅដល់ប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ចូលរួមបំបាត់ប្រឆាំងនឹងអំពើពុករលួយ និងលើកទឹកចិត្តឲ្យមានការចូលរួមតាមរយៈ ការរាយការណ៍អំពីអំពើពុករលួយណាដែលខ្លួនបានដឹង មកអង្គភាពប្រឆាំងអំពើពុករលួយតាមប្រអប់សំបុត្រតាមផ្លូវសាធារណៈដែលបានរៀបចំដោយអង្គភាពប្រឆាំងអំពើពុករលួយទូទាំងប្រទេស។

៥. បង្កើននូវសមត្ថភាព សម្ភារៈបច្ចេកទេសដល់អង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីជាជំនួយក្នុងការស្រាវជ្រាវស៊ើបអង្កេតបទល្មើសពុករលួយឲ្យទទួលបានប្រសិទ្ធភាពខ្ពស់។

៦. ជំរុញដល់មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយក្នុងការបង្ក្រាប និងអនុវត្តឲ្យបានតឹងរឹងទៅបទល្មើសពុករលួយ។

៧. បង្កើតក្រុមការងារឆ្លើយតបបន្ទាន់ទទួលបន្ទុកផ្នែកបច្ចេកវិទ្យា និងប្រព័ន្ធបណ្តាញសង្គម ដើម្បីតាមដាន ឆ្លើយតបទៅនឹងសារ ឬវាយតម្លៃការផ្ញើសារ ការផ្តល់យោបល់ (Facebook Comment) និងការទទួលបានបណ្តឹងគ្រប់រូបភាពដែលប្រើប្រាស់ដោយប្រព័ន្ធបច្ចេកវិទ្យា។

៨. លើកស្ទួយ និងបង្កើតក្រុមការងារដើម្បីចងក្រង និងបង្កើតកម្មវិធីទូរស័ព្ទឆ្លើយតបនឹងបណ្តឹង ឬករណីពុករលួយ។

៩. អប់រំ ផ្តល់ពុទ្ធិ ចំណេះជំនាញបន្ថែមដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញបេសកកម្ម ទាំងរឿងក្តីព្រហ្មទណ្ឌ សណ្តាប់ធ្នាប់សង្គម ទាំងរឿងក្តីពុករលួយ។

# ឯកសារយោង

## ឯកសារយោង

១. ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧។

២. ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើនៅថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៣។

៣. ក្រមព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩។

៤. ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨១០/០០៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០១០។

៥. ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨១១/ ០១៧ ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១១។

៦. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី ០២ ខែមករា ឆ្នាំ ២០១២។

៧. ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ១៩៩៣។

៨. ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ១៩៩២។

៩. អនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ។

១០. ប្រកាសលេខ ១០៩ កយ.ប្រក/១១ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌។

១១. សៀវភៅ "នីតិព្រហ្មទណ្ឌទូទៅ- រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ឆ្នាំ២០១២។

១២. ឯកសារមេរៀន "នីតិវិធីព្រហ្មទណ្ឌ" ដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រី ចាំង ស៊ីណាត។

# ឧបសម្ព័ន្ធ ១

ព្រះរាជក្រម

នស/រកម/០៨០៧/០២៤

# យើង

# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
# សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
# ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
# ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាម ទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ក្រមនីតិវិធីព្រហ្មទណ្ឌ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

ដោយពាក្យសុំដែលមានសំអាងហេតុរបស់ព្រះរាជអាជ្ញា ដែលធ្វើឡើងដោយការផ្ដើមគំនិតផ្ទាល់ខ្លួន ឬតាមរយៈពាក្យប្ដឹងរបស់ភាគី ។

មូលហេតុនៃការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ ត្រូវយោងតាមបញ្ញត្តិនៃមាត្រា ៥៥៦ (មូលហេតុនៃការប្ដឹងជំទាស់ចៅក្រមអាសនៈ) នៃក្រមនេះ ។

**មាត្រា ៥៤. – ករណីមិនព្រមវៀរចាកដែលនាំឱ្យមោឃភាព**

ចៅក្រមស៊ើបសួរមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងព្រហ្មទណ្ឌ ដែលខ្លួនបានចាត់ការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើពុំដូច្នេះទេ ការជំនុំជម្រះត្រូវចាត់ទុកជាមោឃៈ ។

ចៅក្រមស៊ើបសួរប្រើអំណាចដែលមានចែងនៅក្នុងក្រមនេះ ។

## មាតិកាទី ៣
## សភាស៊ើបសួរ
## ជំពូកតែមួយ
## សភាស៊ើបសួរ

**មាត្រា ៥៥. – សភាពិសេសនៃសាលាឧទ្ធរណ៍**

នៅក្នុងសាលាឧទ្ធរណ៍មានសភាមួយដែលមានឈ្មោះថា សភាស៊ើបសួរ ។ សភាស៊ើបសួរមានសមត្ថកិច្ចជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ដែលធ្វើឡើងប្រឆាំងនឹងសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ ។

សមាជិកនៃសភាស៊ើបសួរពុំអាចចូលរួមក្នុងការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌ ដែលខ្លួនបានចាត់ការក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើមិនដូច្នេះទេ សាលដីកានោះត្រូវចាត់ទុកជាមោឃៈ ។

## មាតិកាទី ៤
## នគរបាលយុត្តិធម៌
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៦. – បេសកកម្មរបស់នគរបាលយុត្តិធម៌**

នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការ ។

នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង ។

**មាត្រា ៥៧.** – សមាសភាពរបស់នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌រួមមាន :

១-មន្ត្រីនគរបាលយុត្តិធម៌ ។

២-ភ្នាក់ងារនគរបាលយុត្តិធម៌ ។

៣-មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៥៨.** – ការសម្របសម្រួលសកម្មភាពការងាររបស់នគរបាលយុត្តិធម៌

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ។

ព្រះរាជអាជ្ញាមានអំណាចទៅលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលចែងនៅក្នុងមាត្រា ៨២ (ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត) នៃក្រមនេះ កាលណាមន្ត្រីនេះបំពេញមុខងាររបស់ខ្លួនជានគរបាលយុត្តិធម៌ ។

កាលណាអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ។

**មាត្រា ៥៩.** – ការត្រួតពិនិត្យលើនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌ ។

## ជំពូកទី ២
## មន្ត្រីនគរបាលយុត្តិធម៌
### ផ្នែកទី ១
### ការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌

**មាត្រា ៦០.** – មន្ត្រីនគរបាលយុត្តិធម៌

មានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ :

១-មន្ត្រីនគរបាលជាតិ មានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបំពេញការងារយ៉ាងតិចបំផុត ២ (ពីរ) ឆ្នាំ ក្នុងនគរបាលជាតិរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ។

២-នាយទាហាននៃកងរាជអាវុធហត្ថ ដែលបានបំពេញការងារយ៉ាងតិចបំផុត ២ (ពីរ) ឆ្នាំ ក្នុងកងរាជអាវុធហត្ថរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ។

៣-អ្នកមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោម :

ក. អភិបាល និងអភិបាលរង ខេត្ត ក្រុង, អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និង មេឃុំ ចៅសង្កាត់ ។

ខ. ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ។

គ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមនិវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ។

ឃ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក នៃ :

- នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"
- មន្ទីរប្រឆាំងគ្រឿងញៀន
- នាយកដ្ឋាននគរបាលទេសចរណ៍
- ស្នងការពិសេសការពារបេតិកភ័ណ្ឌ ។

ង. ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង ។

ច. ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុងដូចជា :

- ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកំរិតស្រាល
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំងភេរវកម្ម និង
- ការិយាល័យជនបរទេស ។

ឆ. អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុក ខណ្ឌ ។

ជ. ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ “ចំពោះបទល្មើសចរាចរ” ។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ “ចំពោះបទល្មើសអាវុធជាតិផ្ទុះ” ។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធាន ផ្នែកនៃការិយាល័យនគរបាលទេសចរណ៍ ។

ឈ. ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ “ចំពោះបទល្មើសព្រហ្មទណ្ឌ” ។

ញ. មេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ដ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ឋ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ឌ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ ។

ឍ. ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់ ។

រដ្ឋមន្ត្រីជាអាណាព្យាបាលនៃមន្ត្រីនគរបាល ឬជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចទី១ ទី២ និងទី៣ នៃមាត្រានេះ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយណាដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៦១. – សញ្ញាប័ត្រជាន់ខ្ពស់របស់នគរបាលយុត្តិធម៌**

សញ្ញាប័ត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌ ត្រូវផ្តល់ជូនបន្ទាប់ពីឆ្លងកាត់ការប្រលងបែបវិជ្ជាជីវៈ ដែលរួមមានវិញ្ញាសាជាមូលដ្ឋានដូចខាងក្រោម :

១-វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌ ។

២-វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

៣-វិញ្ញាសាស្តីពីករណីយកិច្ចសាស្ត្រ ដូចដែលមានចែងនៅក្នុងក្រមសីលធម៌ ដែលតាក់តែងដោយអង្គការសហប្រជាជាតិ ។

សញ្ញាប័ត្រនេះត្រូវចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីពាក់ព័ន្ធ និងមានបោះត្រាផង ។

**មាត្រា ៦២. - គណៈមេប្រយោគ**

គណៈមេប្រយោគនៃការប្រលង ស្ថិតក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលមុខងារនេះ ។

១-ទាក់ទងនឹងមន្ត្រីនៃនគរបាលជាតិ គណៈមេប្រយោគមានសមាសភាពដូចតទៅ :

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូប របស់ក្រសួងមហាផ្ទៃ ។

២-ទាក់ទងនឹងយោធិននៃកងរាជអាវុធហត្ថ គណៈមេប្រយោគមានសមាសភាពដូចតទៅ :

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូប មកពីក្រសួងការពារជាតិ ។

បែបបទនៃការចេញសញ្ញាប័ត្រ ត្រូវកំណត់ដោយប្រកាសរួមមួយ រវាងរដ្ឋមន្ត្រីពាក់ព័ន្ធ ។

**មាត្រា ៦៣. - សម្បថនៃមន្ត្រីនគរបាលយុត្តិធម៌**

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវស្បថថា ខ្លួននឹងបំពេញដោយភក្ដីភាពនូវមុខងាររបស់ខ្លួន ។ សម្បថត្រូវធ្វើនៅមុខសាលាឧទ្ធរណ៍ ។ សម្បថមិនចាំបាច់ធ្វើជាថ្មីម្ដងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត ។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ផ្នែកទី ២

## កំហុសប្រព្រឹត្តក្នុងពេលអនុវត្តមុខងារ

**មាត្រា ៦៤. - នីតិវិធីខាងវិន័យ**

រាល់កំហុសទាំងឡាយ ដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងពេលអនុវត្តមុខងាររបស់ខ្លួន ត្រូវតែរាយការណ៍ដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីផ្ដើមដំណើរការនីតិវិធីវិន័យ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានផ្ដល់ដំណឹងអំពីចំណាត់ការជាបន្តនៃនីតិវិធីវិន័យនេះ ។

**មាត្រា ៦៥.** – ទណ្ឌកម្មខាងវិន័យ

ទណ្ឌកម្មខាងវិន័យទាំងឡាយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

កាលណាមន្ត្រីនគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួន យុត្តាធិការស៊ើបសួរ ឬជំនុំជម្រះដែលទទួលបន្ទុករឿងនេះ ត្រូវផ្ញើរសំណុំរឿងតាមសេចក្តីសម្រេចរបស់តុលាការកំពូលទៅឱ្យយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ និងត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាពសាមី ។

ពាក្យសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ។

**មាត្រា ៦៦.** – ការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា សភាពធ្ងន់ធ្ងរនៃកំហុសដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ មានវិសមិតភាពជាមួយនឹងការបំពេញមុខងារ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិប្រកាសចេញវិធានការដូចខាងក្រោម :

១-ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើនបំផុត ។

២-ហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ ។

មុននឹងចេញសេចក្តីសម្រេចរបស់ខ្លួន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ កោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រាទុកនូវសេចក្តីសង្កេតរបស់មន្ត្រីនោះ ។ សាមីជនអាចរកជំនួយពីមេធាវី ឬពីទីប្រឹក្សាម្នាក់ តាមការជ្រើសរើសរបស់ខ្លួន ។

សេចក្តីសម្រេចពីការហាមឃាត់ ត្រូវតែបញ្ជាក់សំអាងហេតុ ។ សេចក្តីសម្រេចនេះ ត្រូវផ្តល់ជាដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ទៅតាមករណីនីមួយៗ ។

សេចក្តីសម្រេចនេះ អាចជាកម្មវត្ថុនៃបណ្តឹងតវ៉ា ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលអាចប្រកាសបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់របស់អគ្គព្រះរាជអាជ្ញា ។ ក្រសួងសាមីនៃមន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ អាចបញ្ជូនយោបល់របស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់ អាចដាក់ពាក្យប្តឹងតវ៉ាដោយមានសំអាងហេតុ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលដំណឹង អំពីសេចក្តីសម្រេចហាមឃាត់នោះ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវសម្រេចសេចក្តីលើបណ្តឹងតវ៉ាខាងលើ ក្នុងអំឡុងពេលយ៉ាងយូរបំផុត ១ (មួយ) ខែ គិតពីថ្ងៃទទួលពាក្យប្តឹង ។ សេចក្តីសម្រេចនេះ មិនអាចប្តឹងតវ៉ាបានឡើយ ។

ក្នុងអំឡុងពេលដែលអាចធ្វើបណ្តឹងតវ៉ា និងអំឡុងពេលនៃការសម្រេចសេចក្តីលើបណ្តឹងតវ៉ា មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានអគ្គព្រះរាជអាជ្ញាសម្រេចហាមឃាត់នោះ មិនអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ឡើយ ។ មន្ត្រីនេះអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌វិញបាន ប្រសិនបើរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សម្រេចបដិសេធចោលការសម្រេចហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់ ។

កិច្ចទាំងឡាយដែលមន្ត្រីនគរបាលយុត្តិធម៌បានបំពេញ ដោយបំពានសេចក្តីសម្រេចពីការហាមឃាត់របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នេះ ត្រូវចាត់ទុកជាមោឃៈ ។

## ផ្នែកទី ៣
## សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌

### មាត្រា ៦៧. – មណ្ឌលរដ្ឋបាលបំពេញការងារ

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឱ្យទៅបំពេញការងារ ។

នៅភ្នំពេញមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅលើវិសាលភាពនៃក្រុងទាំងមូល ទោះបីជាអង្គភាពដែលខ្លួនផ្ទាស់ទៅកាន់នោះ នៅកន្លែងណាក៏ដោយ ។

សេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជាក់មណ្ឌលរដ្ឋបាល ដែលមន្ត្រីនោះត្រូវចាត់តាំងឱ្យទៅបំពេញការ ។ សេចក្តីសម្រេចនេះ ត្រូវផ្តល់ដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

### មាត្រា ៦៨. – ការពន្លាតសមត្ថកិច្ចដែនដី

ក្នុងករណីបទឧក្រិដ្ឋ ឬបទបញ្ជិមជាក់ស្តែងតាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៧ (ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ ហើយប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល ។ ការអនុញ្ញាតអាចធ្វើដោយផ្ទាល់មាត់ ប៉ុន្តែការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត ។

ក្នុងក្របខ័ណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីកាចាត់ឱ្យស៊ើបសួរជំនួសក្នុងករណីបន្ទាន់ ចៅក្រមនេះអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដីជាតិទាំងមូល ។

កាលណាធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី ។

ចៅក្រមដែលបានអនុញ្ញាតឱ្យមានការពន្យាតសមត្ថកិច្ច ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដី ។

### មាត្រា ៦៩. - កម្មវិបាកនៃការមិនគោរពវិធានសមត្ថកិច្ច

វិធាននៃសមត្ថកិច្ចខាងដែនដីដែលបានបញ្ញត្តនៅក្នុងមាត្រាមុនៗនេះ មានលក្ខណៈដាច់ខាត ។ បើមិនគោរពតាមទេនោះ កិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ ។

### មាត្រា ៧០. - សេចក្តីបង្គាប់បញ្ជារបស់អាជ្ញាធរតុលាការ

មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ទទួលបញ្ជា ឬសុំបញ្ជាតែពីអាជ្ញាធរតុលាការ ។

## ផ្នែកទី ៤
## បេសកកម្មនៃមន្ត្រីនគរបាលយុត្តិធម៌

### មាត្រា ៧១. - កំណត់ហេតុនៃបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌ទទួលបណ្តឹងទាមទារ និងបណ្តឹងហិរហារ ។ មន្ត្រីនគរបាលយុត្តិធម៌ពិនិត្យបទល្មើសទាំងឡាយ ។

មន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងធ្វើការស៊ើបអង្កេតបឋមក្នុងលក្ខខណ្ឌនៃមាត្រា ៨៤ (ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត) ដល់មាត្រា ១១០ (អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម) នៃក្រមនេះ ។

កាលណាការស៊ើបសួរបានចាប់ផ្តើម មន្ត្រីនគរបាលយុត្តិធម៌ អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសពីចៅក្រមស៊ើបសួរនៅក្នុងលក្ខខណ្ឌដែលបានចែងដោយមាត្រា ១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។

### មាត្រា ៧២. - កំណត់ហេតុ

គ្រប់បណ្តឹងដែលទទួលដោយមន្ត្រីនគរបាលយុត្តិធម៌នោះ តម្រូវឱ្យមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវស្រង់ដោយត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់អ្នកប្តឹង ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែភាសាម្នាក់ដែលត្រូវស្បថតាមជំនឿ ឬសាសនាថាខ្លួននឹងបកប្រែភាសាឱ្យបានត្រឹមត្រូវតាមសេចក្តីរាយការណ៍ ។ នៅក្នុងករណីណាក៏ដោយអ្នកបក

ប្រែភាសាមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការបានឡើយ ។

កំណត់ហេតុស្តីអំពីការដាក់ពាក្យប្តឹងត្រូវមានចុះសេចក្តីដូចតទៅ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌នេះ

-កាលបរិច្ឆេទ ។

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអ្នកប្តឹង ។

ការឆូត ការថែម និងការយោង ត្រូវតែមានបញ្ជាក់ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹង នៅរឹមទំព័រ ។

មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ អ្នកប្តឹងត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានខ្លឹមសារកំណត់ហេតុដោយសំលេងខ្លាំងៗ ។

## មាត្រា ៧៣. – បញ្ជីបណ្តឹង

នៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវតែមានបញ្ជីបណ្តឹងមួយ ។ នៅគ្រប់ពេលដែលមានការដាក់ពាក្យប្តឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះក្នុងបញ្ជីនូវនិទ្ទេសដូចតទៅ :

-អត្តសញ្ញាណរបស់អ្នកប្តឹង

-កាលបរិច្ឆេទនៃការដាក់ពាក្យប្តឹង

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹង

-ប្រភេទនៃអំពើដែលប្តឹង

-ចំណាត់ការលើបណ្តឹងដូចជាបញ្ជូនទៅព្រះរាជអាជ្ញា ឬក៏ផ្តើមធ្វើការស៊ើបអង្កេត ។

បញ្ជីបណ្តឹងត្រូវតែកាន់កាប់ជាអចិន្ត្រៃយ៍សម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ ។

## មាត្រា ៧៤. – ចំណាត់ការបន្តពីការដាក់ពាក្យប្តឹង

មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបណ្តឹងនោះ ត្រូវតែចាប់ផ្តើមភ្លាមៗ ធ្វើការស៊ើបអង្កេត ឬក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹងនោះ ទៅព្រះរាជអាជ្ញាដើម្បីចាត់ការតទៅ ។

មន្ត្រីនគរបាលយុត្តិធម៌ មុនធ្វើការស៊ើបអង្កេត អាចសុំសេចក្តីណែនាំពីព្រះរាជអាជ្ញា ។

កាលណាទទួលពាក្យប្តឹងបរិហារ ដែលមានបង្ហាញមូលហេតុជាក់ច្បាស់សមហេតុផល មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ ។

## មាត្រា ៧៥. – ការបំពានលើសកម្មភាពតុលាការ

ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុក

ឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬក៏មានការដកពាក្យប្ដឹងក៏ដោយ ។

មន្ត្រីនគរបាលយុត្តិធម៌ដែលរក្សាទុកកំណត់ហេតុ ឬវត្ថុតាងដោយចេតនា ឬក៏លាក់បំបាំងដល់អាជ្ញាធរតុលាការ អំពីអត្ថិភាពនៃកំណត់ហេតុ ឬវត្ថុតាង ត្រូវចាត់ទុកថា មន្ត្រីនគរបាលនោះបានប្រព្រឹត្តបទល្មើស ដែលត្រូវផ្ដន្ទាទោសតាមក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងជំពូកស្ដីពីការស្រាវជ្រាវរកភស្តុតាង ។

## ជំពូកទី ៣
## ភ្នាក់ងារនគរបាលយុត្តិធម៌

**មាត្រា ៧៦.** – ការទទួលបាននូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌

មានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ :

១-នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

២-ភ្នាក់ងារនគរបាលជាតិផ្សេងទៀត ។

៣-នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

៤-យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ ។

**មាត្រា ៧៧.** – សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់ ។ សម្បថនេះត្រូវធ្វើឡើងនៅចំពោះមុខសាលាដំបូង ។ សម្បថនេះពុំចាំបាច់ធ្វើឡើងវិញឡើយ នៅពេលដែលបានទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ នាពេលក្រោយទៀត ។ រូបមន្តសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៧៨.** – បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ មានបេសកកម្ម :

១-ពិនិត្យបទល្មើស ជាអាទិ៍ បទលហុ ។

២-ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់គេ ។

ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ធ្វើរបាយការណ៍ ។ របាយការណ៍នេះមានតំលៃត្រឹមតែព័ត៌មានធម្មតា ។

ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយ ដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌ ។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើការហាមឃាត់នេះត្រូវចាត់ទុកជាមោឃៈ ។

**មាត្រា ៧៩.** – កំហុសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលបំពេញមុខងារ

រាល់កំហុសទាំងឡាយ ដែលប្រព្រឹត្តដោយភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីចាប់ផ្ដើមនីតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្ដល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ ។

**មាត្រា ៨០.** – ទណ្ឌកម្មខាងវិន័យ

ទណ្ឌកម្មខាងវិន័យរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ មិនមែនជាឧបសគ្គដល់ការធ្វើបណ្ដឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

កាលណាភ្នាក់ងារនគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើស នៅក្នុងការបំពេញមុខងាររបស់ខ្លួន តុលាការកំពូលអាចផ្ទេរអំណាចឱ្យទៅយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ ។

ពាក្យសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ។

## ជំពូកទី ៤
## ការកំណត់សមត្ថកិច្ចរបស់នគរបាលជាតិ និងកងរាជអាវុធហត្ថ

**មាត្រា ៨១.** – ការកំណត់សមត្ថកិច្ច

ក្នុងវិស័យនគរបាលយុត្តិធម៌ នគរបាលជាតិ និងកងរាជអាវុធហត្ថ ត្រូវមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៥៦ (បេសកកម្មរបស់នគរបាលយុត្តិធម៌) នៃក្រមនេះ ។

លើសពីនេះទៅទៀត ចំពោះបទល្មើសយោធា មានតែកងរាជអាវុធហត្ថទេ ដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌ ។

កិច្ចប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការរវាងនាយនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ ក្នុងពេលបំពេញមុខងារជានគរបាលយុត្តិធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

អង្គភាពនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចថ្នាក់ជាតិ អាចត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ៥

## មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលមាននីតិសម្បទាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន

**មាត្រា ៨២.** – ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យពិនិត្យបទល្មើស ត្រូវដាក់ឱ្យស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ក្នុងពេលបំពេញមុខងារនេះ ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ ។

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់ ។ សម្បថត្រូវធ្វើនៅចំពោះមុខសាលាដំបូង ។ រូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ។

ចំពោះការពិនិត្យបទល្មើស មន្ត្រីរាជការ និងភ្នាក់ងារទាំងនេះធ្វើរបាយការណ៍ ។ របាយការណ៍នេះមានតំលៃត្រឹមតែព័ត៌មានធម្មតាប៉ុណ្ណោះ ។

រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រីឬភ្នាក់ងារនោះនៅក្រោមឱវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ ។ ទណ្ឌកម្មខាងវិន័យមិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត ។

## គន្ថីទី ៣
## ការស៊ើបអង្កេត
### មាតិកាទី ១
### បទប្បញ្ញត្តិទូទៅ
### ជំពូកតែមួយ
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៣.** – ការសម្ងាត់នៃការស៊ើបអង្កេត

ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់ ។ បុគ្គលទាំងឡាយ ដែលចូលរួមក្នុងការស៊ើបអង្កេត ជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និង បុគ្គលដែលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។

ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនមែនជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។

ម្យ៉ាងទៀត ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មាន ដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។

ការបំពានលើការសម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើស ដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៨៤.** – ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត

អំណាចទាំងឡាយ ដែលផ្តល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះបំពេញការក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ឬក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតជាបឋម ។

### មាតិកាទី ២
### ការស៊ើបអង្កេតករណីជាក់ស្តែង
### ជំពូកទី ១
### បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

**មាត្រា ៨៥.** – អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង

ក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែគោរពតាមបទប្បញ្ញត្តិនៃមាតិកានេះ ។

**មាត្រា ៨៦.** – និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ :

-បទល្មើសដែលកំពុងប្រព្រឹត្ត

-បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ។

ត្រូវចាត់ទុកថា ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក :

-ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រហឹង

-បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះ បានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

**មាត្រា ៨៧.** – ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

**មាត្រា ៨៨.** – ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ ។

## ជំពូកទី ២

## វិធានការស្រាវជ្រាវ

**មាត្រា ៨៩.** –វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ ។ មន្ត្រី

នគរបាលយុត្តិធម៌អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។

ប្រសិនបើយល់ឃើញថា មានប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត ។

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយ ដែលមានចែងក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ ។

**មាត្រា ៩០.** - កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។

**មាត្រា ៩១.** - ការឆែកឆេរ

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ ។ សាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ សាក្សីមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ លើកលែងតែ :

-ក្នុងករណីដែលមានចែងដោយមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-ក្នុងករណីដែលចែងដោយមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-ក្នុងករណីមានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង

-ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន

-ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលនៅក្នុងនោះមានចុះ :

-ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ

-អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន នៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី ។

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍បានតែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរី នូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ ។

**មាត្រា ៩២.** – ការបិទស្លាកបោះត្រាលើវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ ។

ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួចមន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់ ។ កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬផ្តិតស្រាមមេដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់ ។

**មាត្រា ៩៣.** – កំណត់ហេតុលើការស្តាប់ចម្លើយ

មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូប ដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្តាប់ចម្លើយជនទាំងនោះ ។

ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវដកស្រង់តាមដោយត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែដែលស្បថថា និយាយការពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន ។ អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាលកងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ ។

ទំព័រនីមួយៗ នៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬផ្តិតស្រាមមេដៃដោយបុគ្គលដែលបានឆ្លើយ ។

មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមមេដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ ។ មន្ត្រីនគរបាល

យុត្តិធម៌អាចហៅរកអ្នកបកប្រែបាន ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ៩៤.** – បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបាន ។

បុគ្គលដែលកោះហៅនោះ ត្រូវចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន ។ បញ្ជាឱ្យចូលខ្លួននេះត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។ បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួន ។ កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ៩៥.** – ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនេះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ ។

## ជំពូកទី ៣
## ការឃាត់ខ្លួន

**មាត្រា ៩៦.** – ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ។ ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។

ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ។ ការពន្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញា ដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព ។ ការអនុញ្ញាតឱ្យពន្យារពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ ការពន្យារគឺជាវិធានការពិសេស ។ ការពន្យារនេះមិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង ឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន ។

ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះ ជាអនីតិជន។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ៣៦ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ២៤ ម៉ោងឡើយ ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ៤៨ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ៣៦ ម៉ោងឡើយ ។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។

**មាត្រា ៩៧. – កំណត់ហេតុស្ដីពីការឃាត់ខ្លួន**

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងជាបន្ទាន់អំពីសេចក្ដីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឱ្យបានដឹងអំពីមូលហេតុនៃសេចក្ដីសម្រេចឃាត់ខ្លួននេះ ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់ដល់សាមីខ្លួនឱ្យបានដឹងផងដែរ អំពីសិទ្ធិដែលបានចែងនៅមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្ដីពីការឃាត់ខ្លួនជាបន្ទាន់ដោយមានចុះសេចក្ដីដូចតទៅ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមឃាត់ខ្លួន

**មាត្រា ១០១. – បញ្ជីនៃការឃាត់ខ្លួន**

នៅក្នុងកន្លែងនីមួយៗ របស់នគរបាល ឬកងរាជអាវុធហត្ថ ដែលសម្រាប់ទទួលជនដែលត្រូវឃាត់ខ្លួន ត្រូវមានបញ្ជីស្តីពីការឃាត់ខ្លួនមួយ ។

គ្រប់ការឃាត់ខ្លួនត្រូវមានចុះនៅក្នុងបញ្ជីដោយមានសេចក្តីដូចតទៅនេះ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យធ្វើការឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន ដោយថាហេតុ

-ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន ដោយថាហេតុ

-ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន ។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ ។

**មាត្រា ១០២. – កំណត់ហេតុសរុបនៃការឃាត់ខ្លួន**

គ្រប់ការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន ។

កំណត់ហេតុសរុបនេះត្រូវមានចុះនិទ្ទេសដូចតទៅ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមការឃាត់ខ្លួន

-បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា

-បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន) នៃក្រមនេះ

-ឈ្មោះគ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន

-អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាម មាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលដោយថាហេតុបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន

-ថិរវេលានៃការស្តាប់ចម្លើយនីមួយៗ និងថិរវេលានៃការសម្រាកដែលនៅចន្លោះការស្តាប់ចម្លើយនីមួយៗ

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន

-ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន

-លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ ។
កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង ។

## ជំពូកទី ៤
## ការបញ្ជូនខ្លួន

**មាត្រា ១០៣. – ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន**

នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវ :

-បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬ

-ដោះលែងឱ្យមានសេរីភាពឡើងវិញ ។

សេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា ។

**មាត្រា ១០៤. – រយៈពេលនៃការបញ្ជូនខ្លួន**

កាលណាបុគ្គលដែលត្រូវឃាត់ខ្លួន ត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា នោះបុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា ។

ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះ រយៈពេលបន្ថែមអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញាបាន ។

នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន ។

មូលហេតុនៃការយឺតយ៉ាវត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌ ។

## ជំពូកទី ៥
## វិធានទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង

**មាត្រា ១០៥. – ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍**

មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យស្តាប់ និងថតសំលេងការសន្ទនាតាមទូរស័ព្ទឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យចាប់ និងថតការផ្ញើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ ជាអាទិ៍ សារតាមទូរសារ ឬសារតាមអិនធើណែត ។

**មាត្រា ១០៦. – ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង**

ថិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង មិនអាចលើសពី ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តិបទល្មើស ។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលានេះ ។ ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ទៅព្រះរាជអាជ្ញា ។

**មាត្រា ១០៧. – ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា**

ក្រោយបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា ។

កាលណាបុគ្គលណាមួយត្រូវបញ្ជូនទៅព្រះរាជអាជ្ញា នោះការបញ្ជូនកំណត់ហេតុ និងវត្ថុតាងត្រូវធ្វើជាមួយការបញ្ជូនខ្លួនបុគ្គលនោះដែរ ។

**មាត្រា ១០៨. – និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ**

កំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនោះ

-កាលបរិច្ឆេទ ។

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ ។

ពាក្យឆូតលុប និងការយោងត្រូវមានបញ្ជាក់យល់ព្រម ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រ ។

កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬស្តីពីការឃាត់ខ្លួន ត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ ។

**មាត្រា ១០៩. – មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ**

វិធាន និងទម្រង់ការដែលបានបញ្ញត្តនៅមាត្រា :

-មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)

-មាត្រា ៩១ (ការឆែកឆេរ)

-មាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង)

-មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ)

-មាត្រា ៩៤ (បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង)

-មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)

-មាត្រា ៩៦ (ការឃាត់ខ្លួន)

-មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)

-មាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)

-មាត្រា ៩៩ (ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន)

-មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)

-មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)

-មាត្រា ១០៦ (ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង) និង

-មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនេះ ។

មានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនដូច្នេះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី ។

**មាត្រា ១១០.** - អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម

តាមគោលការណ៍កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរី តាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។

ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ។

## មាតិកាទី ៣
## ការស៊ើបអង្កេតបឋម
## ជំពូកទោល
## ការស៊ើបអង្កេតបឋម

**មាត្រា ១១១.** - ការបើកការស៊ើបអង្កេតបឋម

កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតជាបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា ។

**មាត្រា ១១២.** - វិធានដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម

បទប្បញ្ញត្តិនៃមាត្រា :

-មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)

-មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)

-មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯង ជាអាទិ៍)

-មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)

-មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនេះ ត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេតបឋម ។

### មាត្រា ១១៣. - ការឆែកឆេរ

កាលណាការស៊ើបអង្កេតជាបឋមនោះ ទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង ។

មន្ត្រីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដ ពីអ្នកកាន់កាប់ទីកន្លែង ។

ការយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ សរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង ។ ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ ។

ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញា ត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនេះ ។ ការឆែកឆេរ ត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា ។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរ នោះឡើយ ។ ការឆែកឆេរ មិនអាចផ្តើមមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយ ម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ ។

បទប្បញ្ញត្តិនៃមាត្រា ៩២ (ការបិទស្លាកបោះត្រា លើវត្ថុតាង) នៃក្រមនេះ ត្រូវយកមកអនុវត្តក្នុងការចាប់យកវត្ថុតាង ។

### មាត្រា ១១៤. - ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ ។

បុគ្គលដែលកោះហៅត្រូវតែចូលមកបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឱ្យចូលខ្លួន ។ បញ្ជាឱ្យចូលខ្លួននេះត្រូវមានចុះអត្តសញ្ញាណបុគ្គលពាក់ព័ន្ធ កាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រា ។

បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ប្រើប្រាស់កងកម្លាំងសាធារណៈ ដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន ។

**មាត្រា ១១៥. – កំណត់ហេតុស្រង់ចម្លើយ ការស៊ើបអង្កេតបឋម**

ការស្ដាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវដកស្រង់ដោយត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅអ្នកបកប្រែដែលបានស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវ ។ អ្នកបកប្រែមិនអាចត្រូវ បានជ្រើសរើសក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងរឿងជាមួយទេ ។

**មាត្រា ១១៦. – ការឃាត់ខ្លួនជនជាប់សង្ស័យ**

កាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ បទប្បញ្ញត្តិនៃជំពូកទី ៣ ស្ដីពី ការឃាត់ខ្លួន និងជំពូកទី ៤ ស្ដីពី ការបញ្ជូនខ្លួន នៃមាតិកាទី២ ស្ដីពី ការស៊ើបអង្កេតករណីជាក់ស្ដែង ក្នុងគន្ថីនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ១១៧. – មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ**

ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម វិធាន និងទម្រង់ការដែលចែងនៅក្នុងមាត្រា :

- -មាត្រា ៩៦ (ការឃាត់ខ្លួន)
- -មាត្រា ៩៧ (កំណត់ហេតុស្ដីពីការឃាត់ខ្លួន)
- -មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
- -មាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្ដាប់ដោយឯកឯង ជាអាទិ៍)
- -មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- -មាត្រា ១១៣ (ការឆែកឆេរ)
- -មាត្រា ១១៤ (ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម) នៃក្រមនេះ

មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នេះទេនាំឱ្យមានមោឃភាពនៃនីតិវិធី ។

**មាត្រា ១១៨. – អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម**

តាមគោលការណ៍ កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ ប៉ុន្តែ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរី តាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។

ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម ។

## មាតិកាទី ៤
## ការប្រគល់ឱ្យម្ចាស់ដើមវិញ នូវវត្ថុដែលចាប់យក ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត
## ជំពូកតែមួយ
## ការប្រគល់ឱ្យម្ចាស់ដើមវិញ នូវវត្ថុដែលចាប់យក ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត

### មាត្រា ១១៩. - អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុជូនម្ចាស់ដើមវិញ

ព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់ឱ្យប្រគល់វត្ថុដែលចាប់បាននៅក្នុងពេលស៊ើបអង្កេត ទៅម្ចាស់ដើមវិញ ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេនោះ ហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះ គ្មានការជំទាស់អ្វីប្រាកដប្រជាទេ ។

ប៉ុន្តែ វត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ មិនអាចប្រគល់ឱ្យវិញបានទេ ។ វត្ថុទាំងនោះត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញចោល ។

ក្នុងករណីមិនព្រមប្រគល់ឱ្យវិញទេ អ្នកប្តឹងអាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន ។

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា គ្មានសមត្ថកិច្ចក្នុងការប្រគល់ទេ កាលណាមានការចោទប្រកាន់ធ្វើឡើងនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា នៅតែមានសមត្ថកិច្ច កាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចលើកលែងចោទប្រកាន់ជាស្ថាពរ ។

### មាត្រា ១២០. - ការប្រគល់វត្ថុដែលរឹបអូសជូនម្ចាស់ដើមវិញ

កាលបើតុលាការដែលទទួលពាក្យប្តឹងបានចេញសេចក្តីសម្រេចមួយជាស្ថាពរ ហើយពុំបានសម្រេចសេចក្តីលើការប្រគល់វត្ថុដល់ម្ចាស់ដើមវិញទេ នោះព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ចទៅតាមករណីនីមួយៗ ដើម្បីសម្រេចដោយឯកឯង លើពាក្យសុំឱ្យមានការប្រគល់វត្ថុដល់ម្ចាស់ដើមវិញនេះ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះ ពុំមានការជំទាស់អ្វីជាប្រាកដប្រជាទេ ។

រដ្ឋសភា
ប៉ុស្តិ៍ លេខ...
ថ្ងៃទី... ឆ្នាំ... ម៉ោង...
បញ្ជូនទៅ...

# ព្រះរាជក្រម

នស/រកម/០៦១៣/០០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# វិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨
# មាត្រា៣៧២ និងមាត្រា៣៨២
# នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**មាត្រា មួយ.-**

មាត្រា២៤៧ (ដីកាដំណោះស្រាយ) មាត្រា៣៦៨ (រយៈពេលសម្រាប់ធ្វើបណ្ដឹងទាស់) មាត្រា៣៧២ (បណ្ដឹងទាស់ដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី) និងមាត្រា៣៨២ (រយៈពេលប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី) នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ២៤៧ថ្មី.- ដីកាដំណោះស្រាយ**

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះឬដីកាលើកលែងចោទប្រកាន់ ។

ប្រសិនបើយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ ៖

១- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ។

២- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ។

៣- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

៤- ករណីដែលបណ្ដឹងអាជ្ញារលត់ ។

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត ។

ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួររកឃើញថា មិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន ។

ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឲ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុនឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការនិងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន ។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មានឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ ។ បែបបទ និងនីតិវិធីនៃការប្តឹងឧទ្ធរណ៍នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា ៣៦៨ថ្មី.– រយៈពេលសម្រាប់ធ្វើបណ្តឹងទាស់**

បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ផ្តើមគិត ៖

- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ
- ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឲ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ ។ ពិរុទ្ធជនត្រូវចាត់ទុកថា បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាម

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

បទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

## មាត្រា ៣៧២ថ្មី.– បណ្ដឹងទាស់ដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចប្ដឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខខ្លួនបានដែរ ។ បណ្ដឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ ។

បណ្ដឹងទាស់ត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតពី ៖

- ថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្ដឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់ដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ ។ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

បណ្ដឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។

ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឲ្យប្ដឹងទាស់ ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកទៅអនុវត្តលើបុគ្គលដែលតុលាការប្រកាសថា ត្រូវទទួលខុសត្រូវរដ្ឋប្បវេណីផងដែរ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

Ksl

**មាត្រា ៣៨២ថ្មី.- រយៈពេលប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើម្បីបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ការប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល១ (មួយ) ខែ ។

កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលប្រកាសសាលក្រម ។

កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ។

កាលណាសាលក្រមនោះជាសាលក្រមកំបាំងមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលផុតកំណត់ប្ដឹងទាស់ ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម/០៦១៣/០០៧

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីគោរពជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អង្គ វង្ស វឌ្ឍនា

លេខ: ៥៩៣ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រី

សយ សុខា

# ច្បាប់
# ស្តីពី
# ការប្រឆាំងអំពើពុករលួយ

# ព្រះរាជក្រម

នស/រកម/០៤១០/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១១០/០០៣/២០១០ កបធ.ច ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១០ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.– គោលបំណង**

ច្បាប់នេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពសេវាគ្រប់បែបយ៉ាង ពង្រឹងអភិបាលកិច្ច និង នីតិរដ្ឋនៅក្នុងការដឹកនាំនិងការគ្រប់គ្រងរដ្ឋ ព្រមទាំងរក្សាភាពស្អាតស្អំ និង យុត្តិធម៌ដែលជាមូលដ្ឋានចាំបាច់ក្នុងការអភិវឌ្ឍសង្គមជាតិ និង កាត់បន្ថយភាពក្រីក្រ ។

**មាត្រា ២.– គោលដៅ**

ច្បាប់នេះ មានគោលដៅប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ តាមរយៈការចាត់វិធានការអប់រំ បង្ការទប់ស្កាត់ និង អនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ ហើយដោយមានការចូលរួម និង គាំទ្រពីមហាជននិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៣.– វិសាលភាព**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និង គ្រប់ជាន់ថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលបានប្រព្រឹត្តក្រោយពេលដែលច្បាប់នេះមានអានុភាពអនុវត្ត ។

**មាត្រា ៤.– និយមន័យ**

វាក្យសព្ទបច្ចេកទេសក្នុងច្បាប់នេះមានន័យដូចតទៅ :

១- **បទល្មើសពុករលួយ** មានន័យថា បទល្មើសព្រហ្មទណ្ឌដែលមានចែងនៅក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

២- **អ្នករាជការសាធារណៈ**: មានន័យថា :

ក- បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការ ដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬ ជាបណ្តោះអាសន្នក្តី ទោះជាបាន ឬ មិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ និងអាយុរបស់បុគ្គលនោះឡើយ ។

ខ- បុគ្គលឯទៀតដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬ សហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

៣- **មន្ត្រីសាធារណៈបរទេស** មានន័យថា មន្ត្រីបរទេសដែលកាន់តំណែងក្នុងស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ ស្ថាប័នតុលាការរបស់ប្រទេសក្រៅទោះជាបានតែងតាំង ឬ បោះឆ្នោតជ្រើសរើសក៏ដោយ និង ជនបរទេសដែលអនុវត្តមុខងារសាធារណៈសម្រាប់ប្រទេសក្រៅណាមួយ រួមមានទីភ្នាក់ងារសាធារណៈ ឬ សហគ្រាសសាធារណៈ ។

៤- **មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ** មានន័យថា មន្ត្រីអន្តរជាតិ ឬ ជនណាដែលទទួលបានការអនុញ្ញាតពីអង្គការអន្តរជាតិឱ្យបំពេញភារកិច្ច ក្នុងនាមអង្គការអន្តរជាតិនោះ ។

៥- **ពលរដ្ឋឧទ្ទលអាណត្តិសាធារណៈដោយការបោះឆ្នោត** មានន័យថា សមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និង សមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

៦- **ចៅក្រម** មានន័យថា ចៅក្រមអាសនៈ និង ចៅក្រមអយ្យការ ។

៧- **នីតិបុគ្គល** មានន័យថា ក្រុមមនុស្ស ឬ មូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច ។

៨- **សង្គមស៊ីវិល** មានន័យថា សហគមន៍ ឬ ក្រុមមនុស្សដែលបង្កើតឡើងដើម្បីធ្វើសកម្មភាពក្នុងការការពារផលប្រយោជន៍លើវិស័យសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ វិទ្យាសាស្ត្រ វប្បធម៌ និង សាសនា មានជាអាទិ៍ សមាគម អង្គការក្រៅរដ្ឋាភិបាល គណបក្សនយោបាយ ។

៩- **អត្ថប្រយោជន៍** មានន័យថា :

ក-អំណោយអ្វីមួយ កម្ចី តម្លៃឈ្នួល រង្វាន់ ឬ កម្រៃជើងសាដែលមិនមានការអនុញ្ញាតដោយច្បាប់ជាធរមាន ជាទឹកប្រាក់ ឬ ជាវត្ថុមានតម្លៃ ឬ ជាទ្រព្យសម្បត្តិប្រភេទអ្វីមួយ ។

ខ- ការងារ តំណែង មុខងារ កិច្ចព្រមព្រៀង ឬ កិច្ចសន្យាអ្វីមួយ ។

គ- ការបង់ប្រាក់ ការលើកលែង ការលុបចោល ការលុបបំបាត់នូវប្រាក់កម្ចីអ្វីមួយ កាតព្វកិច្ច ឬ បំណុលផ្សេងទៀត ទោះជាទាំងមូលក្តី ឬ ដោយផ្នែកក្តី ។

ឃ- សេវាកម្មផ្សេងទៀត ឬ ការផ្តល់ជាគុណប្រយោជន៍ រួមទាំងកិច្ចការពារមិនឱ្យមានការដាក់ទណ្ឌកម្ម ដែលលេចចេញពីអំពើ ឬ ដំណើរការនៃការដាក់ទណ្ឌកម្មរដ្ឋបាល ឬ ព្រហ្មទណ្ឌ ទោះបីទណ្ឌកម្មនេះ ត្រូវបានកំណត់ ឬ ពុំទាន់ត្រូវបានកំណត់ក៏ដោយ ។

ង- ការអនុវត្ត ឬ ការរារាំងមិនឱ្យអនុវត្តនូវសិទ្ធិ ឬ អំណាច ឬ ភារកិច្ចអ្វីមួយ ។

ច-ការស្នើជូន ឬ ការសន្យាថាជូន ទោះបីមានលក្ខខណ្ឌ ឬ គ្មានលក្ខខណ្ឌក្តី នូវអត្ថប្រយោជន៍ ដូចមានចែងក្នុងស្មារតីនៃកថាខណ្ឌ (ក) (ខ) (គ) (ឃ) និង(ង) ។

១០- **អំណោយ** មានន័យថា ទ្រព្យ ឬ សេវាដែលត្រូវបានផ្តល់ឱ្យ ទៅបុគ្គលណាម្នាក់ ឬ ដើម្បីជាប្រយោជន៍ដល់បុគ្គលណាម្នាក់ ហើយដែលមិនត្រូវបានចាត់ទុកជាកិច្ចព្រមព្រៀង និង មិនមែនជាជំនូនតាមទំនៀមទម្លាប់ ឬ ប្រពៃណី ។

១១- **ទំនាស់ផលប្រយោជន៍** មានន័យថា ផលប្រយោជន៍ជាទឹកប្រាក់ ផលប្រយោជន៍នយោបាយ ផលប្រយោជន៍សម្រាប់គ្រួសារ ឬ ផលប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចមានឥទ្ធិពលលើចង្វើរបស់ជនណាម្នាក់ ក្នុងការអនុវត្តកាតព្វកិច្ចជាផ្លូវការរបស់ខ្លួន ។

១២- **ទ្រព្យសម្បត្តិ** មានន័យថា ទ្រព្យគ្រប់ប្រភេទ ទោះជាចលនវត្ថុ ឬ ជាអចលនវត្ថុ រូបីយ ឬ អរូបីយ និង ឯកសារគតិយុត្ត ឬ លិខិតូបករណ៍ដែលបញ្ជាក់ពីកម្មសិទ្ធិ ឬ ផលប្រយោជន៍នៅក្នុងទ្រព្យសម្បត្តិនោះ ។

១៣- **ការចាប់យក** មានន័យថា ការហាមឃាត់ជាបណ្តោះអាសន្នមិនឱ្យធ្វើការផ្ទេរ ផ្លាស់ប្តូរ ប្រែប្រួល ប្រគល់ឱ្យ ឬ ធ្វើចលនានៃទ្រព្យសម្បត្តិ ឬ យកធ្វើជាទ្រព្យសម្បត្តិបណ្តោះអាសន្ន ឬ គ្រប់គ្រងទ្រព្យសម្បត្តិ តាមរយៈដីកាតុលាការ ។

១៤- **ការរឹបអូស** មានន័យថា ការដកហូតជាអចិន្ត្រៃយ៍នូវទ្រព្យសម្បត្តិណាមួយ តាមរយៈសេចក្តីសម្រេចរបស់តុលាការ ។

១៥- **ផលនៃអំពើពុករលួយ** មានន័យថា ទ្រព្យណាក៏ដោយដែលបានមកពី ឬ ទទួលបានដោយផ្ទាល់ ឬ ដោយប្រយោល តាមរយៈការប្រព្រឹត្តអំពើពុករលួយ ។

១៦- **កម្រៃ** មានន័យថា ផលជាប្រាក់បានមកអំពីកិច្ចការការិយាល័យ ឋានៈ មុខងារ ឬ ការងារ ដែលរួមទាំងប្រាក់បៀវត្ស ប្រាក់ឈ្នួល និង ប្រាក់បន្ថែមឯទៀត ។

១៧- **ការប៉ុនប៉ង** មានន័យថា ការប្រព្រឹត្តអំពើពុករលួយដែលអាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះ ត្រូវបានបំពេញ :

ក- ចារីបានចាប់ផ្តើមប្រព្រឹត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស និង

ខ- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្តតែត្រូវបានរាំងស្ទះ ឬ រាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។ អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្តើមប្រព្រឹត្តទេ ។

១៨- **អ្នកផ្តើមគំនិត** មានន័យថា បុគ្គលណាដែល :

ក- ជម្រុញឱ្យប្រព្រឹត្តបទល្មើសពុករលួយតាមការណែនាំ ឬ បញ្ជា ។

ខ- បង្កឱ្យមានបទល្មើសពុករលួយ ដោយផ្តល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន ។

១៩- **អ្នកសមគំនិត** មានន័យថា បុគ្គលដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬ ការសម្រេចបទល្មើសពុករលួយដោយផ្តល់ជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន ។

២០- **អង្គភាពដើមប្រឆាំងអំពើពុករលួយ** មានន័យថា អង្គភាពប្រឆាំងអំពើពុករលួយដែលត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៦ ។

## ជំពូកទី ២

## ស្ថាប័នប្រឆាំងអំពើពុករលួយ

**មាត្រា ៥.- ស្ថាប័នប្រឆាំងអំពើពុករលួយ**

ស្ថាប័នប្រឆាំងអំពើពុករលួយរួមមានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង

អង្គភាពប្រឆាំងអំពើពុករលួយ ។

ស្ថាប័នប្រឆាំងអំពើពុករលួយមានរូបសញ្ញា និង ត្រាសម្រាប់ប្រើប្រាស់ក្នុងដំណើរការការងាររបស់ខ្លួនដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី ១
## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

**មាត្រា ៦.- ការបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ដែលមានតួនាទីពិគ្រោះយោបល់ និង ផ្តល់អនុសាសន៍លើការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ។ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមានសមាជិក ១១ (ដប់មួយ) រូប ដែលមានសមាសភាពដូចខាងក្រោម :

១- ឥស្សរជន ១ (មួយ) រូប តែងតាំងដោយព្រះមហាក្សត្រ ។

២- ឥស្សរជន ១ (មួយ) រូប ជ្រើសតាំងដោយព្រឹទ្ធសភា តាមសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

៣- ឥស្សរជន ១ (មួយ) រូប ជ្រើសតាំងដោយរដ្ឋសភា តាមសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

៤- ឥស្សរជន ១ (មួយ) រូប ជ្រើសតាំងចេញពីរាជរដ្ឋាភិបាល ។

៥- ឥស្សរជន ១ (មួយ) រូប ជ្រើសតាំងដោយ ឬ ចេញពីអាជ្ញាធរសវនកម្មជាតិ ។

៦- ឥស្សរជន ១ (មួយ) រូប ជ្រើសតាំងដោយ ឬ ចេញពីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច ។

៧- ឥស្សរជន ១ (មួយ) រូប ជ្រើសតាំងដោយ ឬ ចេញពីក្រុមប្រឹក្សាអ្នកច្បាប់ ។

៨- ឥស្សរជន ១ (មួយ) រូប ជ្រើសតាំងដោយ ឬ ចេញពីក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ។

៩- ឥស្សរជន ១ (មួយ) រូប ជ្រើសតាំងដោយ ឬ ចេញពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ROYAUME DU CAMBODGE CABINET DU PALAIS ROYAL

១០-តំណាងអ្នកប្រជុំជន ១ (មួយ) រូប ជ្រើសតាំងចេញពីគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ។

១១- ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ។

សមាជិកនីមួយៗ នៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ត្រូវមានលក្ខណសម្បត្តិដូចតទៅ :

- មានសញ្ជាតិខ្មែរពីកំណើត
- មានសីលធម៌ល្អ និង មានកេរ្តិ៍ឈ្មោះស្អាតស្អំ
- មិនដែលមានទោសមជ្ឈិម ឬ ឧក្រិដ្ឋ ឬ មិនមានក្ស័យធន
- មានសញ្ញាបត្រចាប់ពីឧត្តមសិក្សាឡើងទៅ
- មានបទពិសោធន៍ការងារក្នុងសង្គមយ៉ាងតិច ១០ (ដប់) ឆ្នាំ
- មានអាយុយ៉ាងតិច ៤៥ (សែសិបប្រាំ) ឆ្នាំ ។

**មាត្រា ៧.- អាណត្តិ ការដកចេញពីតំណែង និង ការជំនួសតំណែង**

សមាជិកទាំងអស់នៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ។ អាណត្តិនេះអាចត្រូវបន្តជាថ្មី ។

ក្នុងករណីសមាជិកណាម្នាក់នៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ទទួលមរណភាព លាលែងចេញពីតំណែង ឬ ត្រូវបានបណ្តេញចេញពីមុខតំណែង ឬ មិនអាចបំពេញមុខតំណែងរបស់ខ្លួនបានដោយប្រការណាមួយចាប់ពី ៦ (ប្រាំមួយ) ខែឡើងទៅមុនពេលបញ្ចប់អាណត្តិ សមាជិកថ្មីត្រូវបានតែងតាំងជំនួស ។

តំណែងរបស់សមាជិកនៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយណាក៏ដោយ នឹងត្រូវបញ្ចប់ជាស្វ័យប្រវត្តិនៅពេលដែលតុលាការសម្រេចថា សមាជិកនោះមានទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋណាមួយ ។

ក្នុងករណីទាំងឡាយខាងលើនេះ ប្រធានត្រូវកោះប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ដើម្បីសម្រេច និង ចាត់វិធានការសមស្របពាក់ព័ន្ធនឹងការបញ្ចប់តំណែង ការដកចេញពីតំណែង ព្រមទាំងការជ្រើសតាំងតំណាងអ្នកប្រជុំជនជំនួស ស្របតាមមាត្រា ៦ (ការបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ) នៃច្បាប់នេះ ។

Kol

**មាត្រា ៨._ ការជ្រើសតាំងប្រធាន និង អនុប្រធាន**

ប្រធាន និង អនុប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយត្រូវជ្រើសតាំងដោយការបោះឆ្នោតពីសមាជិករបស់ខ្លួនតាមសំឡេងភាគច្រើនដាច់ខាត ដែលត្រូវធ្វើឡើងក្នុងសម័យប្រជុំលើកទី ១ តាមការកោះអញ្ជើញរបស់សមាជិក ដែលមានវ័យចាស់ជាងគេ ។ ក្នុងករណីបោះឆ្នោតលើកទី ១ ពុំបានសម្រេច ការបោះឆ្នោតលើកទី ២ ត្រូវយកមតិភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយអវត្តមាន ឬ មិនអាចបំពេញភារកិច្ចបាន អនុប្រធានបំពេញភារកិច្ចជំនួស ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយមិនអាចឈរឈ្មោះជាប្រធាន ឬ អនុប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយបានឡើយ ។

**មាត្រា ៩._ ឋានៈរបស់សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**

សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមានឋានៈ ដូចខាងក្រោម :

- ប្រធាន មានឋានៈស្មើឧបនាយករដ្ឋមន្ត្រី
- អនុប្រធាន មានឋានៈស្មើទេសរដ្ឋមន្ត្រី
- សមាជិក មានឋានៈស្មើរដ្ឋមន្ត្រី ។

**មាត្រា ១០._ ភារកិច្ចរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**

ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមានភារកិច្ចដូចតទៅ :

- កសាងយុទ្ធសាស្ត្រ និង នយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ពិគ្រោះយោបល់ និង ផ្តល់អនុសាសន៍ដល់អង្គភាពប្រឆាំងអំពើពុករលួយពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ឃ្លាំមើលដំណើរការការងារនៃអង្គភាពប្រឆាំងអំពើពុករលួយ
- ស្នើអង្គភាពប្រឆាំងអំពើពុករលួយឱ្យរាយការណ៍ ឬ បំភ្លឺ
- ធ្វើរបាយការណ៍ជូននាយករដ្ឋមន្ត្រី អំពីដំណើរការរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើរបាយការណ៍ប្រចាំឆមាស និង ប្រចាំឆ្នាំជូននាយករដ្ឋមន្ត្រី
- រៀបចំ និង អនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

Kol

## ផ្នែកទី ២

## អង្គភាពប្រឆាំងអំពើពុករលួយ

### មាត្រា ១១.- ការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ

ត្រូវបានបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ដែលមានឯករាជ្យភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

អង្គភាពប្រឆាំងអំពើពុករលួយដឹកនាំដោយប្រធាន ១ (មួយ) រូប មានឋានៈស្មើទេសរដ្ឋមន្ត្រី និង អនុប្រធានមួយចំនួនមានឋានៈស្មើរដ្ឋមន្ត្រីជាជំនួយការតាមការចាំបាច់ ។

ប្រធាន និង អនុប្រធានត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ១២.- លក្ខណសម្បត្តិនៃប្រធាន និង អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

ប្រធាន និង អនុប្រធានត្រូវមានលក្ខណសម្បត្តិដូចតទៅ :

- មានសញ្ជាតិខ្មែរពីកំណើត
- មានសីលធម៌ល្អ និង កេរ្តិ៍ឈ្មោះស្អាតស្អំ
- មិនដែលមានទោសមជ្ឈិម ឬ ឧក្រិដ្ឋ ឬ មិនមានក្ស័យធន
- មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ
- មានបទពិសោធន៍ការងារក្នុងសង្គមយ៉ាងតិច ៧ (ប្រាំពីរ) ឆ្នាំ
- មានអាយុយ៉ាងតិច ៣៥ (សាមសិបប្រាំ) ឆ្នាំ ។

### មាត្រា ១៣.- ភារកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ

អង្គភាពប្រឆាំងអំពើពុករលួយមានភារកិច្ចដូចខាងក្រោម :

- អនុវត្តច្បាប់ បទបញ្ញា និង បទប្បញ្ញត្តិពាក់ព័ន្ធនឹងបទល្មើសពុករលួយជា

- រៀបចំកសាងផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើពុករលួយស្របតាមយុទ្ធសាស្ត្រ និង នយោបាយរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

- ដឹកនាំការងារទប់ស្កាត់ និង បង្ក្រាបអំពើពុករលួយ

- តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ និង ធ្វើការសិក្សាស្រាវជ្រាវព្រមទាំងលើកវិធានការនានា ពាក់ព័ន្ធនឹងបទល្មើសពុករលួយនៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈ និង ឯកជនទាំងអស់ស្របតាមនីតិវិធីជាធរមាន

- ទទួល និង ពិនិត្យរាល់ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងអំពើពុករលួយព្រមទាំងចាត់ការទៅតាមនីតិវិធីជាធរមាន

- ស្វែងរក ពិនិត្យ និង រៀបចំឯកសារ និង ព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ

- រក្សាការសម្ងាត់ជាដាច់ខាតចំពោះប្រភពព័ត៌មានទាក់ទងនឹងអំពើពុករលួយ

- ចាត់វិធានការចាំបាច់ដើម្បីរក្សាសន្តិសុខដល់បុគ្គលដែលផ្តល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ

- ធ្វើការគ្រប់គ្រងប្រព័ន្ធការប្រកាសទ្រព្យសម្បត្តិ និង បំណុលដូចមានបញ្ញត្តក្នុងច្បាប់នេះ

- ដឹកនាំការងារឃោសនាអប់រំមហាជនអំពីផលវិបាកនៃអំពើពុករលួយ និង លើកទឹកចិត្តឱ្យមហាជនចូលរួមក្នុងការបង្ការទប់ស្កាត់ និង កម្ចាត់អំពើពុករលួយ

- ពិនិត្យ និង លើកគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងរបស់អង្គភាពប្រឆាំងអំពើពុករលួយ

- ទទួលឆ្លើយបំភ្លឺដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរចំពោះរាល់សំណួរដែលលើកឡើងដោយសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ឬ សមាជិករដ្ឋសភា

- បម្រើសេវាការងារជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

- តែងតាំង ផ្លាស់ប្តូរ និង គ្រប់គ្រង ឬ លើកសំណើតែងតាំង ផ្លាស់ប្តូរ មន្ត្រីរាជការក្រោមឱវាទក្នុងអង្គភាពប្រឆាំងអំពើពុករលួយ

- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការតំបន់ អង្គការអន្តរជាតិ និង ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយឆ្លងដែន

- ផ្ញើរបាយការណ៍អំពីសកម្មភាពទាំងឡាយរបស់អង្គភាពប្រឆាំងអំពើពុករលួយ ជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

- មានសិទ្ធិធ្វើការព្រមានចំពោះមុខសញ្ញាដែលក្នុងដំណាក់កាលដំបូងមានការខកខានមិនបានអនុវត្តច្បាប់ និង បទប្បញ្ញត្តិជាធរមាន ក្នុងគោលដៅបង្ការនិងទប់ស្កាត់អំពើពុករលួយ ។

## មាត្រា ១៤.– មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ

មន្ត្រីបម្រើការងារនៅក្នុងអង្គភាពប្រឆាំងអំពើពុករលួយរួមមាន មន្ត្រីរាជការដែលត្រូវបានតែងតាំង ឬ ផ្ទេរ ឬ បញ្ជូនមកបម្រើការងារក្នុងអង្គភាព និង មន្ត្រីដែលត្រូវបានជ្រើសរើសឱ្យមកបម្រើការងារតាមកិច្ចសន្យា ។ មន្ត្រីទាំងអស់ខាងលើនេះត្រូវគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និង លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធដទៃទៀតជាធរមាន ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចជ្រើសរើសអ្នកជំនាញការ អ្នកឯកទេស និង អ្នកស្រាវជ្រាវជាតិ អន្តរជាតិ ជាប់កិច្ចសន្យា ឬ ដោយស្ម័គ្រចិត្តឱ្យមកជួយផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធការប្រឆាំងអំពើពុករលួយ។

## មាត្រា ១៥.– បណ្តាញនៃអង្គភាពប្រឆាំងអំពើពុករលួយ

អង្គភាពប្រឆាំងអំពើពុករលួយ អាចមានការិយាល័យរបស់ខ្លួននៅគ្រប់រាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើជាបណ្តាញការងាររបស់ខ្លួន ។

ការិយាល័យប្រឆាំងអំពើពុករលួយ អនុវត្តការងាររបស់ខ្លួនក្រោមការដឹកនាំរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ។ ការិយាល័យប្រឆាំងអំពើពុករលួយដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

# ជំពូកទី ៣

# ថវិកា និង ធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

## មាត្រា ១៦.– ថវិកា និង ធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

ស្ថាប័នប្រឆាំងអំពើពុករលួយមានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើរការដែល

ស្ថិតនៅក្នុងកញ្ចប់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ ស្ថាប័នប្រឆាំងអំពើពុករលួយទទួលធនធានចាំបាច់នានាពីរាជរដ្ឋាភិបាលនិងមានសិទ្ធិទទួលនូវអំណោយ ឬ ជំនួយពីអង្គការជាតិ អន្តរជាតិនានា ។ ស្ថាប័នប្រឆាំងអំពើពុករលួយមិនត្រូវទទួលជំនួយណាដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយជាអាណាប័កទទួលសិទ្ធិ ។

ការគ្រប់គ្រង និង ចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤

## ការប្រកាសទ្រព្យសម្បត្តិ និង បំណុល

### មាត្រា ១៧.– សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល

ក្នុងពេលចូលកាន់មុខតំណែង និង ក្នុងពេលចេញពីមុខតំណែងបុគ្គលដូចខាងក្រោមនេះ ត្រូវប្រកាសទ្រព្យសម្បត្តិរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ឬ ជាទម្រង់អេឡិចត្រូនិកទោះជាទ្រព្យសម្បត្តិនោះនៅក្រៅប្រទេសក្តី ឬ ក្នុងប្រទេសក្តី រួមទាំងបំណុលផង ហើយដាក់ជូនអង្គភាពប្រឆាំងអំពើពុករលួយដោយសាមីខ្លួនផ្ទាល់ :

១- សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និង សមាជិករាជរដ្ឋាភិបាល ។

២- មន្ត្រីសាធារណៈដែលមានអាណត្តិជ្រើសតាំង ។

៣- សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធាន អនុប្រធាន និង មន្ត្រីទាំងអស់នៃអង្គភាពប្រឆាំងអំពើពុករលួយ ។

៤- មន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និង អ្នករាជការសាធារណៈផ្សេងទៀតដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ។

៥- មន្ត្រីផ្សេងទៀតដែលតែងតាំងដោយប្រកាសហើយត្រូវបានកំណត់ឱ្យប្រកាសទ្រព្យសម្បត្តិ និង បំណុលតាមបញ្ជីដែលរៀបចំឡើងដោយអង្គភាពប្រឆាំងអំពើពុករលួយ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ។

៦- ចៅក្រមអាសនៈ ចៅក្រមអយ្យការ សារការី ក្រឡាបញ្ជី និង អាជ្ញាសាលា ។

៧- ថ្នាក់ដឹកនាំនៃសង្គមស៊ីវិល ។

**មាត្រា ១៨._ របបប្រកាសទ្រព្យសម្បត្តិ និង បំណុល**

មន្ត្រីដូចមានចែងក្នុងមាត្រា ១៧ (សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) ខាងលើនេះ ត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុលរបស់ខ្លួនរៀងរាល់ ២ (ពីរ) ឆ្នាំម្តង នៅដើមខែមករា ហើយមិនឱ្យហួសពីថ្ងៃទី ៣១ ខែមករាឡើយ ។ ការប្រកាសទ្រព្យសម្បត្តិ និង បំណុលលើកដំបូងត្រូវអនុវត្តធ្វើ ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ ក្រោយពេលចូលកាន់មុខតំណែង ។ ចំណែកការប្រកាសទ្រព្យសម្បត្តិ និង បំណុលលើកទីពីរ ត្រូវធ្វើនៅខែ មករា ឆ្នាំទី ៣ នៃការកាន់មុខតំណែង ហើយការប្រកាស់ទ្រព្យសម្បត្តិ និង បំណុលចុងក្រោយត្រូវធ្វើ ៣០ (សាមសិប) ថ្ងៃយ៉ាងយូរមុនពេលចាកចេញពីមុខតំណែង ។ ក្នុងករណីមិនអាចធ្វើការប្រកាសមុនពេលចាកចេញពីមុខតំណែងបានដោយមូលហេតុមានការដកហូតមុខតំណែង ត្រូវប្រកាសយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ក្រោយការចាកចេញពីមុខតំណែង។

ចំពោះបុគ្គលដែលមានសមាសភាពដូចមានចែងក្នុងមាត្រា ១៧ (សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) ដែលកំពុងបំពេញមុខតំណែងត្រូវធ្វើការប្រ-កាសទ្រព្យសម្បត្តិ និង បំណុលលើកដំបូងក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ បន្ទាប់ពីស្ថាប័នប្រឆាំងអំពើពុករលួយបានបង្កើតឡើងដូចមានចែងក្នុងមាត្រា ៥៤ (ការរៀបចំដំណើរការរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង អង្គភាពប្រឆាំងអំពើពុករលួយ) នៃច្បាប់នេះ ។

ទម្រង់បែបបទ និង នីតិវិធីនៃការប្រកាសទ្រព្យសម្បត្តិ និង បំណុលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អង្គភាពប្រឆាំងអំពើពុករលួយ ។

**មាត្រា ១៩._ ជនផ្សេងទៀតដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល**

ក្រោយពីត្រូវបានស៊ើបអង្កេត និង ទទួលសេចក្តីសម្រេចពីអង្គភាពប្រឆាំងអំពើពុករលួយ ជនដែលមានការពាក់ព័ន្ធនឹងអំពើពុករលួយត្រូវធ្វើការប្រកាសទ្រព្យសម្បត្តិ និង បំណុលរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ឬ ជាទម្រង់អេឡិចត្រូនិក ទោះបីជននោះពុំមានឈ្មោះក្នុងបញ្ជីប្រកាសទ្រព្យសម្បត្តិ និង បំណុលដូចមានចែងក្នុងមាត្រា ១៧ (សមាសភាព

បុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) និង មាត្រា ១៨ (របបប្រកាសទ្រព្យសម្បត្តិនិងបំណុល) នៃច្បាប់នេះក៏ដោយ។

ការប្រកាសទ្រព្យសម្បត្តិ និង បំណុលរបស់ជនដែលជាប់ពាក់ព័ន្ធខាងលើនេះត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងមាត្រា ១៨ (របបប្រកាសទ្រព្យសម្បត្តិ និង បំណុល) នៃច្បាប់នេះរហូតពេលដែលអស់មានការចាំបាច់ ។

**មាត្រា ២០._ ការរក្សាទុកឯកសារប្រកាសទ្រព្យសម្បត្តិ និង បំណុល**

សំណុំឯកសារផ្ទាល់ខ្លួនម្នាក់ៗនៃអ្នកប្រកាសទ្រព្យសម្បត្តិ និង បំណុលត្រូវទុកជាការសម្ងាត់ខ្ពស់បំផុត និង ធ្វើជាទម្រង់អេឡិចត្រូនិកដោយមានលេខសម្ងាត់ ឬ ធ្វើជាលិខិតជាពីរច្បាប់តាមគំរូដែលកំណត់ដោយអង្គភាពប្រឆាំងអំពើពុករលួយ ហើយដាក់ក្នុងស្រោមសំបុត្រពីរដាច់ដោយឡែកពីគ្នា ដែលមួយច្បាប់រក្សាទុកដោយសាមីខ្លួន និង មួយច្បាប់ទៀតរក្សាទុកនៅអង្គភាពប្រឆាំងអំពើពុករលួយ ។ លើមាត់ស្រោមសំបុត្រដែលបិទជិតត្រូវប្រថាប់ត្រា និង ចុះហត្ថលេខាដោយប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ឬ តំណាងព្រមទាំងមានផ្តិតម្រាមដៃសាមីខ្លួនផង ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចធ្វើការសម្រេចបើកស្រោមសំបុត្រ ឬ បើកមើលឯកសារអេឡិចត្រូនិកខាងលើដើម្បីបុព្វហេតុនៃការស៊ើបអង្កេតតាមការចាំបាច់ ។

អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវរក្សាសំណុំឯកសារប្រកាសទ្រព្យសម្បត្តិ និង បំណុល ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ ចាប់ពីពេលទទួលសំណុំឯកសារ ។

នីតិវិធីក្នុងការបើកស្រោមសំបុត្រ ឬ បើកមើលឯកសារអេឡិចត្រូនិកប្រកាសទ្រព្យសម្បត្តិ និង បំណុលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អង្គភាពប្រឆាំងអំពើពុករលួយ ។

## ជំពូកទី ៥

## នីតិវិធីអនុវត្តចំពោះបទល្មើសពុករលួយ និង អាជ្ញាធរមានសមត្ថកិច្ច

**មាត្រា ២១._ នីតិវិធីសម្រាប់អនុវត្តចំពោះបទល្មើសពុករលួយ**

នីតិវិធីសម្រាប់អនុវត្តចំពោះបទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL •

Kol

និង បទល្មើសពុករលួយដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាពុំមានចែងនីតិវិធីដោយឡែកនៅក្នុងច្បាប់នេះទេ។

**មាត្រា ២២._ មន្ត្រីមានសមត្ថកិច្ចនៅក្នុងការស៊ើបអង្កេតបទល្មើសពុករលួយ**

ប្រធាន អនុប្រធាន និង មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចស៊ើបអង្កេតលើបទល្មើសពុករលួយដែលមានចែងនៅក្នុងច្បាប់នេះ និង បទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ។

អង្គភាពផ្សេងទៀតដែលបានដឹងអំពីបទល្មើសពុករលួយទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ និងបទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌត្រូវប្តឹងទៅអង្គភាព ឬ ការិយាល័យរាជធានី-ខេត្ត ប្រឆាំងអំពើពុករលួយអំពីរឿងហេតុនៃបទល្មើសទាំងនេះ។

**មាត្រា ២៣._ ការផ្តល់នីតិសម្បទាចំពោះមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ**

ប្រធាន និង អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដោយពេញច្បាប់ ដើម្បីបំពេញមុខងាររបស់ខ្លួន ។

មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយអាចទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយមានភារកិច្ចរៀបចំបញ្ជីឈ្មោះមន្ត្រី នៃអង្គភាពប្រឆាំងអំពើពុករលួយដែលត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២៤._ សម្បថ**

ប្រធាន អនុប្រធាន និង មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្បថថាបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់តាមល័ក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៦៣ (សម្បថនៃមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

Kol

**មាត្រា ២៥.‒ អំណាចស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ**

មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបអង្កេតបទល្មើសពុករលួយ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និង បទប្បញ្ញត្តិនៅក្នុងច្បាប់នេះ ។

មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចស៊ើបអង្កេតបទល្មើសពុករលួយ ។ ក្នុងករណីស៊ើបអង្កេតបទល្មើសពុករលួយហើយរកឃើញបទល្មើសផ្សេងទៀតដែលមានអង្គហេតុទាក់ទិននឹងបទល្មើសដែលកំពុងស៊ើបអង្កេត មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ អាចធ្វើការស៊ើបអង្កេតបទល្មើសទាំងនោះរហូតចប់នីតិវិធី ។

អង្គភាពប្រឆាំងអំពើពុករលួយមិនអាចចាប់ផ្តើមការស៊ើបអង្កេតបទល្មើសអ្វីក្រៅពីបទល្មើសពុករលួយបានទេ លើកលែងតែមានបញ្ជាពីអាជ្ញាធរតុលាការឱ្យអង្គភាពប្រឆាំងអំពើពុករលួយស៊ើបអង្កេតបទល្មើសអ្វីក្រៅពីបទល្មើសពុករលួយ ។

តុលាការអាចបញ្ជាឱ្យអង្គភាពប្រឆាំងអំពើពុករលួយ ធ្វើកោសល្យវិច័យនានាដើម្បីជួយដល់ការវិនិច្ឆ័យរបស់តុលាការ ។

នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតទាំងនេះ និង ដោយបដិប្បញ្ញត្តិទៅនឹងមាត្រា ៨៥ (អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង) មាត្រា ៩១ (ការឆែកឆេរ) មាត្រា ៩៤ (បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង) និង មាត្រា ១១៤ (ការបញ្ជាឱ្យចូលខ្លួន ការស៊ើបអង្កេតបឋម) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ឬ តំណាងដែលខ្លួនបានចាត់តាំងយ៉ាងត្រឹមត្រូវ មានតួនាទីដឹកនាំ សម្របសម្រួល និង ត្រួតពិនិត្យបេសកកម្មរបស់មន្ត្រីទាំងនេះជំនួសតួនាទីរបស់ព្រះរាជអាជ្ញារហូតដល់មានការឃាត់ខ្លួនជនសង្ស័យ ។

បន្ទាប់ពីមានការឃាត់ខ្លួន ព្រះរាជអាជ្ញាអនុវត្តអំណាចរបស់ខ្លួនដូចបានកំណត់នៅក្នុងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

នៅក្នុងបញ្ចប់នៃការស៊ើបអង្កេតនីមួយៗ អង្គភាពប្រឆាំងអំពើពុករលួយត្រូវបញ្ជូនសំណុំរឿងនីតិវិធីទាំងអស់ទៅព្រះរាជអាជ្ញា ដើម្បីចាត់ការបន្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ២៦._ បុព្វសិទ្ធិពិសេសរបស់អង្គភាពប្រឆាំងអំពើពុករលួយ**

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចស្នើសុំពីអាជ្ញាធរឋានានុក្រមពាក់ព័ន្ធ ឱ្យផ្អាកជាបណ្តោះអាសន្ននូវមុខងារនៃបុគ្គលទាំងឡាយណាដែលមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាជាប់ទាក់ទិននឹងរឿងហេតុនៃបទល្មើសពុករលួយ ។

ប្រសិនបើជនជាប់សង្ស័យរត់គេចខ្លួនទៅបរទេស ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ចធ្វើបត្យាប័នតាមបទប្បញ្ញត្តិជាធរមាន ។

អង្គភាពប្រឆាំងអំពើពុករលួយអាចរៀបចំឱ្យមានទីកន្លែងមួយចំនួនជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នសមស្រប សម្រាប់ការឃាត់ខ្លួននានាដែលធ្វើឡើងស្របទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ នៅកន្លែងណាដែលអង្គភាពប្រឆាំងអំពើពុករលួយមិនអាចរៀបចំឱ្យមានទីកន្លែងជាអចិន្ត្រៃយ៍ឬជាបណ្តោះអាសន្នសមស្របសម្រាប់ការឃាត់ខ្លួន អង្គភាពប្រឆាំងអំពើពុករលួយអាចសុំឱ្យស្ថាប័នមានសមត្ថកិច្ចរក្សាទុកជនដែលត្រូវបានអង្គភាពប្រឆាំងអំពើពុករលួយឃាត់ខ្លួន ។

**មាត្រា ២៧._ បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការតាមដាន**

ដោយបដិប្បញ្ញត្តិទៅនឹងមាត្រា ១០៥ (ការហាមឃាត់មិនឱ្យស្តាប់ដោយឯកឯងជាអាទិ៍) និង មាត្រា ១៧២ (ការស្តាប់ទូរស័ព្ទជាអាទិ៍ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលមានតម្រុយជាក់លាក់ថាមានបទល្មើសពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយអាច :

ក- ពិនិត្យ និង ដាក់ឱ្យស្ថិតក្រោមការឃ្លាំមើលនូវគណនីធនាគារ ឬ គណនីឯទៀតដែលចាត់ទុកដូចជាគណនីធនាគារ ។

ខ- ធ្វើការត្រួតពិនិត្យ និង បង្គាប់ឱ្យផ្តល់ឬថតចម្លងលិខិតយថាភូត ឬ លិខិតឯកជន ឬ ឯកសារធនាគារ ហិរញ្ញវត្ថុ និង ពាណិជ្ជកម្មទាំងអស់ ។

គ- តាមដាន ឃ្លាំមើល លបស្តាប់ លបថតសំឡេងនិងរូបភាព និង ដាក់ខ្សែទូរស័ព្ទក្រោមការលបស្តាប់ និង ថត ។

ឃ- ចូលទៅពិនិត្យឯកសារនានា ព្រមទាំងឯកសាររក្សាទុកក្នុងប្រព័ន្ធអេឡិច-

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

Kol

ង- រៀបចំប្រតិបត្តិការដែលមានគោលដៅប្រមូលភស្តុតាងជាក់ស្តែង ។

វិធានការខាងលើនេះ មិនត្រូវចាត់ទុកថាជាការរំលោភលើការសម្ងាត់វិជ្ជាជីវៈឡើយ ។ ការសម្ងាត់របស់ធនាគារក៏មិនមែនជាយុត្តិកម្មសម្រាប់បដិសេធមិនផ្តល់ភស្តុតាងពាក់ព័ន្ធនឹងបទល្មើសពុករលួយ ដែលមានបញ្ញត្តនៅក្នុងច្បាប់នេះឡើយ ។

**មាត្រា ២៨._ បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការបង្កកទ្រព្យសម្បត្តិរបស់បុគ្គល**

តាមការស្នើសុំរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រាជរដ្ឋាភិបាលអាចធ្វើអធិបញ្ញាឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអមសាលាដំបូង បង្កកទ្រព្យសម្បត្តិរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងនៅក្នុងច្បាប់នេះ និងបទល្មើសពុករលួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ។

ទ្រព្យសម្បត្តិរបស់បុគ្គលដែលបានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ រាប់បញ្ចូលទាំងមូលនិធិដែលបានមក ឬ បង្កើតបានជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់បុគ្គលនោះ ។

**មាត្រា ២៩._ បុព្វសិទ្ធិរបស់អង្គភាពក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសាធារណៈ**

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ អាចធ្វើអធិបញ្ញាដល់អាជ្ញាធរសាធារណៈ មន្ត្រីរាជការ ពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត ព្រមទាំងបណ្តាអង្គភាពនៃវិស័យឯកជនពាក់ព័ន្ធមានជាអាទិ៍ស្ថាប័នហិរញ្ញវត្ថុធ្វើកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីនៃអង្គភាពក្នុងការងារស៊ើបអង្កេត ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយក៏អាចស្នើសុំការសហការពីស្ថាប័នជាតិ និងអន្តរជាតិក្នុងការធ្វើកោសល្យវិច័យនានាទាក់ទងទៅនឹងការស៊ើបអង្កេតរបស់ខ្លួនផងដែរ ។

**មាត្រា ៣០._ ការចាប់យក**

ការចាប់យកត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៣១._ នីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌ**

នៅក្នុងរឿងក្តីព្រហ្មទណ្ឌពាក់ព័ន្ធនឹងបទល្មើសពុករលួយ តុលាការដែលបានទទួលបណ្តឹង ត្រូវធ្វើការបើកសវនាការជំនុំជម្រះយ៉ាងឆាប់បំផុត ។

ROYAUME DU CAMBODGE PALAIS ROYAL

## ជំពូកទី ៦
## បទល្មើសពុករលួយ និង ទោស

### មាត្រា ៣២.- បទល្មើសពុករលួយដែលមានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌ

ក្រៅពីបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ បទល្មើសដែលមានចែងនៅក្នុង មាត្រា ២៧៨ (បទស៊ីសំណូកនៃនិយោជិត) មាត្រា ២៧៩ (បទសូកប៉ាន់ដល់និយោជិត) មាត្រា ២៨០ (បទស៊ីសំណូករបស់អភិបាលជាអាទិ៍) មាត្រា ២៨៣ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា ៣៨៧ (បទចេញថ្លៃមិនត្រឹមត្រូវ) មាត្រា ៤០៤ (និយមន័យនៃការសម្លាតប្រាក់) មាត្រា ៤០៥ (ទោសដែលត្រូវអនុវត្ត) មាត្រា ៤០៦ (ស្ថានទម្ងន់ទោស) មាត្រា ៤០៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា ៥១៧ (បទស៊ីសំណូកប្រព្រឹត្តដោយចៅក្រម) មាត្រា ៥១៨ (បទសូកប៉ាន់ចំពោះចៅក្រម) មាត្រា ៥១៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា ៥៤៧ (បទស៊ីសំណូករបស់សាក្សីដើម្បីធ្វើសក្ខីកម្មក្លែងក្លាយ) មាត្រា ៥៤៨ (បទសូកប៉ាន់សាក្សី) មាត្រា ៥៥៣ (បទស៊ីសំណូករបស់អ្នកបកប្រែ) មាត្រា ៥៥៤ (បទសូកប៉ាន់អ្នកបកប្រែ) មាត្រា ៥៥៥ (បទស៊ីសំណូករបស់អ្នកជំនាញ) មាត្រា ៥៥៦ (បទសូកប៉ាន់អ្នកជំនាញ) មាត្រា ៥៥៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា ៥៩២ (និយមន័យនៃវិតិក្រម) មាត្រា ៥៩៣ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៩៤ (បទស៊ីសំណូក) មាត្រា ៥៩៥ (និយមន័យនៃជំនួញឥទ្ធិពលអកម្ម) មាត្រា ៥៩៦ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៩៧ (និយមន័យនៃការកេងយកផលប្រយោជន៍ដោយខុសច្បាប់) មាត្រា ៥៩៨ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៩៩ (និយមន័យនៃបក្ខានុគ្រោះ) មាត្រា ៦០០ (ទោសដែលត្រូវអនុវត្ត) មាត្រា ៦០១ (បទបំផ្លាញដោយចេតនា និងកែបំបាត់ដោយទុច្ចរិត) មាត្រា ៦០៥ (បទសូកប៉ាន់) មាត្រា ៦០៦ (បទជំនួញឥទ្ធិពលសកម្ម) មាត្រា ៦០៧ (បទសម្លុតគំរាម) មាត្រា ៦០៨ (បទបំផ្លាញនិងកែបំបាត់) មាត្រា ៦២៥ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) មាត្រា ៦៣៧ (បទស៊ីសំណូកដោយអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា ៦៣៨ (បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា ៦៣៩ (បទស៊ីសំណូកដោយសមាជិកនៃវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា ៦៤០ (បទសូកប៉ាន់

ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា ៦៤១ (ការអនុវត្តបទមជ្ឈិមនៃមាត្រា ៦៣៩ និង មាត្រា ៦៤០ ចំពោះគ្រប់វិជ្ជាជីវៈខាងវេជ្ជសាស្ត្រ) និង មាត្រា ៦៤៤ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌជាបទល្មើសពុករលួយដែលត្រូវអនុវត្តតាមច្បាប់នេះ ។

**មាត្រា ៣៣.— បទស៊ីសំណូកនៃមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ អំពើប្រព្រឹត្តដោយមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈដែលសុំទាមទារ ឬ យល់ព្រមទទួលដោយគ្មានសិទ្ធិដោយផ្ទាល់ ឬ ដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍ណាមួយដើម្បី :

១- បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

២- មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

**មាត្រា ៣៤.— បទសូកប៉ាន់ចំពោះមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បុគ្គលណាដែលគ្មានសិទ្ធិដោយផ្ទាល់ ឬ ដោយប្រយោលប្រគល់អំណោយ ឬ ជំនូន ឬ ធ្វើការសន្យាជាមួយ ឬ ផ្តល់អត្ថប្រយោជន៍អ្វីមួយដល់មន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធា-រណៈដើម្បីឱ្យមន្ត្រីនោះ :

១- បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

២- មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

**មាត្រា ៣៥.— បទរំលោភអំណាច**

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬ ដោយពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោតនៅក្នុងការបំពេញមុខងាររបស់ខ្លួន ឬ ក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ចាត់វិធានការរារាំងការអនុវត្តច្បាប់ ដើម្បីទទួលបានដោយខុសច្បាប់នូវអត្ថប្រយោជន៍ណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ)

Kol

ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះមានប្រសិទ្ធភាព ។

**មាត្រា ៣៦.– បទមានទ្រព្យសម្បត្តិដោយខុសច្បាប់**

ការមានទ្រព្យសម្បត្តិដោយខុសច្បាប់ គឺជាកំណើនទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលបុគ្គលនោះមិនអាចផ្តល់ការពន្យល់សមហេតុសមផលនូវការកើនឡើងនៃទ្រព្យសម្បត្តិនេះដោយប្រៀបធៀបទៅនឹងចំណូលស្របច្បាប់របស់ខ្លួន ។

បន្ទាប់ពីបានធ្វើការប្រកាសទ្រព្យសម្បត្តិ និង បំណុលលើកមុន គ្រប់បុគ្គលដូចមានចែងនៅក្នុង មាត្រា ១៧ (សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) និង មាត្រា ១៩ (ជនផ្សេងទៀតដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) នៃច្បាប់នេះ ដែលមិនអាចផ្តល់ការពន្យល់សមហេតុសមផលនូវការកើនឡើងនៃទ្រព្យសម្បត្តិនេះ ដោយប្រៀបធៀបទៅនឹងចំណូលស្របច្បាប់របស់ខ្លួន ត្រូវទទួលរងនូវការរឹបអូសទ្រព្យសម្បត្តិដែលពុំអាចពន្យល់បានទាំងអស់ ទុកជាសម្បត្តិរដ្ឋ ។

ប្រសិនបើទ្រព្យសម្បត្តិដែលកើនដោយពុំអាចពន្យល់បាននេះ មានការពាក់ព័ន្ធនឹងបទល្មើសពុករលួយណាមួយដូចមានចែងក្នុងច្បាប់នេះ ម្ចាស់ទ្រព្យសម្បត្តិត្រូវទទួលទោសដែលមានចែងនៅក្នុងច្បាប់នេះ ។

**មាត្រា ៣៧.– បទទទួលផលបន្តពីបទល្មើសពុករលួយ**

អំពើទទួលផលបន្តពីបទល្មើសពុករលួយ គឺជាអំពើលាក់បំបាំង រក្សាទុក ឬ ជញ្ជូនរបស់អ្វីមួយដោយដឹងថារបស់នោះបានមកពីបទល្មើសពុករលួយ ដូចមានចែងនៅក្នុងច្បាប់នេះ ។ ត្រូវចាត់ទុកជាអំពើទទួលផលបន្តពីបទល្មើសពុករលួយផងដែរចំពោះ :

១- អំពើធ្វើជាអន្តរការី ដើម្បីបញ្ជូនរបស់អ្វីមួយដោយដឹងថារបស់នោះបានមកពីបទល្មើសពុករលួយ ។

២- អំពើដែលបានទទួលប្រយោជន៍ពីផលបន្តពីបទល្មើសពុករលួយដោយបានដឹងហេតុការណ៍ច្បាស់ ។

Kol

អំពើទទួលផលបន្តពីបទល្មើសពុករលួយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

អំពើទទួលផលបន្តពីបទល្មើសពុករលួយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើបទល្មើសនេះត្រូវបានប្រព្រឹត្តឡើង ៖

១- ជាទម្លាប់ ។

២- ដោយប្រើប្រាស់ភាពងាយស្រួលដែលទទួលបានពីសកម្មភាពវិជ្ជាជីវៈផ្តល់ឱ្យ ។

៣- ជាក្រុមមានការចាត់តាំង ។

**មាត្រា ៣៨.- បទមិនប្រកាសទ្រព្យសម្បត្តិ និង បំណុល**

ជនណាដែលមិនបានប្រកាសទ្រព្យសម្បត្តិនិងបំណុល ឬ បានប្រកាសមិនត្រឹមត្រូវនូវទ្រព្យសម្បត្តិរបស់ខ្លួនទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ១៧ (សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) មាត្រា ១៨ (របបប្រកាសទ្រព្យសម្បត្តិ និង បំណុល) និង មាត្រា ១៩ (ជនផ្សេងទៀតដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ហើយត្រូវបានបង្ខំឱ្យធ្វើការប្រកាសទ្រព្យសម្បត្តិជូនអង្គភាពប្រឆាំងអំពើពុករលួយ ។ ក្នុងករណីរឹងរូសមិនព្រមប្រកាសទ្រព្យសម្បត្តិទៀតត្រូវផ្តន្ទាទោសទ្វេដង ។

ដោយឡែកចំពោះថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល ប្រធានអង្គភាពប្រឆាំងអំពើពុករលួយមានភារកិច្ចរំលឹកជាលាយលក្ខណ៍អក្សរដល់ថ្នាក់ដឹកនាំនៃអង្គការសង្គមស៊ីវិល មុននឹងអនុវត្តមាត្រានេះ ។

**មាត្រា ៣៩.- បទធ្លាយការសម្ងាត់នៃប្រភពព័ត៌មានស្តីពីអំពើពុករលួយ**

ជនណាដែលធ្វើឱ្យធ្លាយការសម្ងាត់នៃប្រភពព័ត៌មានស្តីពីអំពើពុករលួយ ត្រូវផ្តន្ទា

ទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

ការរក្សាការសម្ងាត់ជាចំខាត មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។

**មាត្រា ៤០.– បទរារាំង និង ការបន្លំប្រឆាំងដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ**

អ្នករាជការសាធារណៈ យោធិន នគរបាលជាតិ ពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោត មន្ត្រីសង្គមស៊ីវិល មន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ ដែលធ្វើការសម្លុតគំរាមកំហែង រារាំង ឬ ជ្រៀតជ្រែកក្នុងការបំពេញមុខងាររបស់មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤១.– បទប្តឹងបរិហារដោយភូតកុហក**

អំពើប្តឹងបរិហារដោយភូតកុហកដល់អង្គភាពប្រឆាំងអំពើពុករលួយឬតុលាការនូវអង្គហេតុបទល្មើសពុករលួយ កាលបើអំពើនេះនាំឱ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៤២.– បទបំពានលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក**

បុគ្គលណាដែលគ្មានសិទ្ធិធ្វើការផ្ទេរ ធ្វើអនុប្បទាន ឬ ធ្វើការដោះដូរនូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យកដោយរំលោភលើបទប្បញ្ញត្តិនៃមាត្រា ៣០ (ការចាប់យក) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៣.– បទល្មើសពុករលួយតូចតាចនិងនោស**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ដល់ ៥ (ប្រាំ) ឆ្នាំ ជនណាដែលប្រព្រឹត្តបទល្មើសពុករលួយដែលបញ្ញត្តនៅក្នុងច្បាប់នេះ ហើយបានបំពេញលក្ខខណ្ឌទាំងបីដូចខាងក្រោម :

Kol

- បទល្មើសប្រព្រឹត្តឡើងសម្រាប់ជីវភាពប្រចាំថ្ងៃ
- បទល្មើសប្រព្រឹត្តឡើងមានលក្ខណៈតូចតាច
- បទល្មើសដែលមិនបង្កព្យសនកម្មធ្ងន់ធ្ងរដល់សង្គមជាតិ
- មានការវាយតម្លៃទទួលស្គាល់ពីអង្គភាពប្រឆាំងអំពើពុករលួយថាជាបទល្មើសពុករលួយតូចតាច ។

**មាត្រា ៤៤.- ការប៉ុនប៉ង**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដូចមានចែងនៅក្នុងមាត្រា ២៧៨ (បទស៊ីសំណូកនៃនិយោជិត) មាត្រា ២៧៩ (បទសូកប៉ាន់ដល់និយោជិត) មាត្រា ៣៨៧ (បទចេញថ្លៃមិនត្រឹមត្រូវ) មាត្រា ៤០៤ (និយមន័យនៃការសំអាតប្រាក់) មាត្រា ៤០៥ (ទោសដែលត្រូវអនុវត្ត) មាត្រា ៤០៦ (ស្ថានទម្ងន់ទោស) មាត្រា ៥៩២ (និយមន័យនៃវិតិក្រម) មាត្រា ៥៩៣ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៩៧ (និយមន័យនៃការកេងយកផលប្រយោជន៍ដោយខុសច្បាប់) មាត្រា ៥៩៨ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៩៩ (និយមន័យនៃបក្ខានុគ្រោះ) មាត្រា ៦០០ (ទោសដែលត្រូវអនុវត្ត) មាត្រា ៦៣៨ (បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) មាត្រា ៦៤០ (បទសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៣៥ (បទរំលោភអំណាច) និង មាត្រា ៤០ (បទរារាំង និង ការជ្រៀតជ្រែកដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមបានសម្រេចដែរ ។

**មាត្រា ៤៥.- ទោសបន្ថែមអនុវត្តចំពោះបទល្មើសពុករលួយ**

ចំពោះបទល្មើសពុករលួយដូចមានចែងនៅក្នុងច្បាប់នេះ ទោសបន្ថែមមួយ ឬ ច្រើនដូចខាងក្រោម អាចត្រូវបានប្រកាសពី :

១- ការដកសិទ្ធិពលរដ្ឋខ្លះជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

២- ការហាមឃាត់ចំពោះការប្រកបមុខរបរជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តក្នុងការប្រកបមុខរបរ ឬ ក្នុងឱកាសនៃការប្រកបមុខរបរនេះ ។

៣- ការហាមឃាត់នូវការស្នាក់អាស្រ័យនៅសម្រាប់រយៈពេលមិនលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទល្មើសឧក្រិដ្ឋ និង សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ចំពោះបទល្មើសមជ្ឈិម ។

៤- ការហាមឃាត់ទណ្ឌិតបរទេសនូវការចូលមក និង ស្នាក់អាស្រ័យនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

៥- ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦- ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាទីដៅនៃបទល្មើស ។

៧- ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨- ការរឹបអូសនូវឧបភោគភណ្ឌសម្ភារៈ និង គ្រឿងសង្ហារិមតែងលំអទីតាំងដែលក្នុងទីតាំងនោះ បទល្មើសត្រូវបានប្រព្រឹត្ត។

៩- ការរឹបអូសនូវយានយន្តរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

១០- ការហាមឃាត់ចំពោះការកាន់កាប់ ឬ យកតាមខ្លួននូវអាវុធជាតិផ្ទុះជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

១១- ការបិទគ្រឹះស្ថានដែលត្រូវបានប្រើប្រាស់សម្រាប់ត្រៀមរៀបចំបទល្មើស ឬ ប្រព្រឹត្តបទល្មើសជាស្ថាពរ ឬ សម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

១២- ការហាមឃាត់ការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកជាសាធារណៈ ឬ ដែលប្រើប្រាស់ដោយសាធារណជនជាស្ថាពរឬសម្រាប់រយៈពេលមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

១៣- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសសម្រាប់រយៈពេលមិនលើសពី ២ (ពីរ) ខែ ។

១៥- ការចេញផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ។

១៦- ការចាក់ផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយគមនាគមន៍សោតទស្សន៍សម្រាប់រយៈពេលមិនលើសពី ៨ (ប្រាំបី) ថ្ងៃ ។

ROYAUME DU CAMBODGE * LE MINISTERE du PALAIS ROYAL *

**មាត្រា ៤៦.– ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល**

នីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើសពុករលួយដែលមានចែងក្នុងមាត្រា ៣៧ (បទទទួលផលបន្តពីបទល្មើសពុករលួយ) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ដល់ ១០០.០០០.០០០ (មួយរយលាន) រៀល និង ត្រូវទទួលទោសបន្ថែមមួយ ឬ ច្រើនដូចខាងក្រោមនេះ :

១- ការរំលាយចោល។

២- ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

៥- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ។

៦- ការហាមឃាត់ចំពោះការចេញមូលប្បទានបត្រក្រៅពីមូលប្បទានបត្រដែលបញ្ជាក់ដោយធនាគារណាមួយ ។

៧- ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់។

៨- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស ។

៩- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬ ដែលបានប្រើប្រាស់ដោយសាធារណជន ។

១០- ការរឹបអូសឧបករណ៍សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។

១១- ការរឹបអូសនូវវត្ថុឬមូលនិធិដែលជាទីដៅនៃបទល្មើស ។

១២- ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣- ការរឹបអូសនូវឧបភោគភណ្ឌ សម្ភារៈ និង ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤- ការបិទផ្សាយនៃសេចក្តីសម្រេចផ្តន្ទាទោស ។

១៥-ការចេញផ្សាយនូវសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ឬ ផ្សព្វផ្សាយតាមមធ្យោបាយគមនាគមន៍សោតទស្សន៍ ។

**មាត្រា ៤៧.- ការផ្សាយចេញនូវកំណត់ត្រារបស់ធនាគារ**

គ្រឹះស្ថានឥណទាន ឬ ស្ថាប័នហិរញ្ញវត្ថុរួចផុតពីការទទួលខុសត្រូវទាំងអស់ ហើយគ្មានបណ្តឹងព្រហ្មទណ្ឌណាមួយត្រូវបានធ្វើប្រឆាំងនឹងអ្នកដឹកនាំ ឬ អាណត្តិនៃគ្រឹះស្ថាន ឬ ស្ថាប័ននោះឡើយ ប្រសិនបើប្រតិបត្តិការនោះត្រូវបានអនុវត្តស្របតាមបទប្បញ្ញត្តិច្បាប់ លើកលែងតែក្នុងករណីដែលរកឃើញថាមានការព្រមព្រៀងគ្នាជាមុន ដើម្បីរៀបចំបន្ទំជាមួយម្ចាស់ប្រាក់ ឬ អ្នកធ្វើប្រតិបត្តិការ ។

**មាត្រា ៤៨.- សេចក្តីសម្រេចរឹបអូស**

នៅពេលដែលបុគ្គលណាមួយត្រូវបានផ្តន្ទាទោសពីបទល្មើសពុករលួយ តុលាការត្រូវសម្រេចរឹបអូសផលនៃអំពើពុករលួយទាំងអស់ដែលរួមមាន ទ្រព្យសម្បត្តិ សម្ភារៈ និងឧបករណ៍ទាំងអស់ដែលជាកម្មវត្ថុនៃអំពើពុករលួយទុកជាសម្បត្តិរដ្ឋ ។

ប្រសិនបើផលនៃអំពើពុករលួយខាងលើត្រូវបានបំប្លែងទៅជាទ្រព្យសម្បត្តិផ្សេងពីសភាពដើម ទ្រព្យសម្បត្តិដែលត្រូវបានបំប្លែងនេះក៏ត្រូវក្លាយជាកម្មវត្ថុនៃការរឹបអូសដល់ទីកន្លែងដែលទ្រព្យសម្បត្តិនេះតាំងនៅផងដែរ ។

ប្រសិនបើផលនៃអំពើពុករលួយនេះបង្កើតឱ្យមានជាចំណូល ឬ ផលដទៃផ្សេងទៀត ចំណូល និង ផលទាំងនេះក៏ត្រូវរឹបអូសផងដែរ ។

ប្រសិនបើផលទាំងនោះរលាយបាត់ ឬ បាត់បង់តម្លៃ តុលាការអាចបញ្ជាឱ្យទូទាត់តម្លៃដើមនៃផលទាំងនោះ ។

**មាត្រា ៤៩.- ការទាមទារឱ្យបញ្ជូននូវផលនៃបទល្មើសពុករលួយ**

នៅក្នុងករណីដែលរកឃើញថាទ្រព្យសម្បត្តិ និង ផលនៃអំពើពុករលួយត្រូវបានរក្សាទុកនៅក្នុងរដ្ឋបរទេស អាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាត្រូវចាត់វិធានការដើម្បីទាមទារយកទ្រព្យសម្បត្តិ និង ផលទាំងនោះមកកម្ពុជាវិញតាមមធ្យោបាយនៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ។ ព្រះរាជាណាចក្រកម្ពុជាក៏ត្រូវធ្វើសហប្រតិបត្តិការជាមួយប្រទេសដទៃដែលលើកសំណើសុំបញ្ជូនទៅវិញនូវផលនៃបទល្មើសពុករលួយ ដែលត្រូវបានរក្សាទុកក្នុងប្រទេសកម្ពុជា ។

## ជំពូកទី ៧
## បត្យាប័ន និង ជំនួយផ្នែកច្បាប់ទៅវិញទៅមក

### មាត្រា ៥០.– បទប្បញ្ញត្តិដែលត្រូវអនុវត្តក្នុងរឿងបត្យាប័ន

បទប្បញ្ញត្តិនៃជំពូកទី ២ មាតិកាទី ១ គន្ថីទី ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងរឿងបត្យាប័នពាក់ព័ន្ធនឹងបទល្មើសពុករលួយ ។

### មាត្រា ៥១.– ជំនួយផ្នែកច្បាប់ទៅវិញទៅមក

ក្នុងករណីបទល្មើសពុករលួយ អាជ្ញាធរតុលាការនៃព្រះរាជាណាចក្រកម្ពុជាអាចប្រគល់អំណាចឱ្យទៅអាជ្ញាធរខាងតុលាការមានសមត្ថកិច្ចនៃរដ្ឋបរទេសណាមួយ និង អាចទទួលអំណាចពីអាជ្ញាធរតុលាការនៃរដ្ឋបរទេសណាមួយដែរដើម្បី :

១- ប្រមូលយកសក្ខីភាព ឬ យកចម្លើយដែលឆ្លើយតាមផ្លូវតុលាការ ។

២- ឱ្យដំណឹងពីលិខិតផ្សេងៗរបស់តុលាការ ។

៣- ធ្វើការឆែកឆេរ ឃាត់ទុក និង ដកហូត ។

៤- ធ្វើការពិនិត្យវត្ថុ និង ទីកន្លែង ។

៥- ផ្តល់ព័ត៌មាន និង វត្ថុតាង ។

៦- ផ្តល់ឯកសារកំណត់ហេតុជាច្បាប់ដើម ឬ សេចក្តីចម្លងដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមនៃឯកសារ និង សំណុំរឿង រាប់ទាំងសេចក្តីស្រង់បញ្ជីប្រាក់ពីធនាគារ ឯកសារគណនេយ្យ សំណុំរឿងរបស់ក្រុមហ៊ុន និង ឯកសារពាណិជ្ជកម្មព្រមទាំងលិខិតយថាភូត ឬ លិខិតឯកជន ។

៧- បង្ហាញ ឬ ផ្តល់សាក្សី អ្នកជំនាញ ឬ ជនដទៃទៀតរាប់ទាំងជនជាប់ឃុំខ្លួនផងដែលយល់ព្រមជួយក្នុងការស៊ើបអង្កេត ឬ យល់ព្រមចូលរួមក្នុងនីតិវិធី ។

៨- កំណត់អត្តសញ្ញាណ ឬ ស្រាវជ្រាវរកធនធាន ទ្រព្យសម្បត្តិ បរិក្ខារ និង សម្ភារៈទាំងឡាយដែលបានមកពីការប្រព្រឹត្តបទល្មើស និង មធ្យោបាយបទល្មើស ។

៩- ដាក់ក្រោមវិធានការរក្សាទុកជាបណ្តោះអាសន្ននូវផលិតផល និង ទ្រព្យសម្បត្តិដែលបានមកពីបទល្មើសពុករលួយព្រមទាំងបរិក្ខារ សម្ភារៈដែលប្រើប្រាស់ ឬ ទុកសម្រាប់ប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសពុករលួយ ។

១០- ចាត់ឱ្យអនុវត្តសេចក្តីសម្រេចដែលបញ្ជាឱ្យធ្វើការរឹបអូស ដកហូត ឬ យកមកវិញនូវផលិតផល ទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ សម្ភារៈទាំងឡាយដែលបានមកពីការប្រព្រឹត្ត អំពើពុករលួយ ។

១១- បញ្ជាឱ្យធ្វើការរឹបអូសវត្ថុទាំងឡាយដែលមានចែងក្នុងចំណុចខាងលើ ។

១២- ឱ្យដំណឹងអំពីការចោទប្រកាន់តាមនីតិវិធីព្រហ្មទណ្ឌ ។

១៣- សួរចម្លើយជនត្រូវចោទតាមនីតិវិធីព្រហ្មទណ្ឌ ។

១៤- រកឱ្យឃើញ និង កំណត់អត្តសញ្ញាណសាក្សី និង ជនសង្ស័យ ។

### មាត្រា ៥២.- ករណីពលរដ្ឋខ្មែរដែលមានសញ្ជាតិលើសពីមួយ

ស្ថាប័នប្រឆាំងអំពើពុករលួយ និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ មានកាតព្វកិច្ចស្វះស្វែងរកកិច្ចសហប្រតិបត្តិការអន្តរជាតិ និង ជំនួយផ្នែកច្បាប់ទៅវិញទៅមកអំពីស្ថានភាពទ្រព្យសម្បត្តិរបស់ពលរដ្ឋខ្មែរដែលមានសញ្ជាតិលើសពីមួយ ។

### មាត្រា ៥៣.- នីតិវិធីជំនួយផ្នែកច្បាប់ទៅវិញទៅមក

នីតិវិធីនៃការអនុវត្តជំនួយផ្នែកច្បាប់ទៅវិញទៅមក ត្រូវអនុវត្តតាមគោលការណ៍ទាំងឡាយដែលបានកំណត់ក្នុងសន្ធិសញ្ញា ឬ កិច្ចព្រមព្រៀងទ្វេភាគីនិងពហុភាគី និង ច្បាប់ជាតិជាធរមាន ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

### មាត្រា ៥៤.- ការរៀបចំដំណើរការរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង អង្គភាពប្រឆាំងអំពើពុករលួយ

បន្ទាប់ពីច្បាប់នេះត្រូវបានប្រកាសឱ្យប្រើ រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង អង្គភាពប្រឆាំងអំពើពុករលួយក្នុងរយៈពេល ៦ (ប្រាំមួយ) ខែយ៉ាងយូរ ។

អង្គភាពដើមប្រឆាំងអំពើពុករលួយ ត្រូវទទួលបន្ទុកអនុវត្តភារកិច្ចប្រឆាំងអំពើពុករលួយតាមច្បាប់ជាធរមាន និង ផ្សព្វផ្សាយច្បាប់នេះរហូតដល់ស្ថាប័នប្រឆាំងអំពើពុករលួយត្រូវបានរៀបចំហើយ ទើបអង្គភាពដើមប្រឆាំងអំពើពុករលួយនេះត្រូវរំលាយ ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៥៥.– និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥៦.– ការប្រកាសឱ្យប្រើច្បាប់**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

**មាត្រា ៥៧.– ការអនុវត្តច្បាប់**

បន្ទាប់ពីការចូលជាធរមាននៃច្បាប់នេះ បទប្បញ្ញត្តិផ្សេងពីបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី ៦ នៃច្បាប់នេះ ត្រូវយកមកអនុវត្តភ្លាម ។

បទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី ៦ នៃច្បាប់នេះ មានអានុភាពអនុវត្តក្នុងរយៈពេល ១២ (ដប់ពីរ) ខែ ក្រោយពេលដែលក្រមព្រហ្មទណ្ឌត្រូវបានអនុវត្តទាំងស្រុង ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០

៣/៧. ១០០៤. ៣១៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ហត្ថលេខា
**សុខ អាន**

៣១/៣/១០

លេខៈ ៣០៥ ច.ល
[illegible]ចម្លងចែក
[illegible] ឆ្នាំ២០១០
[illegible]រដ្ឋាភិបាល
ស៊ុន ជិនអេន

## មាតិកា


**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ** ............ ១

មាត្រា ១ គោលបំណង............ ១

មាត្រា ២ គោលដៅ............ ១

មាត្រា ៣ វិសាលភាព............ ១

មាត្រា ៤ និយមន័យ ............ ១

**ជំពូកទី ២ ស្ថាប័នប្រឆាំងអំពើពុករលួយ** ............ ៤

មាត្រា ៥ ស្ថាប័នប្រឆាំងអំពើពុករលួយ............ ៤

**ផ្នែកទី ១ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**............ ៥

មាត្រា ៦ ការបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ............ ៥

មាត្រា ៧ អាណត្តិ ការដកចេញពីតំណែង និងការជំនួសតំណែង ............ ៦

មាត្រា ៨ ការជ្រើសតាំងប្រធាននិងអនុប្រធាន ............ ៧

មាត្រា ៩ ឋានៈរបស់សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ............ ៧

មាត្រា ១០ ភារកិច្ចរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ............ ៧

**ផ្នែកទី ២ អង្គភាពប្រឆាំងអំពើពុករលួយ** ............ ៨

មាត្រា ១១ ការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ............ ៨

មាត្រា ១២ លក្ខណសម្បត្តិនៃប្រធាននិងអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ..... ៨

មាត្រា ១៣ ភារកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ............ ៨

មាត្រា ១៤ មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ ............ ១០

មាត្រា ១៥ បណ្តាញនៃអង្គភាពប្រឆាំងអំពើពុករលួយ............ ១០

**ជំពូកទី ៣ ថវិកានិងធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ** ............ ១០

មាត្រា ១៦ ថវិកានិងធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ............ ១០

**ជំពូកទី ៤ ការប្រកាសទ្រព្យសម្បត្តិនិងបំណុល**............ ១១

មាត្រា ១៧ សមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល ............ ១១

មាត្រា ១៨ របបប្រកាសទ្រព្យសម្បត្តិនិងបំណុល ............ ១២

មាត្រា ១៩ ជនផ្សេងទៀតដែលត្រូវប្រកាសទ្រព្យសម្បត្តិនិងបំណុល............ ១២

មាត្រា ២០ ការរក្សាទុកឯកសារប្រកាសទ្រព្យសម្បត្តិនិងបំណុល............ ១៣


Kol

**ជំពូកទី ៥ នីតិវិធីអនុវត្តចំពោះបទល្មើសពុករលួយនិងអាជ្ញាធរមានសមត្ថកិច្ច** ................ ១៣
មាត្រា ២១ នីតិវិធីសម្រាប់អនុវត្តចំពោះបទល្មើសពុករលួយ ........................ ១៣
មាត្រា ២២ មន្ត្រីមានសមត្ថកិច្ចនៅក្នុងការស៊ើបអង្កេតបទល្មើសពុករលួយ........... ១៤
មាត្រា ២៣ ការផ្តល់នីតិសម្បទាចំពោះមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ ........ ១៤
មាត្រា ២៤ សម្បថ.............................................................. ១៤
មាត្រា ២៥ អំណាចស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ................. ១៥
មាត្រា ២៦ បុព្វសិទ្ធិពិសេសរបស់អង្គភាពប្រឆាំងអំពើពុករលួយ .................... ១៦
មាត្រា ២៧ បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការតាមដាន..... ១៦
មាត្រា ២៨ បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការបង្កកទ្រព្យសម្បត្តិរបស់
បុគ្គល.............................................................. ១៧
មាត្រា ២៩ បុព្វសិទ្ធិរបស់អង្គភាពក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសាធារណៈ. ១៧
មាត្រា ៣០ ការចាប់យក ........................................................ ១៧
មាត្រា ៣១ នីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌ ............................. ១៧
**ជំពូកទី ៦ បទល្មើសពុករលួយនិងទោស** .............................................. ១៨
មាត្រា ៣២ បទល្មើសពុករលួយដែលមានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌ............. ១៨
មាត្រា ៣៣ បទស៊ីសំណូកនៃមន្ត្រីសាធារណៈបរទេសឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ ១៩
មាត្រា ៣៤ បទសូកបាន់ចំពោះមន្ត្រីសាធារណៈបរទេសឬមន្ត្រីនៃអង្គការអន្តរជាតិ
សាធារណៈ.................................................... ១៩
មាត្រា ៣៥ បទរំលោភអំណាច.................................................. ១៩
មាត្រា ៣៦ បទមានទ្រព្យសម្បត្តិដោយខុសច្បាប់ ................................... ២០
មាត្រា ៣៧ បទទទួលផលបន្តពីបទល្មើសពុករលួយ.................................. ២០
មាត្រា ៣៨ បទមិនប្រកាសទ្រព្យសម្បត្តិនិងបំណុល................................ ២១
មាត្រា ៣៩ បទទម្លាយការសម្ងាត់នៃប្រភពព័ត៌មានស្តីពីអំពើពុករលួយ.............. ២១
មាត្រា ៤០ បទរារាំងនិងការជ្រៀតជ្រែកដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ .. ២២
មាត្រា ៤១ បទប្តឹងបរិហារដោយភូតកុហក ....................................... ២២
មាត្រា ៤២ បទបំពានលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក................ ២២
មាត្រា ៤៣ បទល្មើសពុករលួយតូចតាចនិងទោស................................ ២២
មាត្រា ៤៤ ការប៉ុនប៉ង.......................................................... ២៣
មាត្រា ៤៥ ទោសបន្ថែមអនុវត្តចំពោះបទល្មើសពុករលួយ......................... ២៣

kol

មាត្រា ៤៦ ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល.................................... ២៥

មាត្រា ៤៧ ការផ្សាយចេញនូវកំណត់ត្រារបស់ធនាគារ .............................. ២៦

មាត្រា ៤៨ សេចក្តីសម្រេចរឹបអូស ............................................ ២៦

មាត្រា ៤៩ ការទាមទារឱ្យបញ្ជូននូវផលនៃបទល្មើសពុករលួយ ...................... ២៦

**ជំពូកទី ៧ បត្យាប័ននិងជំនួយផ្នែកច្បាប់ទៅវិញទៅមក**.................................... ២៧

មាត្រា ៥០ បទប្បញ្ញត្តិដែលត្រូវអនុវត្តក្នុងរឿងបត្យាប័ន............................ ២៧

មាត្រា ៥១ ជំនួយផ្នែកច្បាប់ទៅវិញទៅមក.......................................... ២៧

មាត្រា ៥២ ករណីពលរដ្ឋខ្មែរដែលមានសញ្ជាតិលើសពីមួយ ........................ ២៨

មាត្រា ៥៣ នីតិវិធីជំនួយផ្នែកច្បាប់ទៅវិញទៅមក ................................. ២៨

**ជំពូកទី ៨ អន្តរប្បញ្ញត្តិ** ................................................... ២៨

មាត្រា ៥៤ ការរៀបចំដំណើរការរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយនិងអង្គភាព
ប្រឆាំងអំពើពុករលួយ.................................................. ២៨

**ជំពូកទី ៩ អវសានប្បញ្ញត្តិ**.................................................. ២៩

មាត្រា ៥៥ និរាករណ៍.......................................................... ២៩

មាត្រា ៥៦ ការប្រកាសឱ្យប្រើច្បាប់ .............................................. ២៩

មាត្រា ៥៧ ការអនុវត្តច្បាប់...................................................... ២៩


ROYAUME DU CAMBODGE

Ksl

ច្បាប់ចម្លង

# ព្រះរាជក្រម

នស/រកម/០៨១១/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានកែតម្រូវ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានប្រកាសជម្រាបជូនអង្គប្រជុំព្រឹទ្ធសភា នាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ ដោយយល់ឃើញថាគ្មានចំណុចអ្វីថ្មីដែលគួរផ្តល់យោបល់ឡើងវិញជាលើកទី២ឡើយ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១១៨/០០៦/២០១១ កបធ.ច ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :



# ច្បាប់

## ស្ដីពី

## វិសោធនកម្មច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ

**មាត្រាមួយ.–**

ត្រូវបានបន្ថែមមាត្រា ១០ ស្ទួនកែប្រែមាត្រា ១៦ និងលុបមាត្រា ៥៧ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០១០ ដូចខាងក្រោម:

**មាត្រា ១០.–ស្ទួន ប្រកាសរបស់ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**

ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ចេញប្រកាសក្នុងការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាពប្រឆាំងអំពើពុករលួយ ចាប់ពីថ្នាក់ក្រោមនាយកដ្ឋាន និងការតែងតាំង ផ្លាស់ប្ដូរ បញ្ចប់ភារកិច្ចមន្ត្រីក្របខណ្ឌស្ថាប័នប្រឆាំងអំពើពុករលួយចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន តាមសំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ។

**មាត្រា ១៦.–ថ្មី ថវិកា និងធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ**

ស្ថាប័នប្រឆាំងអំពើពុករលួយមានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន ដែលស្ថិតនៅក្នុងថវិការបស់ជាតិ ។ ស្ថាប័នប្រឆាំងអំពើពុករលួយ ទទួលធនធានចាំបាច់នានាពីរាជរដ្ឋាភិបាល និងមានសិទ្ធិទទួលនូវអំណោយ ឬ ជំនួយពីអង្គការជាតិ អន្តរជាតិនានា ។ ស្ថាប័នប្រឆាំងអំពើពុករលួយ មិនត្រូវទទួលជំនួយណាដែលនាំឲ្យមានទំនាស់ផលប្រយោជន៍ ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយជាអាណាប័កដើមខ្សែ ។



ការគ្រប់គ្រងនិងចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥៧ ត្រូវបានលុបចោល ។

**មាត្រា ពីរ.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស. ១១០៩.៣៣៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

**ហត្ថលេខា**

**ឱម យ៉ិនទៀង**

លេខ:៦៩៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១១

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

[illegible]

**ឃុន ជិនកេន**

# ឧបសម្ព័ន្ធ ២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ

~~~~~~~~

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

### សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ហៅកាត់ថា " អ.ប.អ.ព " ដែលស្ថិតនៅក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី។

Ku
~~~~~~~~

**មាត្រា២ ..**

អង្គភាពប្រឆាំងអំពើពុករលួយ មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ឱម យ៉ិនទៀង** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម **មល់ ធឿប** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម **ឡូរី សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤-ឯកឧត្តម **ឆឹយ ធឿន** | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | អនុប្រធាន |
| ៥-ឯកឧត្តម **ឆេង សារឿន** | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច | សមាជិក |
| ៦-ឯកឧត្តម **ហង់ជួន ណារ៉ុន** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-ឯកឧត្តមឧត្តមសេនីយ៍ឯក **នេត សាវឿន** | អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៨-ឯកឧត្តមឧត្តមសេនីយ៍ឯក **ជុំ ឃាត់** | មេបញ្ជាការរងកងទ័ពជើងគោក | សមាជិក |
| ៩-ឯកឧត្តម **ម៉ុន ហុន** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១០-ឯកឧត្តមឧត្តមសេនីយ៍ទោ **ខឹម្ស ពិសេន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១១-លោក **សរ សម្បត្តិ** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកប្រចាំការ |

**មាត្រា៣ ..**

អង្គភាពប្រឆាំងអំពើពុករលួយ មានបេសកកម្មក្នុងការធ្វើសកម្មភាព ដោយផ្តោតសំខាន់លើកត្តាជាសារវ័ន្តពា ដែលមានភាពប្រទាក់ក្រឡាគ្នា គឺ ការបង្ការទប់ស្កាត់ជាមុន ការពង្រឹងការអនុវត្តច្បាប់ និងការគាំទ្រពីមហាជន ក្នុងការប្រយុទ្ធប្រឆាំងកំចាត់អំពើពុករលួយ ។

អង្គភាពប្រឆាំងអំពើពុករលួយមានតួនាទី និងភារកិច្ច ដូចតទៅ :

-ប្រមែប្រមូលគ្រប់ឯកសារ និងព័ត៌មានពាក់ព័ន្ធអំពើពុករលួយគ្រប់ប្រភេទ និងរក្សាការសម្ងាត់នៃប្រភពទទួលព័ត៌មាន ស្តីពីការកើតមានអំពើពុករលួយ

-ពិនិត្យ និងរៀបចំឯកសារ ព្រមទាំងលើកឡើងគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងការប្រឆាំងកំចាត់អំពើពុករលួយ ដែលមានចរិតជាចក្ខុវិស័យ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

-រៀបចំកសាងផែនការសកម្មភាពប្រឆាំងអំពើពុករលួយ

-ទទួល និងពិនិត្យរាល់ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងអំពើពុករលួយ

-តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ និងធ្វើការសិក្សាស្រាវជ្រាវ ព្រមទាំងលើកឡើងនូវវិធានការនានាពាក់ព័ន្ធនឹងបទល្មើសពុករលួយនៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ក្រុមហ៊ុនរដ្ឋ និងអាជ្ញាធរដែនដីខេត្ត ក្រុង ព្រមទាំងចាត់ការទៅតាមនីតិវិធីជាធរមាន

-អនុវត្តនូវវិធានការរបស់រាជរដ្ឋាភិបាល តាមរយៈការអប់រំ ឃោសនា ផ្សព្វផ្សាយ ការបង្ការ ការទប់ស្កាត់ ការជំរុញការអនុវត្តច្បាប់ និងការបង្ក្រាបអំពើពុករលួយ

-ធ្វើទំនាក់ទំនង សម្របសម្រួល និងកៀរគរធនធាន និងជំនួយអន្តរជាតិ

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ជូនប្រមុខរាជរដ្ឋាភិបាល ។

-ជំរុញ និងលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋានសាធារណៈទាំងអស់ ឱ្យចូលរួមផ្តល់ព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ

-ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ក្នុងគោលដៅប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងស្វែងរកជំនួយឧបត្ថម្ភពីដៃគូនានា ទាំងសម្ភារៈ បច្ចេកទេសជំនាញ និងថវិកា

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ ជូនប្រធានអង្គភាព

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៧ .-**

ផ្នែកស៊ើបអង្កេត មានតួនាទី និងភារកិច្ចដូចតទៅ :

-ទទួលពាក្យបណ្តឹង និងស្វែងរកព័ត៌មាន ដែលពាក់ព័ន្ធនឹងអំពើពុករលួយ

-សិក្សាស្រាវជ្រាវ និងប្រមូលឯកសារពាក់ព័ន្ធនឹងអំពើពុករលួយ រួចធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំអង្គភាព

-សហការជាមួយសមត្ថកិច្ច និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីធ្វើការស៊ើបអង្កេតដល់ទីកន្លែងនូវរាល់ករណីពាក់ព័ន្ធនឹងការក្លែងបន្លំ ការកិបកេងទ្រព្យសម្បត្តិរដ្ឋ ការបាត់បង់ថវិកាជាតិ និងសកម្មភាពនៃអំពើពុករលួយផ្សេងទៀត

-តាមដានលើឯកសារ និងសកម្មភាពនៃការងារចំណូល ចំណាយថវិកាជាតិ និងការប្រើប្រាស់ជំនួយជាតិ និងអន្តរជាតិ នៅតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អាជ្ញាធរដែនដីខេត្ត ក្រុង គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងក្រុមហ៊ុនរដ្ឋ ដើម្បីធ្វើការវាយតម្លៃ សន្និដ្ឋាន និងលើកវិធានការជូនថ្នាក់ដឹកនាំអង្គភាព

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ ជូនប្រធានអង្គភាព

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៨ .-**

ផ្នែកជំរុញការអនុវត្តច្បាប់ មានតួនាទី និងភារកិច្ចដូចតទៅ :

-សិក្សា និងវិភាគពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើពុករលួយ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់បទល្មើស រួចស្នើសុំការសម្រេចពីថ្នាក់ដឹកនាំអង្គភាព

-សហការជាមួយផ្នែកស៊ើបអង្កេត និងផ្នែកពាក់ព័ន្ធ ព្រមទាំងនគរបាលយុត្តិធម៌ ក្នុងការរៀបចំបែបបទបញ្ជូនសំណុំរឿង និងជនល្មើសទៅតុលាការតាមនីតិវិធីជាធរមាន

-សិក្សាស្រាវជ្រាវឯកសារច្បាប់ និងលិខិតបទដ្ឋាននានា ទាំងក្នុង និងក្រៅប្រទេសដែលពាក់ព័ន្ធនឹងការប្រឆាំងនឹងអំពើពុករលួយ

-តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួង ស្ថាប័ន ដើម្បីធានាបាននូវភាពសុចរិត ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព

-ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមកាលកំណត់ ជូនប្រធានអង្គភាព

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៤ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានរចនាសម្ព័ន្ធដូចតទៅ :

១-ផ្នែករដ្ឋបាល ហិរញ្ញកិច្ច និងធនធានមនុស្ស

២-ផ្នែកអប់រំ បង្ការ ទប់ស្កាត់ និងសហប្រតិបត្តិការ

៣-ផ្នែកស៊ើបអង្កេត

៤-ផ្នែកជំរុញការអនុវត្តច្បាប់ ។

ផ្នែកនីមួយៗត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

**មាត្រា៥ .-**

ផ្នែករដ្ឋបាល ហិរញ្ញកិច្ច និងធនធានមនុស្ស មានតួនាទី និងភារកិច្ចដូចតទៅ :

-ទទួល និងពិនិត្យរាល់លិខិតចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងពាក្យបណ្តឹងនានា ព្រមទាំងបញ្ជូនលិខិតឯកសារទៅផ្នែកថ្នាក់ដឹកនាំ និងក្រសួង ស្ថាប័នពាក់ព័ន្ធ

-លើក និងអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ, ព្រមទាំងគ្រប់គ្រងគណនេយ្យ និងហិរញ្ញកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ

-គ្រប់គ្រង និងរៀបចំបណ្តុះបណ្តាលធនធានមនុស្ស ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកំពស់សមត្ថភាពជំនាញដល់មន្ត្រីរាជការក្នុងអង្គភាព និងក្រសួង ស្ថាប័នពាក់ព័ន្ធ

-ធ្វើសេចក្តីព្រាងបូកសរុបរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់អង្គភាព តាមកាលកំណត់ ជូនប្រធានអង្គភាព ពិនិត្យ និងសម្រេច

-អនុវត្តភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានអង្គភាព ។

**មាត្រា៦ .-**

ផ្នែកអប់រំ បង្ការ ទប់ស្កាត់ និងសហប្រតិបត្តិការ មានតួនាទី និងភារកិច្ចដូចតទៅ :

-កសាងផែនការសកម្មភាព ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើពុករលួយតាមទស្សនៈ កម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍន៍ជាតិ

-កសាងឯកសារយុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយក្នុងអភិបាលកិច្ចល្អ

-ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ អន្តរជាតិ និងបង្កើតកម្មវិធីផ្សេងៗ ដើម្បីផ្សព្វផ្សាយដល់មហាជនឱ្យយល់ដឹងអំពីផលវិបាកនៃអំពើពុករលួយ

-ធ្វើការអប់រំក្រមសីលធម៌វិជ្ជាជីវៈដល់មន្ត្រីរាជការ អាជ្ញាធរដែនដី សិស្សានុសិស្ស និស្សិត កងកម្លាំងប្រដាប់អាវុធ និងមហាជន ដើម្បីចូលរួមក្នុងការបង្ការទប់ស្កាត់ និងកំចាត់អំពើពុករលួយ

**មាត្រា៩ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានខ្ទង់ថវិកាដោយឡែកមួយ នៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ ធនធាន និងថវិការបស់អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវផ្គត់ផ្គង់ដោយ :

-ថវិកាជាតិ

-ហិរញ្ញប្បទានពីអង្គការជាតិ និងអន្តរជាតិ ។

**មាត្រា១០ .-**

អង្គភាពប្រឆាំងអំពើពុករលួយ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា១១ .-**

អនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតអង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ អភិបាលខេត្ត ក្រុង និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ២ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១២

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៥ .អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០

## ស ម្រេ ច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ។

## ជំពូកទី២
## បេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

អង្គភាពប្រឆាំងអំពើពុករលួយ មានបេសកកម្មដឹកនាំការប្រយុទ្ធប្រឆាំងអំពើពុករលួយគ្រប់រូបភាព គ្រប់វិស័យ និងគ្រប់ជាន់ថ្នាក់ តាមរយៈវិធានការអប់រំ បង្ការ ទប់ស្កាត់ និងអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ ដោយមានការចូលរួមគាំទ្រពីមហាជន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ៣.-**

អង្គភាពប្រឆាំងអំពើពុករលួយមានភារកិច្ចដូចតទៅ៖

-អនុវត្តច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងបទល្មើសពុករលួយ

-រៀបចំកសាងផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើពុករលួយស្របតាមយុទ្ធសាស្ត្រ និងនយោបាយរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

-ដឹកនាំការងារទប់ស្កាត់ និងបង្ក្រាបអំពើពុករលួយ

-តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ និងធ្វើការស្រាវជ្រាវ ព្រមទាំងលើកវិធានការនានាពាក់ព័ន្ធនឹងបទល្មើសពុករលួយនៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈ និងឯកជនទាំងអស់ស្របតាមនីតិវិធីជាធរមាន

-ទទួល និងពិនិត្យរាល់ពាក្យប្តឹងដែលពាក់ព័ន្ធនឹងអំពើពុករលួយ ព្រមទាំងចាត់ការទៅតាមនីតិវិធីជាធរមាន

-ទទួល និងពិនិត្យពាក្យប្តឹងដែលពាក់ព័ន្ធនឹងការមិនអនុវត្តក្រមងព័ត៌មាន សេវាសាធារណៈ

-ស្វែងរក ពិនិត្យ និងរៀបចំឯកសារ និងព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ

-រក្សាការសម្ងាត់ជាដាច់ខាតចំពោះប្រភពព័ត៌មានទាក់ទងនឹងអំពើពុករលួយ

-ចាត់វិធានការចាំបាច់ដើម្បីរក្សាសន្តិសុខដល់បុគ្គលដែលផ្តល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ

-ធ្វើការគ្រប់គ្រងប្រព័ន្ធនៃការប្រកាសទ្រព្យសម្បត្តិ និងបំណុលដូចមានបញ្ញត្តិក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

-ដឹកនាំការងារឃោសនាអប់រំមហាជនអំពីផលវិបាកនៃអំពើពុករលួយ និងលើកទឹកចិត្តឲ្យមហាជនចូលរួមក្នុងការបង្ការ ទប់ស្កាត់ និងកម្ចាត់អំពើពុករលួយ

-ពិនិត្យ និងលើកគម្រោងថវិកាប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងរបស់អង្គភាពប្រឆាំងអំពើពុករលួយ

-ទទួលឆ្លើយបំភ្លឺដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរចំពោះរាល់សំណួរដែលលើកឡើង ដោយសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ឬសមាជិករដ្ឋសភា

-បម្រើសេវាការងារជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

-តែងតាំង ផ្លាស់ប្តូរ និងគ្រប់គ្រង ឬលើកសំណើតែងតាំង ផ្លាស់ប្តូរ មន្ត្រីរាជការក្រោមឱវាទក្នុងអង្គភាពប្រឆាំងអំពើពុករលួយ

-ធ្វើសហប្រតិបត្តិការជាមួយនឹងអង្គការជាតិ អង្គការតំបន់ អង្គការអន្តរជាតិនានាដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយឆ្លងដែន

-ធ្វើរបាយការណ៍អំពីសកម្មភាពទាំងឡាយរបស់អង្គភាពប្រឆាំងអំពើពុករលួយ ជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

-មានសិទ្ធិធ្វើការព្រមានចំពោះមុខសញ្ញាដែលក្នុងដំណាក់កាលដំបូងមានការខកខានមិនបានអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងគោលដៅបង្ការ និងទប់ស្កាត់អំពើពុករលួយ

-បំពេញភារកិច្ចផ្សេងៗទៀតតាមការបញ្ញត្តរបស់ច្បាប់ជាធរមាន និងតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**មាត្រា ៤.–**

អង្គភាពប្រឆាំងអំពើពុករលួយមានរចនាសម្ព័ន្ធដូចតទៅ៖

-អគ្គនាយកដ្ឋានរដ្ឋបាល និងសន្តិសុខ

-អគ្គនាយកដ្ឋានប្រតិបត្តិការ

-ផ្នែកស៊ើបអង្កេតផ្ទៃក្នុង

-ការិយាល័យប្រឆាំងអំពើពុករលួយរាជធានី ខេត្ត

-ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ។

រចនាសម្ព័ន្ធរបស់អង្គភាពប្រឆាំងអំពើពុករលួយជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៥.–**

ប្រធាន និងអនុប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងប្រធានអង្គភាពប្រឆាំងអំពើពុករលួយ មានជំនួយការមិនឲ្យលើសពី ៤ (បួន) រូប ដែលមានឋានៈស្មើអគ្គនាយក ឬអគ្គនាយករង ដើម្បីជួយការងាររបស់ខ្លួន។

សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ មានជំនួយការពី ១ (មួយ) ទៅ ២ (ពីរ) រូប ដែលមានឋានៈស្មើអគ្គនាយករង ឬប្រធាននាយកដ្ឋាន ដើម្បីជួយការងាររបស់ខ្លួន។

**មាត្រា ៦.–**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយចាប់ពីថ្នាក់ក្រោមនាយកដ្ឋាននិងការតែងតាំងមន្ត្រីរាជការនៅក្នុងស្ថាប័នប្រឆាំងអំពើពុករលួយ ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ តាមសំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ លើកសំណើតែងតាំងជំនួយការរបស់ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងប្រធាន ព្រមទាំងអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ដោយផ្អែកតាមសំណើរបស់ម្ចាស់សាមីសំណើ។

**មាត្រា ៧ .–**

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចប្រើប្រាស់ធនធានមនុស្ស សម្ភារៈ ឧបករណ៍ បច្ចេកទេសនៃនាយកដ្ឋានចារកម្ម ស៊ើបអង្កេត និងកម្លាំងពិសេសវាយលុកភេរវកម្មនៃនាយកដ្ឋានពិសេសនៃលេខាធិការដ្ឋានជាតិប្រឆាំងភេរវកម្ម។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយមានសិទ្ធិស្នើសុំកិច្ចសហការប្រមូលព័ត៌មាន និងតាមដានពីផ្នែកចារកម្មពីស្ថាប័ននានា និងសុំកម្លាំងប្រតិបត្តិការពីនគរបាលជាតិ កងរាជអាវុធហត្ថ និងកម្លាំងប្រដាប់អាវុធផ្សេងទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ អាចចុះអនុស្សរណៈយោគយល់គ្នាជាមួយនឹងស្ថាប័នជាតិពាក់ព័ន្ធដើម្បីឲ្យដំណើរការការងារបានរលូន។

**មាត្រា ៨.–**

តំណាងអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវបានអញ្ជើញឲ្យចូលរួមប្រជុំឆ្លងលិខិតបទដ្ឋាននានារបស់រាជរដ្ឋាភិបាល។

**មាត្រា ៩.–**

អង្គភាពប្រឆាំងអំពើពុករលួយ មានឧបការីមួយចំនួនដែលបំពេញតួនាទី និងភារកិច្ចតាមការប្រគល់ជូនរបស់ប្រធានអង្គភាព។

ឧបការី ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងអនុក្រឹត្យ។

## ជំពូកទី៣
## អគ្គនាយកដ្ឋានរដ្ឋបាល និងសន្តិសុខ

**មាត្រា ១០.–**

អគ្គនាយកដ្ឋានរដ្ឋបាល និងសន្តិសុខ មានតួនាទីជាសេនាធិការឲ្យអង្គភាពប្រឆាំងអំពើពុករលួយលើការងារសម្របសម្រួល និងគ្រប់គ្រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក បណ្តុះបណ្តាល សន្តិសុខ ប្រកាសទ្រព្យសម្បត្តិ និងបំណុល។

អគ្គនាយកដ្ឋានរដ្ឋបាល និងសន្តិសុខ មាននាយកដ្ឋានក្រោមឱវាទចំនួន៤៖

-នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល

-នាយកដ្ឋានសន្តិសុខ

-នាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុល។

អគ្គនាយកដ្ឋានរដ្ឋបាល និងសន្តិសុខ ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១១.–**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ទទួលបន្ទុក៖

-រៀបចំឲ្យមានទីកន្លែងទទួលពាក្យប្តឹង និងប្រអប់សំបុត្ររបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

-គ្រប់គ្រងឯកសារ និងលិខិតរដ្ឋបាលចេញ ចូល ដែលមិនមែនពាក្យប្តឹង

-សម្របសម្រួលសកម្មភាពគ្រប់គ្រងផ្នែករដ្ឋបាលរបស់អង្គភាពប្រឆាំងអំពើពុករលួយ

-គ្រប់គ្រង និងធ្វើចរាចរណ៍ឯកសាររដ្ឋបាលរបស់អង្គភាពប្រឆាំងអំពើពុករលួយ

-គ្រប់គ្រងថវិកា និងហិរញ្ញវត្ថុសម្រាប់ដំណើរការការងាររបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

-គ្រប់គ្រង និងធ្វើបញ្ជីសារពើភណ្ឌលើទ្រព្យសម្បត្តិរបស់អង្គភាពប្រឆាំងអំពើពុករលួយ

-រៀបចំគម្រោងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

-ប្រតិបត្តិកិច្ចការលទ្ធកម្មសាធារណៈរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ
-ទទួល និងបែងចែកសម្ភារៈបរិក្ខារជូនស្ថាប័នប្រឆាំងអំពើពុករលួយ
-រៀបចំការប្រជុំ សន្និបាត សន្និសីទ សិក្ខាសាលា កិច្ចការពិធីការ និងពិធីបុណ្យផ្សេងៗរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ
-ធ្វើរបាយការណ៍ជាប្រចាំអំពីសកម្មភាពការងាររបស់នាយកដ្ឋានជូនប្រធានអង្គភាពប្រឆាំងអំពើពុករលួយ
-ធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារ និងទិសដៅរបស់ស្ថាប័នប្រឆាំងអំពើពុករលួយប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
-ផ្តល់សេវារដ្ឋបាលជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ
-បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់។

**មាត្រា ១២.-**

នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល ទទួលបន្ទុក៖

-គ្រប់គ្រងបុគ្គលិកទាំងអស់របស់ អង្គភាពប្រឆាំងអំពើពុករលួយ
-រៀបចំបែបបទជ្រើសរើស តែងតាំង ផ្លាស់ប្តូរ ដំឡើងឋានៈ ដាក់វិន័យ និងដាក់ឲ្យចូលនិវត្តន៍តាមច្បាប់កំណត់
-រៀបចំបែបបទ និងលើកសំណើដើម្បីផ្តល់មេដាយការងារ និងគ្រឿងឥស្សរិយយសផ្សេងៗជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ និងអ្នកដែលមានស្នាដៃការងារល្អជូនអង្គភាពប្រឆាំងអំពើពុករលួយ
-កំណត់ក្របខណ្ឌ និងចំនួនបុគ្គលិករបស់អង្គភាពប្រឆាំងអំពើពុករលួយ ទាំងថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត
-រៀបចំរាល់សំណុំលិខិតរដ្ឋបាលសម្រាប់ការគ្រប់គ្រងអាជីព
-បណ្តុះបណ្តាល ហ្វឹកហាត់ធនធានមនុស្ស និងពង្រឹងសមត្ថភាពវិជ្ជាជីវៈប្រឆាំងអំពើពុករលួយទាំងក្នុង ទាំងក្រៅប្រទេស
-រៀបចំកម្មវិធី និងឯកសារសម្រាប់បង្រៀន និងហ្វឹកហាត់មន្ត្រីរបស់អង្គភាព និងត្រួតពិនិត្យការហ្វឹកហាត់
-ធ្វើរបាយការណ៍ជាប្រចាំអំពីសកម្មភាពការងាររបស់នាយកដ្ឋានជូនប្រធានអង្គភាពប្រឆាំងអំពើពុករលួយ
-បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាព ប្រឆាំងអំពើពុករលួយ។

នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១៣.-**

នាយកដ្ឋានសន្តិសុខ ទទួលបន្ទុក៖

-គ្រប់គ្រងកម្លាំងសន្តិសុខរបស់អង្គភាពប្រឆាំងអំពើពុករលួយ

-ចូលរួមក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសពុករលួយ

-ការពារ ថែរក្សាសណ្តាប់ធ្នាប់របស់ស្ថាប័នប្រឆាំងអំពើពុករលួយ និងបណ្តាញតាម រាជធានី ខេត្ត

-អនុរក្សទីកន្លែងឃាត់ខ្លួន និងទីកន្លែងឃុំខ្លួនបណ្តោះអាសន្នរបស់អង្គភាពប្រឆាំងអំពើពុក-រលួយ

-ការពារសុវត្ថិភាពដល់សាក្សី ម្ចាស់បណ្តឹង និងបុគ្គលដែលផ្តល់ព័ត៌មានពាក់ព័ន្ធអំពើពុករលួយ

-ស្នើសុំអន្តរាគមន៍ និងសហការពីសមត្ថកិច្ចកម្លាំងប្រដាប់អាវុធតាមការចាំបាច់ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ជាពិសេសក្នុងភារកិច្ចការពារសាក្សី និងម្ចាស់បណ្តឹង

-គ្រប់គ្រង និងថែទាំសម្ភារៈអាវុធរបស់អង្គភាពប្រឆាំងអំពើពុករលួយ

-ធ្វើរបាយការណ៍ជាប្រចាំ ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានជូនប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

-បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

នាយកដ្ឋានសន្តិសុខ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១៤.-**

នាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុល ទទួលបន្ទុក៖

-គ្រប់គ្រងប្រព័ន្ធប្រកាសទ្រព្យសម្បត្តិ និងបំណុល

-ការពារ និងថែរក្សាឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលឲ្យបានត្រឹមត្រូវ

-រក្សាការសម្ងាត់ចំពោះឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល

-រៀបចំ និងតាក់តែងលិខិតឯកសារគតិយុត្តពាក់ព័ន្ធនឹងការប្រកាសទ្រព្យសម្បត្តិ និងបំណុល

-កសាងផែនការសកម្មភាពស្តីពីការប្រកាសទ្រព្យសម្បត្តិ និងបំណុល

-ធ្វើទំនាក់ទំនងជាមួយបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល

-ទទួល និងចុះបញ្ជិកាលើឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល

-រៀបចំឲ្យមានប្រព័ន្ធទិន្នន័យ និងបច្ចេកវិទ្យាព័ត៌មានតាមឆ្នាំនីមួយៗ

-ចូលរួមការបើកស្រោមសំបុត្រ និងឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមការកំណត់របស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

-ធ្វើរបាយការណ៍ជាប្រចាំពីសកម្មភាពការងាររបស់នាយកដ្ឋានជូនប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

-បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

នាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុល ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី៤
## អគ្គនាយកដ្ឋានប្រតិបត្តិការ

**មាត្រា ១៥.-**

អគ្គនាយកដ្ឋានប្រតិបត្តិការ មានតួនាទីជាសេនាធិការឲ្យអង្គភាពប្រឆាំងអំពើពុករលួយ លើការ

ងារសម្របសម្រួល និងគ្រប់គ្រងកិច្ចការគតិយុត្ត ទទួលពាក្យប្តឹង ស៊ើបអង្កេត និងចារកម្ម បច្ចេកទេស និងកោសលវិច័យ អប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ បង្ក្រាប និងទំនាក់ទំនងអន្តរជាតិ ។

អគ្គនាយកដ្ឋានប្រតិបត្តិការ មាននាយកដ្ឋានក្រោមឱវាទចំនួន៤ ៖

-នាយកដ្ឋានកិច្ចការគតិយុត្ត ពាក្យប្តឹង និងអន្តរជាតិ

-នាយកដ្ឋានអប់រំ បង្ការ និងទប់ស្កាត់

-នាយកដ្ឋានបច្ចេកទេស និងកោសលវិច័យ

-នាយកដ្ឋានស៊ើបអង្កេត និងចារកម្ម។

អគ្គនាយកដ្ឋានប្រតិបត្តិការ ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១៦.-**

នាយកដ្ឋានកិច្ចការគតិយុត្ត ពាក្យប្តឹង និងអន្តរជាតិ ទទួលបន្ទុក៖

-អនុវត្តច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងអំពើពុករលួយ

-រៀបចំកសាងផែនការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានារបស់អង្គភាពប្រឆាំងអំពើពុករលួយ

-សម្របសម្រួលលើការងារកសាង និងតាក់តែងសេចក្តីព្រាងច្បាប់ បទបញ្ជា និងលិខិតបទ-ដ្ឋានគតិយុត្តដែលទាក់ទងនឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

-ស្វែងរក ពិនិត្យ និងរៀបចំឯកសារព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ

-ចុះបញ្ជីពាក្យប្តឹងតាមគ្រប់រូបភាពជាអាទិ៍ ទូរស័ព្ទ ទូរសារ អ៊ីម៉ែល ការិយាល័យទទួលពាក្យប្តឹង និងប្រអប់សំបុត្ររបស់អង្គភាពប្រឆាំងអំពើពុករលួយ

-ពិនិត្យ វិភាគពាក្យប្តឹង និងលើកយោបល់លើទិដ្ឋភាពច្បាប់ជូនអង្គភាពប្រឆាំងអំពើពុករលួយ

-គ្រប់គ្រងពាក្យប្តឹងពាក់ព័ន្ធនឹងអំពើពុករលួយគ្រប់ប្រភេទ

-រៀបចំ និងចងក្រងទិន្នន័យនៃពាក្យប្តឹងរបស់អង្គភាពតាមប្រព័ន្ធព័ត៌មានវិទ្យា

-រក្សាព័ត៌មានសម្ងាត់ចំពោះអ្នកប្តឹង និងសាក្សី

-ធ្វើទំនាក់ទំនងជាមួយអ្នកប្តឹង ឬសាក្សីក្នុងការប្រមូលព័ត៌មានបន្ថែម

-សហការជាមួយនឹងនាយកដ្ឋានផ្សេងៗ ស្ថាប័នមានសមត្ថកិច្ចនានា និងស្ថាប័នតុលាការគ្រប់ជាន់ថ្នាក់ ដើម្បីបញ្ជូនសំណុំរឿង និងជនល្មើសទៅតុលាការ

-ធ្វើជាតំណាងអង្គភាពនៅក្នុងនីតិវិធីតុលាការ

-រៀបចំចម្លើយឆ្លើយបំភ្លឺដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ ចំពោះរាល់សំណួរដែលលើកឡើងដោយសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ឬសមាជិករដ្ឋសភា

-ទទួលជួយអង្គភាពអំពីការងារជួយគ្នាទៅវិញទៅមកផ្នែកច្បាប់សម្រាប់ការងារអាស៊ាន

-សម្របសម្រួល និងចាត់ចែងកិច្ចការគតិយុត្តជាមួយមេធាវីរបស់អង្គភាពប្រឆាំងអំពើពុករលួយ

-រៀបចំចងក្រងឯកសារច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងអំពើពុករលួយ

-សម្របសម្រួលកិច្ចការបរទេសពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ

-សម្របសម្រួលជំនួយអន្តរជាតិដើម្បីពង្រឹងស្ថាប័នប្រឆាំងអំពើពុករលួយជាអាទិ៍ការបណ្តុះបណ្តាលធនធានមនុស្ស និងសម្ភារៈបច្ចេកទេសផ្សេងៗ

-ធ្វើទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ និងទីភ្នាក់ងារប្រឆាំងអំពើពុករលួយនានារបស់រដ្ឋបរទេស

-សហការជាមួយដៃគូអភិវឌ្ឍនានា ដើម្បីបង្កើតយន្តការសម្រាប់គ្រប់គ្រងជំនួយតាមការចាំបាច់

-សម្របសម្រួល និងរៀបចំបេសកកម្មក្រៅប្រទេសរបស់ថ្នាក់ដឹកនាំ និងប្រតិភូរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

-សហការជាមួយនឹងនាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានផ្សេងៗ ក្នុងការរៀបចំប្រជុំ និងពិធីផ្សេងទៀតពាក់ព័ន្ធនឹងកិច្ចការអន្តរជាតិ

-ធ្វើរបាយការណ៍ជាប្រចាំពីសកម្មភាពការងាររបស់នាយកដ្ឋានជូនប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

-បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

នាយកដ្ឋានកិច្ចការគតិយុត្ត ពាក្យប្តឹង និងអន្តរជាតិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធាន មួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១៧.-**

នាយកដ្ឋានអប់រំ បង្ការ និងទប់ស្កាត់ ទទួលបន្ទុកៈ

-រៀបចំកសាងផែនការយុទ្ធសាស្ត្រ និងនយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយជូនប្រធានអង្គភាពប្រឆាំងអំពើពុករលួយពិនិត្យនិងដាក់ជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

-រៀបចំកសាងផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើពុករលួយ របស់អង្គភាពប្រឆាំងអំពើពុករលួយ ដោយសហការជាមួយនឹងនាយកដ្ឋានផ្សេងៗ

-ដឹកនាំ និងសហការកសាងផែនការសកម្មភាពប្រឆាំងអំពើពុករលួយនៅតាមក្រសួង ស្ថាប័ន អង្គភាពនានា និងរាជធានី ខេត្ត

-ជំរុញការអនុវត្តកម្រងព័ត៌មានសេវាសាធារណៈដែលចងក្រងដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ឲ្យកាន់តែមានប្រសិទ្ធភាពនៅក្នុងក្រសួង ស្ថាប័ន អង្គភាពនានា និងរាជធានី ខេត្ត

-អប់រំ ផ្សព្វផ្សាយច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ

-ដឹកនាំការងារឃោសនាអប់រំមហាជនអំពីផលវិបាកនៃអំពើពុករលួយ

-ចងក្រង និងរៀបចំបោះពុម្ពពាល់លិខិតបទដ្ឋានជាធរមានដែលទាក់ទងនឹងអំពើពុករលួយ

-រៀបចំបង្កើត និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា និងគេហទំព័ររបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

-ដឹកនាំ សហការកែលម្អ និងផ្សព្វផ្សាយក្រមសីលធម៌របស់ស្ថាប័ន និងមូលដ្ឋាននីមួយៗ និងត្រួតពិនិត្យការអនុវត្តក្រមសីលធម៌ទាំងនេះឲ្យមានប្រសិទ្ធភាព

-ជំរុញ និងលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋានសាធារណៈទាំងអស់ ឲ្យចូលរួមផ្តល់ព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ

-រៀបចំចាត់ចែងសកម្មភាព ថតស្ប៉ុត និងផ្ទាំងទស្សនីយភាពផ្សេងទៀត ប្រកាសព័ត៌មានដែលទាក់ទងនឹងជោគជ័យនៃប្រតិបត្តិការ

-រៀបចំមណ្ឌលទិន្នន័យភ្ជាប់ពីស្ថាប័ននានាមកស្ថាប័នប្រឆាំងអំពើពុករលួយ
-អភិវឌ្ឍកម្មវិធីកុំព្យូទ័របម្រើរាល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ រាប់ទាំងកម្មវិធីគ្រប់គ្រង វិភាគ និងការធានាសន្តិសុខ
-ស្នើសុំកិច្ចសហការពីស្ថាប័នជាតិ និងអន្តរជាតិក្នុងការធ្វើកោសលវិច័យនានា
-ធ្វើការវិភាគទៅលើវត្ថុតាងពាក់ព័ន្ធនឹងបទល្មើស
-ទទួលធ្វើការវិភាគលើវត្ថុតាងផ្សេងទៀតតាមការស្នើសុំពីអាជ្ញាធរមានសមត្ថកិច្ច
-រៀបចំឲ្យមានមន្ទីរពិសោធ និងផ្នែកកោសលវិច័យដោយកុំព្យូទ័រ
-គ្រប់គ្រង និងដំណើរការឧបករណ៍ប៉ូលីក្រាហ្វសម្រាប់អង្គភាពប្រឆាំងអំពើពុករលួយ និងសម្រាប់ការពិចារណារបស់តុលាការដោយឈរលើមូលដ្ឋានស្ម័គ្រចិត្តពីសាមីខ្លួន
-ធ្វើរបាយការណ៍ជាប្រចាំពីសកម្មភាពការងាររបស់នាយកដ្ឋានជូនប្រធានអង្គភាពប្រឆាំងអំពើពុករលួយ
-បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

នាយកដ្ឋានបច្ចេកទេស និងកោសលវិច័យ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ១៩.-**

នាយកដ្ឋានស៊ើបអង្កេត និងចារកម្ម ទទួលបន្ទុក៖

-តាមដានស៊ើបអង្កេត ត្រួតពិនិត្យ និងស្រាវជ្រាវបទល្មើសពុករលួយដោយសម្ងាត់ និងដោយចំហ
-ស្រាវជ្រាវ ប្រមូលព័ត៌មាន និងភស្តុតាងពាក់ព័ន្ធនឹងអំពើពុករលួយគ្រប់រូបភាព
- កំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង
-ការពារ និងថែរក្សាភស្តុតាងដើម្បីបញ្ជូនទៅតុលាការ
-សម្ភាស ស្តាប់ចម្លើយជនសង្ស័យពាក់ព័ន្ធនឹងអំពើពុករលួយ
-សម្ភាសសាក្សី អ្នកប្តឹងពីបទល្មើសពុករលួយ
-ធ្វើកំណត់ហេតុសម្ភាស ស្តាប់ចម្លើយ ដើម្បីបញ្ជូនទៅតុលាការ
-សហការជាមួយនាយកដ្ឋានសន្តិសុខ ដើម្បីការពារសន្តិសុខ និងសុវត្ថិភាពជូនសាក្សីម្ចាស់បណ្តឹង និងបុគ្គលដែលផ្តល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ
-ទទួលខុសត្រូវក្នុងការឆ្លើយបំភ្លឺចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់
-ទទួលបន្ទុកអនុវត្តដីកាផ្ទេរសិទ្ធិពីតុលាការ
-ពិនិត្យឯកសារនានាព្រមទាំងឯកសាររក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក
-ធ្វើកិច្ចសហការជាមួយនឹងនាយកដ្ឋានកិច្ចការគតិយុត្ត ពាក់ព័ន្ធនឹងបទល្មើសពុករលួយឆ្លងដែន
-ពិនិត្យ និងផ្តល់យោបល់លើកិច្ចការស៊ើបអង្កេតជូនអង្គភាពប្រឆាំងអំពើពុករលួយ
-កសាងកម្លាំងសម្ងាត់ជាបណ្តាញរបស់អង្គភាពប្រឆាំងអំពើពុករលួយ
-រក្សាឯកសារស៊ើបអង្កេតជាសម្ងាត់របស់នាយកដ្ឋាន ក្នុងករណីចាំបាច់
-ធ្វើរបាយការណ៍ជាប្រចាំអំពីសកម្មភាពការងាររបស់ នាយកដ្ឋានជូនប្រធានអង្គភាពប្រឆាំងអំពើពុករលួយ
-បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

នាយកដ្ឋានស៊ើបអង្កេត និងចារកម្ម ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

## ជំពូកទី៥
## ផ្នែកស៊ើបអង្កេតផ្ទៃក្នុង

**មាត្រា ២០.-**

ផ្នែកស៊ើបអង្កេតផ្ទៃក្នុងមានភារកិច្ច ឃ្លាំមើល និងតាមដាន ពីសកម្មភាពការងាររបស់មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ។

ផ្នែកស៊ើបអង្កេតផ្ទៃក្នុងដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

ផ្នែកស៊ើបអង្កេតផ្ទៃក្នុង ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

## ជំពូកទី៦
## ការិយាល័យប្រឆាំងអំពើពុករលួយរាជធានី ខេត្ត

**មាត្រា ២១.-**

នៅតាមរាជធានី ខេត្ត អាចមានការិយាល័យប្រឆាំងអំពើពុករលួយ ដែលទទួលបន្ទុកអនុវត្តការងារប្រឆាំងអំពើពុករលួយនៅមូលដ្ឋាន។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យប្រឆាំងអំពើពុករលួយរាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី៧
## ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ

**មាត្រា ២២.-**

នៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ ត្រូវបង្កើតក្រុមជនបង្គោលប្រឆាំងអំពើពុករលួយចាប់ពីមួយក្រុមឡើងទៅដើម្បីចូលរួមអប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើពុករលួយ ។

**មាត្រា ២៣.-**

ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ មានសមាជិកចាប់ពី ៣ (បី) រូបដល់ ១១ (ដប់មួយ) រូប ដែលមានសមាសភាពដូចតទៅ ប្រធានក្រុម ១ (មួយ) រូប អនុប្រធានក្រុម ១ (មួយ) ទៅ ២ (ពីរ) រូប និងសមាជិកក្រុមមួយចំនួន។

ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ត្រូវចាត់តាំងដោយប្រកាស ឬសេចក្តីសម្រេចរបស់ប្រធានសាមីនៃក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈទាំងនោះ។

**មាត្រា ២៤.-**

សមាជិកនៃក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

-ជាមន្ត្រីនៅក្នុងក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ ហើយមានតួនាទីដែលអាចដឹកនាំ និងបំពេញការងារក្រុមជនបង្គោលបាន

-មានភាពស្អាតស្អំ ឈ្លាសវៃ សមត្ថភាព ឆន្ទៈ និងពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញការងារប្រឆាំងអំពើពុករលួយ។

**មាត្រា ២៥.-**

ក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-សម្របសម្រួលការងារអប់រំ ផ្សព្វផ្សាយ ច្បាប់ លិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ នៅក្នុងក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈរបស់ខ្លួន

-ធ្វើបញ្ជីសមាសភាពបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និងបំណុល ដើម្បីផ្ញើមកអង្គភាពប្រឆាំងអំពើពុករលួយ

-ជួយសម្រួលឲ្យការងារប្រកាសទ្រព្យសម្បត្តិ និងបំណុល ដំណើរការបានត្រឹមត្រូវ ច្បាស់លាស់ និងទាន់ពេល

-ធ្វើជាសេនាធិការឲ្យប្រធានសាមីនៃក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈក្នុងការកសាងផែនការសកម្មភាព បង្ការ ទប់ស្កាត់អំពើពុករលួយ កសាងអង្គភាពសស្អាត និងលើកសរសើរ ព្រមទាំងការដាក់ពិន័យ កសាង និងពង្រឹងក្រមសីលធម៌ ព្រមទាំងបទប្បញ្ញត្តិនៃការទទួលអំណោយ

-ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលអនុវត្តជូនអង្គភាពប្រឆាំងអំពើពុករលួយដោយមានការឯកភាពពីប្រធានសាមីនៃក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈនោះ។

## ជំពូកទី៨
## ឯកសណ្ឋាន ប្រាក់រង្វាន់ និងការប្រើប្រាស់អាវុធ

**មាត្រា ២៦.-**

កម្លាំងសន្តិសុខរបស់អង្គភាពប្រឆាំងអំពើពុករលួយមានឯកសណ្ឋានសំគាល់ដោយឡែក។

ឯកសណ្ឋានត្រូវកំណត់ដោយប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

**មាត្រា ២៧.-**

អង្គភាពប្រឆាំងអំពើពុករលួយ មានសិទ្ធិទទួលប្រាក់រង្វាន់ក្នុងប្រតិបត្តិការរបស់ខ្លួនដែលបានទទួលជោគជ័យ ដើម្បីលើកទឹកចិត្តមន្ត្រី អ្នកសហការ និងកសាងមូលដ្ឋានសម្ភារៈរបស់ខ្លួន។

ប្រាក់រង្វាន់ជាក់ស្តែងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើ របស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ។

**មាត្រា ២៨.-**

អង្គភាពប្រឆាំងអំពើពុករលួយមានសិទ្ធិប្រើប្រាស់អាវុធក្នុងការបំពេញបេសកកម្មរបស់ខ្លួន។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយចេញបណ្ណប្រើប្រាស់អាវុធដល់មន្ត្រី និងអ្នកសហការរបស់ខ្លួនបន្ទាប់ពីអង្គភាពប្រឆាំងអំពើពុករលួយបានចុះបញ្ជីអាវុធ និងទទួលបានបណ្ណសំគាល់សិទ្ធប្រើប្រាស់អាវុធជាអចិន្ត្រៃយ៍ពីក្រសួងមហាផ្ទៃ។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា ២៩.-**

មន្ត្រីរាជការ និងសកម្មភាពការងារទាំងអស់ ដែលស្ថិតនៅក្នុងក្របខណ្ឌនៃអង្គភាពដើមប្រឆាំងអំពើពុករលួយ ត្រូវបានផ្ទេរ និងបន្តនិរន្តរភាពនៅក្នុងអង្គភាពប្រឆាំងអំពើពុករលួយ ស្របតាមអនុក្រឹត្យនេះ។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា ៣០.-**

អនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋលេខាធិការនៃរដ្ឋលេខា-ធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៣១
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៧. អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# រូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣០ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីសញ្ញារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតរូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ សម្រាប់ប្រើប្រាស់ក្នុងដំណើរការការងាររបស់ខ្លួន។

ស្ថាប័នប្រឆាំងអំពើពុករលួយសរសេរអក្សរកាត់ថា ស.ប.ព. ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយសរសេរអក្សរកាត់ថា ក.ជ.ប.ព. និងអង្គភាពប្រឆាំងអំពើពុករលួយសរសេរអក្សរកាត់ថា អ.ប.ព.។

**មាត្រា ២.-**

ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយប្រើប្រាស់រួមគ្នារូបសញ្ញារបស់ស្ថាប័នប្រឆាំងអំពើពុករលួយ។

រូបសញ្ញារបស់ស្ថាប័នប្រឆាំងអំពើពុករលួយមានរូបភាព និងខ្នាតដូចតទៅ៖

-ខ្សែរង្វង់រាងពងក្រពើមានផ្ទៃអមសងខាងពណ៌ខៀវនិងផ្ទៃខាងក្នុងពណ៌ក្រហម មានចារឹកអក្សរខ្មែរពណ៌សថា " ព្រះរាជាណាចក្រកម្ពុជា " នៅផ្នែកខាងលើ និងចារឹកអក្សរឡាតាំងជាភាសាអង់គ្លេសថា "KINGDOM OF CAMBODIA " នៅផ្នែកខាងក្រោម តំណាងឱ្យប្រជាជាតិខ្មែរ

-នៅខាងក្នុងរង្វង់រាងពងក្រពើ មានផ្ទៃពណ៌ស រំលេចរូបសញ្ញារាជរដ្ឋាភិបាលពណ៌មាស តំណាង ឱ្យស្ថាប័ននីតិប្រតិបត្តិ

-នៅខាងក្នុងរង្វង់រាងពងក្រពើ ផ្នែកខាងក្រោម មានចារឹកអក្សរខ្មែរពណ៌ខៀវថា ស្ថាប័នប្រឆាំងអំពើពុករលួយ និងអក្សរកាត់ថា "ស.ប.ព." នៅខាងក្រោម ដែលជាយន្តការជាតិក្នុងការប្រឆាំងអំពើ-ពុករលួយ

-ផ្ទៃពណ៌ស និងអក្សរពណ៌ស តំណាងឱ្យសុចរិត និងភាពស្អាតស្អំនៃសង្គមជាតិ

-ខ្សែបូពណ៌មាសទ្រពីក្រោមមានចារឹកអក្សរឡាតាំងជាភាសាអង់គ្លេសពណ៌សថា "ANTI-CORRUPTION INSTITUTION" និងអក្សរកាត់ថា "ACI" តំណាងឱ្យការចូលរួមគាំទ្រពីមហាជន និងកិច្ចសហប្រតិបត្តិការពីសហគមន៍តំបន់ និងអន្តរជាតិក្នុងការប្រឆាំងអំពើពុករលួយ

-រូបសញ្ញារបស់ស្ថាប័នប្រឆាំងអំពើពុករលួយមានទទឹង ៣ ភាគ ៤ នៃបណ្តោយ ។

រូបសញ្ញាដែលមានខ្លឹមសារដូចបានចែងខាងលើ ជាឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

រូបសញ្ញារបស់ស្ថាប័នប្រឆាំងអំពើពុករលួយត្រូវបានប្រើប្រាស់ ដូចខាងក្រោម៖

-ដាក់នៅកន្លែងធ្វើការរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

-ដាក់នៅលើក្បាលលិខិតផ្លូវការរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុកលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ

-បំពាក់លើឯកសណ្ឋានរបស់កម្លាំងសន្តិសុខ នៃអង្គភាពប្រឆាំងអំពើពុករលួយ

-ប្រើប្រាស់សម្រាប់ស្ថាប័នប្រឆាំងអំពើពុករលួយ ក្នុងករណីផ្សេងៗទៀត។

**មាត្រា ៤.-**

ស្ថាប័នប្រឆាំងអំពើពុករលួយមានត្រាមូលពីរគឺត្រាប្រើប្រាស់សម្រាប់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងត្រាប្រើប្រាស់សម្រាប់អង្គភាពប្រឆាំងអំពើពុករលួយ។

ត្រារបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ មានវណ្ឌពីរជាន់ រំលេចរូបប្រាសាទអង្គរវត្តកំពូលបីនៅចំកណ្តាល។ នៅខាងក្រោមរូបប្រាសាទអង្គរវត្តកំពូលបីមានឆ្លាក់អក្សរ "ស្ថាប័នប្រឆាំងអំពើពុករលួយ" ។ ផ្នែកខាងលើមានឆ្លាក់អក្សរ "ព្រះរាជាណាចក្រកម្ពុជា" ស្របតាមវណ្ឌ ផ្នែកខាងក្រោមមានឆ្លាក់អក្សរ "ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ" ស្របតាមវណ្ឌ និងនៅចន្លោះពាក្យទាំងពីរ មានរូបផ្កាចន្ទន៍នៅសងខាង។

ត្រារបស់អង្គភាពប្រឆាំងអំពើពុករលួយ មានវណ្ឌពីរជាន់ រំលេចរូបប្រាសាទអង្គរវត្តកំពូលបី នៅចំកណ្តាល។ នៅខាងក្រោមរូបប្រាសាទអង្គរវត្តកំពូលបីមានឆ្លាក់អក្សរ "ស្ថាប័នប្រឆាំងអំពើពុករលួយ" ។

ផ្នែកខាងលើមានឆ្លាក់អក្សរ "ព្រះរាជាណាចក្រកម្ពុជា" ស្របតាមវណ្ណ ផ្នែកខាងក្រោមមានឆ្លាក់អក្សរ "អង្គភាពប្រឆាំងអំពើពុករលួយ" ស្របតាមវណ្ណ និងនៅចន្លោះពាក្យទាំងពីរ មានរូបផ្កាចន្ទន៍នៅសងខាង ។

ត្រាដែលមានខ្លឹមសារដូចបានចែងខាងលើ ជាឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ ។

ក្រៅពីនេះប្រធានអង្គភាពប្រឆាំងអំពើពុករលួយអាចបង្កើតឲ្យមានត្រាប្រើប្រាស់តាមជំនាញ និងតាមរចនាសម្ព័ន្ធរបស់ខ្លួននៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានតាមការចាំបាច់។

**មាត្រា ៥.-**

អនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៨ ស្តីពីរូបសញ្ញានៃអង្គភាពប្រឆាំងអំពើពុករលួយ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១ នៃអនុក្រឹត្យលេខ០៧អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១១

ព្រះរាជាណាចក្រកម្ពុជា

អង្គភាពប្រឆាំងអំពើពុករលួយ

អ.ប.ព.

KINGDOM OF CAMBODIA

ANTI-CORRUPTION INSTITUTION-ACI

ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១១






# រចនាសម្ព័ន្ធរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

